# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣


បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា

នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

ត្រូវនឹងថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០១៩

# បុព្វកថា

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយកំណើនខ្ពស់ និងរឹងមាំ សម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយជោគជ័យគួរជាទីមោទនៈ ដោយសម្រេចបានទាំងកំណើនចំណូល, ការពង្រឹងធនធានមនុស្ស, សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច, ការសម្របសម្រួលក្រសួង-ស្ថាប័នគ្រប់គ្រង និងប្រមូលចំណូល និងការលើកកម្ពស់វប្បធម៌បង់ពន្ធរបស់ប្រជាពលរដ្ឋ ។ ជាក់ស្តែង ចំណូលចរន្តសរុបបានកើនឡើងពី ១៥,១% នៃ ផ.ស.ស. នៅឆ្នាំ ២០១៣ ដល់ ២២,០% នៃ ផ.ស.ស. នៅឆ្នាំ ២០១៨ ហើយមានកំណើនជាមធ្យមប្រមាណ ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ។ ភាពជោគជ័យដ៏កម្រក្នុងការកៀរគរចំណូលរបស់កម្ពុជា ត្រូវបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទាំងក្នុងតំបន់ និងសកលលោក ។

ជាមួយគ្នានេះ កំណើនចំណូលនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ដោយបានរួមចំណែកក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ, ការកាត់បន្ថយភាពក្រីក្រមកក្នុងរង្វង់ ១០% ក្នុងឆ្នាំ ២០១៨, ការបង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ, ការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ, ការបង្កើនគុណភាពនិងពង្រីកវិសាលភាពសេវាសាធារណៈសំខាន់ៗ ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, អប់រំ, សុខាភិបាល និងសេវាមូលដ្ឋានចាំបាច់ផ្សេងទៀត រួមទាំងរបបសន្តិសុខសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋទូទៅ និងការកាត់បន្ថយគម្លាតនៃការរីកចម្រើនរវាងទីក្រុង និងជនបទ ជាពិសេសការបន្តពង្រឹងភាពជាម្ចាស់ និងឯករាជ្យភាពកម្ពុជាក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍរបស់ខ្លួន ។

**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ជាការបន្តកែទម្រង់ជាយុទ្ធសាស្ត្រ មួយដំណាក់កាលទៀត ដែលកាន់តែមុតស្រួច និងកាន់តែស៊ីជម្រៅ ក្នុងការលើកកម្ពស់សមត្ថភាពរដ្ឋបាលប្រមូលចំណូល, ការបន្តពង្រឹងអភិបាលកិច្ច, ការលើកកម្ពស់គុណភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវា និងការរៀបចំគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ សំដៅលើកកម្ពស់បរិយាកាសធុរកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និយាយជារួម និងជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលមួយយ៉ាងសំខាន់ក្នុងការបន្តកៀរគរចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តវិធានការកែទម្រង់នានា ជាពិសេសរួមចំណែកក្នុងការអនុវត្តឱ្យចេញជាផ្លែផ្កានូវ **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** និយាយដោយឡែក ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ៤ គឺ÷ (១)ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២)រក្សាបាននូវចីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល, (៣)ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង (៤)ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប, បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន ។

ជារួម យុទ្ធសាស្ត្រនេះមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើប ដែលអាចឆ្លើយតបទៅនឹងបរិការណ៍នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងដំណាក់កាលប្រែប្រួលថ្មីមួយទៀត ដោយធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របតាមគោលដៅរួមរបស់រាជរដ្ឋាភិបាលគឺ កសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែមានភាពស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីសម្រេចឱ្យបាននូវឋានៈជាប្រទេសមាន **ចំណូលមធ្យមកម្រិតខ្ពស់** នៅឆ្នាំ ២០៣០ ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះបានកំណត់គោលដៅ ២ សំខាន់ៗគឺ÷ (១)ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិច 0,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និង(២)បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។

ជាចុងក្រោយ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែង ទាំងកម្លាំងកាយ និងកម្លាំងចិត្ត របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានសហការគ្នាល្អក្នុងការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយភាពជោគជ័យខ្ពស់ ។ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅ លើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងលទ្ធផលជាក់ស្តែង សំដៅចូលរួមគាំទ្រដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យមានភាពរុងរឿងជានិច្ចនិរន្តរ៍ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នា និងការរំពឹងទុកកាន់តែខ្ពស់របស់ប្រជាពលរដ្ឋកម្ពុជា ។ ក្នុងន័យនេះ ខ្ញុំជឿជាក់ថាគ្រប់តួអង្គពាក់ព័ន្ធទាំងអស់នឹងបន្តខិតខំប្រឹងប្រែងទ្វេដងប្រកបដោយសុឆន្ទៈ, បុរេសកម្ម, អន្តរសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ដោយប្រកាន់ខ្ជាប់នូវអភិក្រម ៥ ប្រការគឺ “**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**” ។

ថ្ងៃព្រហ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** នេះត្រូវបានរៀបចំឡើងផ្អែកលើបទពិសោធន៍ល្អៗដកស្រង់ចេញពីការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** និងគិតគូរលើគ្រប់ទិដ្ឋភាពការផ្លាស់-ប្តូរយ៉ាងលឿននៃរចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គម ទាំងក្នុងប្រទេស, តំបន់ និងសកលលោក, ការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការត្រៀមខ្លួនរបស់កម្ពុជាសម្រាប់សេដ្ឋកិច្ចឌីជីថល ។ល។ ជាងនេះទៅទៀត ឯកសារនេះត្រូវបានរៀបចំឡើងដោយឆ្លងកាត់ ការសិក្សាស្រាវជ្រាវ, វិភាគ និងផ្លាស់ប្តូរយោបល់, គំនិត និងទស្សនៈធំៗ តាមរយៈការធ្វើទស្សនកិច្ចសិក្សាទៅប្រទេសក្នុងតំបន់ និងសកលលោក, ការប្រឹក្សាយោបល់ជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងអ្នកជំនាញការក្នុងស្រុកនិងបរទេស ជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោកជាដើម, ការប្រឹក្សាយោបល់ជាមួយសមាគមពាណិជ្ជកម្មក្នុងស្រុក និងវិស័យឯកជន និងការពិភាក្សាជាច្រើនលើកច្រើនសាទាំងផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ។ ជារួម យើងធានាបានទាំងស្រុងនូវភាពជាម្ចាស់ក្នុងការសម្រេចបាននូវការរៀបចំយុទ្ធសាស្ត្រនេះ ដោយបង្កើត និងដឹកនាំ ក្រុមការងារធ្វើការសិក្សាស្រាវជ្រាវ, ប្រមូលធាតុចូលពីគ្រប់តួអង្គពាក់ព័ន្ធ និងតាក់តែងគោលនយោបាយ ដើម្បីឱ្យការរៀបចំឯកសារនេះស្របទៅតាមទិដ្ឋភាពឧត្តមានុ-វត្តន៍អន្តរជាតិ និងតាមតថភាពជាក់ស្តែងនៃកម្ពុជា ។

**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** កំណត់ទស្សនវិស័យវែងឆ្ងាយក្នុងការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយបន្តផ្តោតសំខាន់លើការកសាងរដ្ឋបាលមួយ ដែលមានសមត្ថភាពរឹងមាំ ដើម្បីរួមចំណែកគាំទ្រការងារកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេស **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ។ សម្រាប់រយៈពេល ៥ ឆ្នាំទៅមុខ យុទ្ធសាស្ត្រកៀរគរចំណូលនេះ នឹងបន្តផ្តោតលើការបង្កើនសមត្ថភាពស្ថាប័ន និងធនធានមនុស្ស, ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងស្របតាមបរិការណ៍អភិវឌ្ឍន៍ថ្មី, ការពង្រឹងប្រសិទ្ធភាពនៃការសម្របសម្រួលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, ការកែសម្រួលនិងដាក់ចេញថ្មីនៃវិធានការគោលនយោបាយដោះស្រាយបញ្ហាប្រឈម, ការបន្តធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធ និង មិនមែនសារពើពន្ធ ដើម្បីធានាសង្គតិភាពជាមួយនឹងទិសដៅការកែទម្រង់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសដាក់ចេញ និងផ្សារភ្ជាប់នូវវិធានការដែលមានចរិតយុទ្ធសាស្ត្រជាមួយនឹងសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីងាយស្រួលត្រួតពិនិត្យ និងវាយតម្លៃ ។

ក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយសមិទ្ធកម្មដ៏ល្អ ទាំងទិដ្ឋភាពការប្រមូលចំណូល, ការកែលម្អវប្បធម៌បង់ពន្ធ និងការពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ជាការពិតណាស់ លទ្ធផលដ៏ត្រចះត្រចង់នៃការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** មិនអាចកាត់ផ្តាច់ចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រមូលចំណូល, កិច្ចសហការល្អនិងការចូលរួមពីវិស័យឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ ។

ក្នុងស្មារតីនេះ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាស្ថាប័នដឹកមុខក្នុងការអនុវត្ត និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់, វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្នុងការរួមគ្នាសម្រេចបានជោគជ័យដ៏ធំមួយក្នុងការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** និងសូមជំរុញលើកទឹកចិត្តផ្តល់ការគាំទ្រ និងបន្តរួមគ្នាអនុវត្ត ដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយបុរេសកម្ម និងការតស៊ូក្នុងការជំនះនូវឧបសគ្គ ដើម្បីឱ្យសម្រេចបាននូវចក្ខុវិស័យ, គោលបំណង និងគោលដៅនៃ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** សំដៅចូលរួមគាំទ្រដល់ការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មី ។ ការអនុវត្តយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព នឹងចូលរួមឆ្លើយតបទៅការកើនឡើងតម្រូវការគុណភាពសេវាអ្នកជាប់ពន្ធកាន់តែខ្ពស់, ការធានាបានសមធម៌សង្គម និងចីរភាពកំណើនចំណូលក្នុងការបំពេញតម្រូវការហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់ការអភិវឌ្ឍរបស់កម្ពុជា ដូចដែលបានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** របស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង-ស្ថាប័ននឹងបន្តចូលរួមក្នុងកិច្ចដំណើរការនៃការកែទម្រង់ស៊ីជម្រៅលើការប្រមូលចំណូលតាមតួនាទីរបស់ខ្លួន និងសម្រេចបានគោលដៅទៅតាមកាលវេលាកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះជោគវាសនារបស់កម្ពុជា និងឈរលើគោលការណ៍តម្កល់ប្រយោជន៍ជាតិ និងប្រជាជនជាធំ ។ ខ្ញុំក៏សូមគោរពសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមប្រកបដោយឆន្ទៈនយោបាយមុតស្រួច លើការងារកែទម្រង់របស់រាជរដ្ឋាភិបាល ហើយតែងតែផ្តល់ការគាំទ្រផ្នែកនយោបាយ និងផ្តល់អនុសាសន៍ល្អៗសំដៅតម្រង់ទិសរាល់កម្មវិធីកែទម្រង់ ដើម្បីឱ្យការអនុវត្តសម្រេចបានជោគជ័យ និងចីរភាព ។

ថ្ងៃ [illegible] ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

ជំពូកទី១÷ សេចក្តីផ្តើម................................................................................................ ១
ជំពូកទី២÷ ការវាយតម្លៃការអនុវត្តយុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨.................... ៣
២.១ វឌ្ឍនភាពនៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ.................................................... ៣
២.២ វឌ្ឍនភាពនៃការកែទម្រង់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ..................................... ៤
២.៣ វឌ្ឍនភាពនៃការកែទម្រង់រដ្ឋបាលប្រមូលចំណូលមិនមែនសារពើពន្ធ....................................... ៥
ជំពូកទី៣÷ ចក្ខុវិស័យ, គោលបំណង, គោលដៅ និងអភិក្រម នៃយុទ្ធសាស្រ្តកៀរគរចំណូល ២០១៩-២០២៣... ៨
៣.១ ចក្ខុវិស័យ.............................................................................................. ៨
៣.២ គោលបំណង និងគោលដៅ.................................................................................. ៨
៣.៣ អភិក្រមនៃការរៀបចំយុទ្ធសាស្រ្ត ........................................................................ ៨
ជំពូកទី៤÷ ទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ.................................................... ១០
៤.១ ទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ............................................................ ១០
ក. ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច ............................................................. ១១
ខ. មុខងារប្រតិបត្តិការស្នូល................................................................................. ១២
គ. មុខងារគាំទ្រ ........................................................................................ ១៤
៤.២ ទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ........................................... ១៦
ក. កិច្ចសម្រួលពាណិជ្ជកម្ម ............................................................................. ១៦
ខ. ការកែលម្អ និងពង្រឹងអភិបាលកិច្ច.................................................................... ១៩
គ. ការគ្រប់គ្រងបែបយុទ្ធសាស្រ្ត.......................................................................... ២០
៤.៣ គោលនយោបាយសារពើពន្ធ ............................................................................... ២១
៤.៣.១ គោលនយោបាយអាករពិសេស............................................................................. ២១
៤.៣.២ ពន្ធលើអចលនទ្រព្យ ..................................................................................... ២៣
៤.៣.៣ អាករលើតម្លៃបន្ថែម....................................................................................... ២៤
៤.៣.៤ អាករសម្រាប់បំភ្លឺសាធារណៈ................................................................................ ២៥
៤.៣.៥ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល.......................................................................... ២៦
៤.៣.៦ ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ............................................................ ២៦
៤.៣.៧ វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ................................................................ ២៧
៤.៣.៨ ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ ........................................... ២៨
៤.៣.៩ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ................................................................. ២៩

៤.៣.១០ ការរៀបចំប្រព័ន្ធសារពើពន្ធ ........ ៣០

ជំពូកទី៥÷ ការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ ........ ៣២

៥.១ ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រង ........ ៣២

៥.២ វិធានការតាមវិស័យ និងប្រភពចំណូលសំខាន់ៗ ........ ៣៣

ក. វិស័យអាកាសចរណ៍ស៊ីវិល ........ ៣៣

ខ. វិស័យទេសចរណ៍ ........ ៣៤

គ. ចំណូលពីអាករស្ថានទូត ........ ៣៥

ឃ. វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ៣៥

ង. ដីសម្បទានសេដ្ឋកិច្ច ........ ៣៦

ច. ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍ ........ ៣៧

ឆ. សហគ្រាសសាធារណៈ ........ ៣៧

ជ. គ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ៣៨

ឈ. វិស័យរ៉ែ និងថាមពល ........ ៣៨

ញ. ចំណូលពីសកម្មភាពល្បែង ........ ៣៩

ដ. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ ........ ៣៩

ឋ. ចំណូលពីការចាត់ចែងវត្ថុតាងរឹបអូសពីបទល្មើស ........ ៤០

ជំពូកទី៦÷ ការត្រួតពិនិត្យ និងវាយតម្លៃ ........ ៤១

ជំពូកទី៧÷ សេចក្តីសន្និដ្ឋាន ........ ៤៣

ឧបសម្ព័ន្ធ ១. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ៤៤

ឧបសម្ព័ន្ធ ២. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ........ ៥៤

ឧបសម្ព័ន្ធ ៣. សូចនាករវិធានការគោលនយោបាយសារពើពន្ធ ........ ៦០

ឧបសម្ព័ន្ធ ៤. សូចនាករសមិទ្ធកម្មគន្លឹះរបស់រដ្ឋបាលចំណូលមិនមែនសារពើពន្ធ ........ ៦៧

## ជំពូកទី១៖ សេចក្តីផ្តើម

១. ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ និងនៅក្នុងរាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ឆ្នាំ ២០១៣-២០១៨ កម្ពុជារក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ជាមធ្យមក្នុងមួយឆ្នាំ និងបានក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ ២០១៥ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏សម្រេចបាននូវការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយផ្លែផ្កា និងជោគជ័យខ្ពស់ដោយចំណូលចរន្តបានកើនឡើងជាមធ្យម ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ដែលខ្ពស់ជាងពីរដងធៀបនឹងគោលដៅ ០,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ពោលគឺចំណូលចរន្តបានកើនឡើងពី ១៥,១% នៃ ផ.ស.ស. នៅឆ្នាំ ២០១៣ ដល់ ២២,០% នៃ ផ.ស.ស. នៅឆ្នាំ ២០១៨[1] ។ ការកើនឡើងនៃចំណូលចរន្តនេះបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលបង្កើនចំណាយសាធារណៈសម្រាប់បន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពសេវាសាធារណៈឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ ព្រមទាំងបង្កើនការវិនិយោគលើវិស័យអាទិភាពសំខាន់ៗ ដូចជាវិស័យអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ ។ល។

២. នៅក្នុងនីតិកាលទី ៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងពោរពេញដោយបញ្ញាញាណរបស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ដើម្បីពង្រឹងនូវបុរេលក្ខខណ្ឌចាំបាច់នានា និងបរិស្ថានគាំទ្រការកែទម្រង់ស៊ីជម្រៅរបស់កម្ពុជា សម្រាប់បន្តបេសកកម្មរបស់ខ្លួន និងក្នុងទិសដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសសម្រេចចក្ខុវិស័យប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ ច្បាស់ណាស់ថា ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ កម្ពុជាត្រូវតែបន្តធានាសម្រេចឱ្យបានជាប់ជានិច្ចនូវកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់, រឹងមាំប្រកបដោយបរិយាប័ន្ន និងមានភាពធន់នឹងវិបត្តិ ។

៣. ក្នុងន័យដើម្បីសម្រេចឱ្យបាននូវគោលដៅ និងបំណងប្រាថ្នាដ៏ពិសិដ្ឋខាងលើជូនដល់ប្រជាជាតិកម្ពុជា រាជ-រដ្ឋាភិបាលបានដាក់ចេញនូវវិធានការមុតស្រួចជាកញ្ចប់ កាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៩ ស្របតាមបាវចនា ២ គឺ "**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅ ដោយឈរលើស្មារតីឯករាជ្យ**" និងអភិក្រម ៥ យ៉ាង គឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" ដើម្បីដោះស្រាយចំៗនូវបញ្ហាជារចនាសម្ព័ន្ធធំៗ ក៏ដូចជាបញ្ហាប្រឈមជាក់ស្តែងសំខាន់ផ្សេងៗទៀត ដែលបណ្តាវិនិយោគិន និងធុរជន បាននិងកំពុងតែជួបប្រទះនៅក្នុងកិច្ចការអាជីវកម្មរបស់ខ្លួននៅកម្ពុជា ក្នុងន័យបន្តពង្រឹង និងពង្រីកភាពប្រកួតប្រជែង ក៏ដូចជាជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ នៅក្នុងល្បឿន និងជវភាពមួយកាន់តែខ្ពស់ថែមទៀត, បង្កើតការងារប្រកបដោយគុណភាព, បង្កើនចំណូល និងលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនទូទាំងប្រទេសផងដែរ ។

---

[1] ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ។

៤. ពិតណាស់ គោលដៅប្រកបដោយមហិច្ឆតា និងពិសិដ្ឋខាងលើពិតជាត្រូវការនូវចំណូលថវិកាជាតិច្រើន ។ ជាមួយនឹងលទ្ធផលដ៏ល្អប្រសើរក្នុងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលនាពេលកន្លង រាជរដ្ឋាភិបាលកម្ពុជាបន្តរៀបចំ និងដាក់ឱ្យអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ច, រក្សាបាននូវចីរភាពចំណូល, ធានានូវយុត្តិធម៌ក្នុងការប្រមូលចំណូល និងធានានូវសមធម៌រវាងអ្នកជាប់ពន្ធ ព្រមទាំងជាមូលដ្ឋានសម្រាប់បន្តធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល សំដៅឆ្លើយតបទៅនឹងតម្រូវការចំណាយរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ។

៥. **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** កំណត់ចក្ខុវិស័យ, គោលបំណង, គោលដៅ និងអភិក្រមច្បាស់លាស់ ព្រមទាំងដាក់ចេញនូវវិធានការគន្លឹះសម្រាប់ការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលរដ្ឋ ដែលគ្របដណ្តប់ទាំងរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ជាពិសេសកំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដាន និងត្រួតពិនិត្យ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះនឹងបន្តដោះស្រាយបញ្ហាប្រឈមចម្បងៗ ដូចជា÷ (១)ការកែសម្រួលគោលនយោបាយសារពើពន្ធមួយចំនួនកន្លងមកផ្តោតលើការបង្កើនចំណូលជាចម្បង ដោយមិនទាន់បានឆ្លើយតបពេញលេញលើទិដ្ឋភាពសេដ្ឋកិច្ច, បរិស្ថាន និងសង្គម ជាពិសេសការទាក់ទាញវិនិយោគ, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មសេដ្ឋកិច្ច, (២)ការរៀបចំគោលនយោបាយសារពើពន្ធមួយចំនួន មិនទាន់មានសង្គតិភាពទៅនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ, (៣)ការពង្រឹងរដ្ឋបាលប្រមូលចំណូល ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ នៅមិនទាន់អាចឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងកំណើនបន្ទុកការងារ និងមិនទាន់អាចសម្រាលបន្ទុកក្នុងការបង់ពន្ធជាអតិបរមា និង (៤)ការអនុវត្តការងារប្រមូលចំណូល ដោយឈរលើគោលការណ៍សមធម៌ និងយុត្តិធម៌ នៅមានកម្រិត ។

៦. រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា ការអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ប្រកបដោយជោគជ័យនឹងធ្វើឱ្យកម្ពុជាបន្តដំណើរទៅមុខ ដោយភាពស្វាហាប់ និងភាពជឿជាក់ខ្ពស់ ក្នុងការកំណត់ជោគវាសនារបស់ខ្លួនទៅថ្ងៃអនាគត ឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យ និងបំណងប្រាថ្នាប្រកបដោយមហិច្ឆតារបស់ខ្លួន ពោលគឺ "**ក្តាប់យកមកវិញនូវមោទនភាពជាតិ និងកសាងជាតិមួយដ៏រស់រវើក**" ដើម្បីឆ្ពោះទៅរកអនាគតដ៏រុងរឿង, ភ្លឺស្វាង និងត្រចះត្រចង់ តាមរយៈ "**ការកសាងជាជំហានៗ នូវសង្គមកម្ពុជាមួយ ដែលមានសុខសន្តិភាព, ស្ថិរភាព, សណ្តាប់ធ្នាប់សង្គម, មានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ, នីតិរដ្ឋ ព្រមទាំងសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស, មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌, មានកោសិកាផ្សារភ្ជាប់គ្នា, មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះ ហើយមានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយភាពសុខដុមរមនា, ទាំងក្នុងសង្គមជាតិ និងទាំងសង្គមគ្រួសារ**" ។

## ជំពូកទី២÷ ការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

៧. យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ បានកំណត់គោលបំណងចំនួនបីគឺ÷ (១) លើកកម្ពស់វប្បធម៌បង់ពន្ធ, (២)បង្កើនប្រសិទ្ធភាពរដ្ឋបាលចំណូល និង (៣)គៀរគរចំណូលឱ្យអស់លទ្ធភាព ។ ជាលទ្ធផល÷ (១)វប្បធម៌បង់ពន្ធមានភាពល្អប្រសើរជាងមុន ដោយមានការកើនឡើងជាបន្តបន្ទាប់នៃអត្រាការបង់ពន្ធទាន់ពេលវេលា ដោយសារការបង្កើនភាពងាយស្រួលក្នុងការបង់ពន្ធ និងការពង្រឹងគុណភាពសេវានិងការអប់រំដល់អ្នកជាប់ពន្ធ ព្រមទាំងការកែសម្រួលគោលនយោបាយសារពើពន្ធមួយចំនួន ដែលបានជួយលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងចូលរួមពង្រឹងសមធម៌ក្នុងការបង់ពន្ធ, (២)ប្រសិទ្ធភាពនៃរដ្ឋបាលចំណូលក៏ត្រូវបានលើកកម្ពស់ដោយសារការអនុវត្តវិធានការកែទម្រង់រដ្ឋបាលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធភាគច្រើនត្រូវបានបញ្ចប់ និង (៣)ការគៀរគរចំណូលទទួលបានជោគជ័យខ្ពស់ហួសពីការគ្រោងទុក ដែលចំណូលចរន្តទទួលបានកំណើនជាមធ្យម ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ដែលខ្ពស់ជាងពីរដងធៀបនឹងគោលដៅ 0,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ពោលគឺបានកើនឡើងពី ១៥,១% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៣ ដល់ ២២,0% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៨ ។

### ២.១ វឌ្ឍនភាពនៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ

៨. អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) បានអនុវត្តវិធានការកែទម្រង់ ដោយបានបញ្ចប់វិធានការចំនួន ៧៤ នៃវិធានការទាំង ៨៦ និងកំពុងបន្តអនុវត្តវិធានការសេសសល់ចំនួន ១២ ទៀត[2] ។ សមិទ្ធផលចម្បងៗក្នុងមុខងារប្រតិបត្តិការស្នូល រួមមាន÷ (១)បានដាក់ឱ្យអនុវត្តការសុំចុះបញ្ជីពន្ធដារតាមប្រព័ន្ធអេឡិចត្រូនិក និងដំណើរការប្រព័ន្ធទិន្នន័យប្រមូលផ្តុំ (centralized database), (២)បានចុះអង្កេតសហគ្រាសចំនួន ៥៨.០៨៥ នៅក្នុង ១១ រាជធានី-ខេត្ត, (៣)បានពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងអប់រំ, ការដាក់បញ្ចូរពិគ្រោះយោបល់, ការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (call centre) និងការដាក់ឱ្យមានកម្រងសំណួរ-ចម្លើយ (FAQs), (៤)បានដាក់ឱ្យប្រើប្រាស់វិក្កយបត្រតែមួយ (single invoice), និងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (e-payment) និងបានបង្កើតជម្រើសបន្ថែមក្នុងការបង់ពន្ធតាមប្រព័ន្ធធនាគារ, (៥)បានរៀបចំសៀវភៅណែនាំស្តីពីការកំណត់ហានិភ័យអ្នកជាប់ពន្ធ និងប្រកាសស្តីពីវិធាននិងនីតិវិធីសម្រាប់បែងចែកចំណូល និងចំណាយក្នុងចំណោមបុគ្គលទាក់ទិន ព្រមទាំងបានកសាងសមត្ថភាពសវនករពន្ធដារ, អនុវត្តសេចក្តីណែនាំស្តីពីនីតិវិធីនៃការធ្វើសវនកម្មលើវិស័យ និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសវនកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង(៦)បានអនុវត្តយន្តការទូទាត់បំណុលជាដំណាក់កាល, កែសម្រួលវិធាន និងនីតិវិធីដោះស្រាយបណ្តឹងតវ៉ាពន្ធដារ និងបង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ។ លើសពីនេះ សមិទ្ធផលធំៗក្នុងមុខងារគាំទ្ររួមមាន÷ (១)បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ២០១៤-២០១៨, (២)បានបញ្ចប់ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង (៣)

---

[2] យោងតាមរបាយការណ៍លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម រយៈពេលប្រាំឆ្នាំ របស់អគ្គនាយកដ្ឋានពន្ធដារ ។

បានបង្កើតមុខងារស៊ើបអង្កេតបទល្មើសពន្ធដារ និងបង្កើតជាថ្មីនូវមុខងារសវនកម្មផ្ទៃក្នុង ។ បញ្ហាគន្លឹះមួយចំនួនដែលអគ្គនាយកដ្ឋានពន្ធដារត្រូវបន្តដោះស្រាយ រួមមាន÷

➢ **មុខងារប្រតិបត្តិការស្នូល**

- មូលដ្ឋានទិន្នន័យអ្នកជាប់ពន្ធ (taxpayer database) មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពពេញលេញ,
- ការធ្វើសវនកម្មត្រួតគ្នា និងការបកស្រាយលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់មានសង្គតិភាពទាំងស្រុង,
- កង្វះយន្តការវាយតម្លៃហានិភ័យអ្នកជាប់ពន្ធដោយស្វ័យប្រវត្តិ (automatic risk assessment),
- កង្វះផែនការយុទ្ធសាស្ត្រស្តីពីការផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ នៅកម្រិតថ្នាក់កណ្តាល និងសាខាខេត្ត-ខណ្ឌ ។

➢ **មុខងារគាំទ្រ**

- ទំនុកចិត្តរបស់មន្ត្រីលើវប្បធម៌អនុលោមភាពរបស់វិស័យឯកជននៅមានកម្រិត ដែលអាចប៉ះពាល់ដល់ទំនាក់ទំនងរវាងមន្ត្រី និងអ្នកជាប់ពន្ធ និងប្រសិទ្ធភាពនៃការផ្តល់សេវា,
- កង្វះមន្ត្រីជំនាញវិភាគតាមវិស័យសម្រាប់ធ្វើសវនកម្មលើវិស័យសំខាន់ៗ,
- មិនទាន់ធ្វើស្វ័យប្រវត្តិកម្មពេញលេញ និងតភ្ជាប់មុខងារស្នូលទាំងអស់ដូចជា ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-filing), ការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) និង សេវាអ្នកជាប់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក ។ល។,
- ការប្រមូល និងការចែករំលែកព័ត៌មាន និងទិន្នន័យទាំងផ្ទៃក្នុងអង្គភាព និងរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានភាពយឺតយ៉ាវ,
- កង្វះសូចនាករសមិទ្ធកម្មគន្លឹះដើម្បីត្រួតពិនិត្យ និងវាយតម្លៃឱ្យទាន់ពេលវេលា ។

## ២.២ វឌ្ឍនភាពនៃការកែទម្រង់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

៩. ជារួម អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (អ.គ.រ.) សម្រេចបានប្រមាណ ៨៦% នៃសកម្មភាពទាំងអស់ដែលមាននៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ មានជាអាទិ៍÷ ការធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយ និងលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់កម្រិតថ្នាក់ហានិភ័យ, ការរៀបចំរួចរាល់និងការអនុវត្តផែនការសកម្មភាពបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធ, ការកំណត់ទិន្នន័យអប្បបរមានៅលើវិក្កយបត្រពាណិជ្ជកម្ម, ការពង្រឹងការងារបច្ចេកទេសគយ, ការពង្រឹងអភិបាលកិច្ចនិងអនុលោមភាពផ្ទៃកងឯកជន, ការជំរុញកិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀតតាមរយៈការធ្វើសាមញ្ញកម្មនីតិវិធីគយ, ការអនុវត្តយន្តការភាពជាដៃគូរវាងគយ និងវិស័យឯកជនបានយ៉ាងខ្ជាប់ខ្ជួន និងការពង្រឹងសមត្ថភាពស្ថាប័ន ជាដើម ។

១០. ដោយឡែក មានសកម្មភាពប្រមាណតែ ១៤% ប៉ុណ្ណោះដែលមិនត្រូវបានសម្រេចពេញលេញ និងមានវឌ្ឍនភាពតិចតួចរួមមាន÷ ការងារមួយចំនួនពាក់ព័ន្ធនឹងការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្មអាស៊ីគូដា និងប្រព័ន្ធអេឡិចត្រូនិកគយផ្សេងៗទៀតដូចជាប្រព័ន្ធគ្រប់គ្រងហានិភ័យគយ (CRMDS) និងប្រព័ន្ធទ្រទ្រង់ការកំណត់តម្លៃគិតពន្ធគយ

(CVSS), ការងារពាក់ព័ន្ធនឹងស្ថាប័នផ្សេងៗ ដែលពុំស្ថិតក្រោមភាពអាចគ្រប់គ្រងបានដោយរដ្ឋបាលគយក្រោមក្របខ័ណ្ឌគម្រោងប្រព័ន្ធបញ្ជរតែមួយជាតិ, ការកែសម្រួលអនុក្រឹត្យ ២០៩ ស្តីពីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់, ការរៀបចំផែនការនិងកម្មវិធីអនុវត្តសវនកម្មផ្ទៃក្នុង អ.គ.រ., ការពិនិត្យលទ្ធភាពនៃការរៀបចំយន្តការប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (authorized economic operator) និងការខកខានក្នុងការសិក្សារយៈពេលបញ្ចេញទំនិញពីគយ (time release study) លើកទី ២ ជាដើម ។

១១. ទន្ទឹមនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានបញ្ហាប្រឈមចម្បងៗមួយចំនួន ដែលត្រូវបន្តគិតគូរនិងដោះស្រាយ ដូចខាងក្រោម÷

- ប្រភពចំណូលមានមូលដ្ឋានតូចចង្អៀត (ចំណូលលើសពី ៦០% បានមកពីតែក្រុមទំនិញយានយន្ត និងផលិតផលតេលសិលា),
- ការប្រើប្រាស់ថាមពលពីប្រភពមិនមែនប្រេង និងផលិតកម្មក្នុងស្រុកកើនឡើងជាបន្តបន្ទាប់,
- ការអនុវត្តកាន់តែទូលំទូលាយនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA),
- វប្បធម៌បង់ពន្ធនៅមានកម្រិត ធ្វើឱ្យអំពើរត់ពន្ធ និងបន្លំពន្ធនៅតែមាន,
- ប្រសិទ្ធភាពនៃការធ្វើសវនកម្មក្រោយបញ្ចេញទំនិញ (post clearance audit) នៅមានកម្រិត ជាក់ស្តែងការពង្រីកអង្គភាពសវនកម្មក្រោយការបញ្ចេញទំនិញនៅមិនទាន់សម្រេចតាមគោលដៅ (យ៉ាងតិច ៦ ក្រុម),
- កង្វះប្រសិទ្ធភាពនៃកិច្ចសហការ និងការចែករំលែកព័ត៌មានជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន ។

## ២.៣ វឌ្ឍនភាពនៃការកែទម្រង់រដ្ឋបាលប្រមូលចំណូលមិនមែនសារពើពន្ធ

១២. ការវាយតម្លៃរដ្ឋបាលចំណូលមិនមែនសារពើពន្ធនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ផ្តោតលើ ២ ទិដ្ឋភាពសំខាន់ៗ គឺ÷ (១) ប្រភពចំណូលមិនមែនសារពើពន្ធធំៗ និង (២) ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលគ្របដណ្តប់លើវិធានការសរុបចំនួន ៩៣[3] រួមមានវិធានការទូទៅ, វិធានការគោល និងវិធានការអន្តរក្រសួង[4] ។

១៣. ចំពោះទិដ្ឋភាពចំណូលមិនមែនសារពើពន្ធមានចំណែកប្រមាណ ១៤% នៃចំណូលចរន្តសរុប[5] ដែលមានប្រភពចំនួន ៥ ធំៗ គឺ÷

---

[3] វិធានការទាំងអស់ចែកចេញជាបីប្រភេទ÷ (១) វិធានការទូទៅគឺជាវិធានការអនុវត្តដោយក្រសួងប្រមូលចំណូលពាក់ព័ន្ធទាំងអស់, (២) វិធានការគោល គឺជាវិធានការក្រសួងសាមីអនុវត្តផ្ទាល់, និង (៣) វិធានការអន្តរក្រសួង គឺជាវិធានការអនុវត្តដោយក្រសួងប្រមូលចំណូលពីរ ឬច្រើនរួមគ្នា។

[4] យោងរបាយការណ៍ពីអគ្គនាយកដ្ឋានពាក់ព័ន្ធនៃ កសហវ និងក្រសួង-ស្ថាប័នត្រឹមខែឧសភា ឆ្នាំ ២០១៨ ។

[5] ផលធៀបចំណូលមិនមែនសារពើពន្ធសរុបនឹង ផ.ស.ស. មិនមានការកើនឡើងច្រើននោះទេគឺពី ២,៣៥% នៅឆ្នាំ ២០១៣ ដល់ ២,៧៨% នៅឆ្នាំ ២០១៧ ដោយក្នុងនោះចំណូលសារពើពន្ធផ្សេងៗ ប្រមាណ ០,៤% នៃ ផ.ស.ស. ត្រូវបានកត់បញ្ចូលក្នុងចំណូលមិនមែនសារពើពន្ធចាប់ពីឆ្នាំ ២០១៦ មក។

**(១) ចំណូលពីសេវាសាធារណៈ** មានចំណែកជាមធ្យមប្រមាណ ៦៦% នៃចំណូលមិនមែនសារពើពន្ធសរុប ។ ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលបានពិនិត្យ និងកែសម្រួលប្រកាសរួមស្តីពីសេវាសាធារណៈចំនួន ៤០ និងប្រកាសរួមស្តីពីការបែងចែកប្រាក់រង្វាន់ចំនួន ២៦ ដើម្បីឆ្លើយតបទៅនឹងកំណើននៃសេវាសាធារណៈ, ការកែប្រែកម្រៃសេវា និងការកែសម្រួលអត្រាប្រាក់រង្វាន់[6] ។ ជាលទ្ធផល ចំណូលពីការផ្តល់សេវាសាធារណៈមានការកើនឡើង, ការផ្តល់សេវាត្រូវបានវាយតម្លៃថាមានភាពប្រសើរឡើងជាងមុន និងការបែងចែកប្រាក់រង្វាន់កាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ។

**(២) ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** មានចំណែកជាមធ្យមប្រមាណ ៩% នៃចំណូលមិនមែនសារពើពន្ធសរុប ។ ការពិនិត្យឡើងវិញនូវកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋមានវឌ្ឍនភាពតិចតួច ដោយសារស្ថាប័នមានសមត្ថកិច្ចត្រូវពិនិត្យទិដ្ឋភាពច្បាប់ និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាភាគីឯកជនដើម្បីពិនិត្យលទ្ធភាពដំឡើងថ្លៃឈ្នួល និងកំណត់លក្ខខណ្ឌដែលផ្តល់ផលប្រយោជន៍សមស្របជូនភាគីរាជរដ្ឋាភិបាល ។

**(៣) ចំណូលពីសកម្មភាពល្បែង** មានចំណែកជាមធ្យមប្រមាណ ៧% នៃចំណូលមិនមែនសារពើពន្ធសរុប ។ ចំនួនកាស៊ីណូដែលចុះបញ្ជីជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកើនឡើងពី ៥៧ កាស៊ីណូ នៅឆ្នាំ ២០១៤ ដល់ ១០៦ កាស៊ីណូ នៅឆ្នាំ ២០១៨ ។ ដើម្បីពង្រឹងការគ្រប់គ្រងចំណូលពីសកម្មភាពល្បែង សេចក្តីព្រាងច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម ត្រូវបានរៀបចំ និងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត ។

**(៤) ចំណូលពីសហគ្រាសសាធារណៈ** មានចំណែកជាមធ្យមប្រមាណ ១% នៃចំណូលមិនមែនសារពើពន្ធសរុប ។ ជាវឌ្ឍនភាព សហគ្រាសសាធារណៈចំនួន ១០ នៃសហគ្រាសសាធារណៈចំនួន ១៤ ត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ ដែលឆ្លុះបញ្ចាំងនូវតម្លាភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងតាមស្តង់ដារជាតិ និងអន្តរជាតិជាធរមាន ។ ជាលទ្ធផល ភាគលាភពីសហគ្រាសសាធារណៈត្រូវបានបង់ចូលថវិការដ្ឋទាន់ពេលវេលា និងកើនពី ៥.៨៣០ លានរៀល ក្នុងឆ្នាំ ២០១៣ ដល់ ១០៦.០៩៨ លានរៀល ក្នុងឆ្នាំ ២០១៨ ។

**(៥) ចំណូលផ្សេងៗទៀត** ដែលមានប្រភពមកពីការផ្ទេរ, អំណោយ, ផលហិរញ្ញវត្ថុ ។ល។ មានចំណែកជាមធ្យមប្រមាណ ១៧% នៃចំណូលមិនមែនសារពើពន្ធសរុប ។ ចំណូលទាំងនេះមានលក្ខណៈចម្រុះ[7] និងមិនស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពជាក់លាក់ណាមួយ ។

១៤. ចំពោះទិដ្ឋភាពប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ២ ធំៗ ត្រូវបាន និងកំពុងរៀបចំ[8] គឺ÷

---

[6] ក្នុងនោះអត្រាប្រាក់រង្វាន់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក៏ត្រូវបានកែសម្រួល ។

[7] ព្រមទាំងមានចរិតជាចំណូលសំណល់ (residual) ។

[8] ខណៈប្រព័ន្ធទាំង ២ ស្ថិតក្នុងដំណាក់កាលរៀបចំ, ក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នបានប្រើប្រាស់កម្មវិធីតេឡេក្រាម ដើម្បីគាំទ្រដល់វិធានការដែលបានដាក់ចេញ ក្នុងន័យសម្រួលដល់ការកត់ត្រា និងការផ្លាស់ប្តូរព័ត៌មានឱ្យបានឆាប់រហ័ស ។

**(១) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)÷** ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់គ្រប់ក្រសួង-ស្ថាប័នប្រមូលចំណូលទាំង ២៣ (គិតត្រឹមខែធ្នូ ឆ្នាំ ២០១៨) ដែលមានមុខងារគ្រប់គ្រងចំណូលពីសេវាសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការកត់ត្រាជាប្រព័ន្ធដូចជា ការធ្វើចំណាត់ថ្នាក់ចំណូល, ការរៀបចំឯកសារយោង និងការចងក្រងរបាយការណ៍ចំណូលតាមប្រព័ន្ធ ។ល។

**(២) ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ÷** មានគោលដៅពង្រឹងការគ្រប់គ្រង និងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំឱ្យមានសង្គតិភាព និងទាន់ពេលវេលា ។ ប្រព័ន្ធនេះកំពុងស្ថិតក្នុងដំណាក់កាលសាកល្បងកម្រិតបច្ចេកទេស និងដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០១៩ ។

១៥. ជារួម វិធានការសរុបទាំង ៩៣ របស់ផ្នែកចំណូលមិនមែនសារពើពន្ធត្រូវបានពិនិត្យឃើញថា ភាគច្រើនបានបញ្ចប់ ខណៈវិធានការមួយចំនួនទៀតកំពុងបន្តអនុវត្ត ដែលធ្វើឱ្យការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធកាន់តែមានភាពរឹងមាំ និងពេញលេញជាងមុន ។ សមិទ្ធផលធំៗរួមមាន÷ (១)ការបង់ និងការកត់ត្រាចំណូលចូលក្នុងគណនីទោលរបស់រតនាគារជាតិមានវឌ្ឍនភាពល្អប្រសើរ និងការប្រើប្រាស់ប្រព័ន្ធធនាគារកាន់តែទូលំទូលាយ និង (២)ការបង្កើតគ្រឹះស្ថានអង្គរបានពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីការលក់បណ្ណចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ ។

១៦. បញ្ហាប្រឈម និងការងារសេសសល់ធំៗ ដែលមិនទាន់សម្រេចបានពេញលេញ រួមមាន÷

- ការយល់ដឹងពីប្រព័ន្ធ NRMIS និងកិច្ចសហការរវាងក្រសួង-ស្ថាប័នមួយចំនួននៅមានកម្រិត,
- ការពិនិត្យ និងកែសម្រួលជាយថាហេតុនូវកិច្ចព្រមព្រៀង, កិច្ចសន្យា និងអាជ្ញាបណ្ណមានវឌ្ឍនភាពតិចតួច,
- ការពន្យារការអនុវត្តតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលរហូតដល់ដើមឆ្នាំ ២០២០ ដោយសារកង្វះធនធានមនុស្សនៅតាមគ្រឹះស្ថានមួយចំនួន និងនីតិវិធីមិនទាន់មានភាពរលូន,
- ច្បាប់ និងបទប្បញ្ញត្តិដែលគ្រោងនឹងដាក់ចេញ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមិនទាន់អនុម័ត ។

## ជំពូកទី៣៖ ចក្ខុវិស័យ, គោលបំណង, គោលដៅ និងអភិក្រម នៃយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

### ៣.១ ចក្ខុវិស័យ

១៧. ដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ ២០៣០ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងដើម្បីធានាបានការអភិវឌ្ឍប្រកបដោយជោគជ័យ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា បានដាក់ចេញនូវ **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដែលជាមូលដ្ឋានសម្រាប់ការរៀបចំផែនការ និងគោលនយោបាយជាក់លាក់តាមវិស័យ ទាំងសង្គម និងសេដ្ឋកិច្ច ឱ្យមានភាពស៊ីចង្វាក់ និងប្រទាក់ក្រឡា ។ ឈរលើមូលដ្ឋាននេះ និងសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជាដាក់ឱ្យអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ដើម្បីឆ្លើយតបទៅនឹងការវិវត្តឥតឈប់ឈរនៃសង្គម-សេដ្ឋកិច្ចជាតិ និងតំបន់ ព្រមទាំងជវភាពនៃពាណិជ្ជកម្ម, ធុរកិច្ច, ឥរិយាបថអ្នកប្រើប្រាស់ និងបរិស្ថាន ។

១៨. **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** មាន **ចក្ខុវិស័យ** ប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើបដែលអាចឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវត្តនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ យុទ្ធសាស្ត្រកៀរគរចំណូល នឹងក្លាយជាឧបករណ៍គោលនយោបាយមួយយ៉ាងសំខាន់ក្នុងការកៀរគរចំណូលរដ្ឋប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ តាមរយៈការដាក់ចេញនូវគោលបំណង និងគោលដៅ ព្រមទាំងវិធានការមុតស្រួចនានាសម្រាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ។

### ៣.២ គោលបំណង និងគោលដៅ

១៩. យុទ្ធសាស្ត្រកៀរគរចំណូលនេះមាន **គោលបំណង** ធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់, កែលម្អបរិយាកាសវិនិយោគ និងតម្រង់ទិសការវិនិយោគ, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ។ ស្របនឹងគោលបំណងខាងលើ យុទ្ធសាស្ត្រនេះមាន **គោលដៅ**៖ (១)ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និង (២)បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។

### ៣.៣ អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ

២០. យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួនបួនគឺ៖ (១)ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២)រក្សាបាននូវចីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល (optimal level), (៣)ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង (៤) ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប, បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន ។

២១. ឯកសារយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ផ្តោតលើការកំណត់វិធានការដែលមានចរិតជាយុទ្ធសាស្ត្រ និងកែទម្រង់ និងផ្តោតលើការកំណត់សូចនាករសមិទ្ធកម្មគន្លឹះសំខាន់ៗ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី៤÷ ទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ

២២. ទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ ផ្តោតលើការធ្វើវិចារណកម្មគោលនយោបាយ និងទំនើប-ភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ ។ ការធ្វើវិចារណកម្មគោលនយោបាយសារពើពន្ធ សំដៅដល់ការពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធបច្ចុប្បន្ន ដោយឈរលើគោលការណ៍សាមញ្ញភាព, តម្លាភាព, ភាពប្រាកដប្រជា, សមធម៌, យុត្តិធម៌ និងប្រសិទ្ធភាព ។ ការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាលសារពើពន្ធ សំដៅកសាង និងពង្រឹងសមត្ថភាពរដ្ឋបាលសារពើពន្ធ ក្នុងការឆ្លើយតបឱ្យទាន់ពេលវេលាទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច, បច្ចេកវិទ្យា, បរិយាកាសធុរកិច្ច និងឥរិយាបថអ្នកជាប់ពន្ធ ខណៈធានាសម្រេចឱ្យបានគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ ។

### ៤.១ ទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ

២៣. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ បានបង្កើតនូវសមិទ្ធផលជាច្រើនក្នុងកម្មវិធីកែទម្រង់រដ្ឋបាលប្រមូលចំណូល និងបានកសាងមូលដ្ឋានដ៏រឹងមាំសម្រាប់ការងារកែទម្រង់បន្តក្នុងអាណត្តិថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ផ្អែកលើបទពិសោធន៍នៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ការពង្រឹងមុខងារសំខាន់បីគឺ÷ (១)គ្រប់ខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច, (២)មុខងារប្រតិបត្តិការស្នូល និង (៣)មុខងារគាំទ្រ បានធ្វើឱ្យរដ្ឋបាលពន្ធដារទាំងមូលមានភាពល្អប្រសើរឡើង ទាំងសមត្ថភាព និងការផ្តល់សេវា ។ សម្រាប់ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ មុខងារទាំងបីខាងលើនៅតែមានសារៈសំខាន់ និងចាំបាច់ ។ ក្នុងន័យនេះ ការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ នឹងផ្តោតលើការធ្វើទំនើបភាវូបនីយកម្មមុខងារទាំងបីខាងលើដដែល ។ លទ្ធផលរំពឹងទុកនៃការធ្វើទំនើបភាវូបនីយកម្ម គឺភាពប្រសើរឡើងនៃ (១)ប្រសិទ្ធភាពប្រតិបត្តិការ, (២)អនុលោមភាពស្ម័គ្រចិត្ត, (៣)គុណភាពសេវា និង (៤)យន្តការត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើសូចនាករសមិទ្ធកម្មគន្លឹះ ។

**គំនូសបំព្រួញនៃការធ្វើទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ**



## គ. ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច

២៤. ផ្អែកតាមឧត្តមានុវត្តន៍អន្តរជាតិ ការធ្វើទំនើបភាវូបនីយកម្មក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ចត្រូវមានលក្ខណៈពិសេសពីរគឺ÷ (១)ការគ្រប់គ្រងលក្ខណៈយុទ្ធសាស្ត្រ តាមរយៈការបែងចែកការទទួលខុសត្រូវ និងសិទ្ធិអំណាចឱ្យដាច់ និងជាក់លាក់÷ ស្នាក់ការកណ្តាល ផ្តោតលើការគ្រប់គ្រងហានិភ័យចម្បងៗ លើចំណូល និងត្រួតពិនិត្យវាយតម្លៃសមិទ្ធកម្មការងារ (output and outcome) រីឯអង្គភាពអនុវត្តថ្នាក់មូលដ្ឋាន (សាខាខេត្ត-ខណ្ឌ) ផ្តោតលើការងារប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានាថារដ្ឋបាលសារពើពន្ធអាចឆ្លើយតប និងសម្របខ្លួនទាន់ពេលវេលាទៅនឹងរបត់សេដ្ឋកិច្ច-សង្គម និង (២)យន្តការប្រតិតុល្យការ (check and balance) ដោយធានាឯករាជ្យភាពនៃសវនកម្មផ្ទៃក្នុង ដើម្បីធានាសុចរិតភាព, វិជ្ជាជីវៈ និងទំនុកចិត្តនៃរដ្ឋបាលសារពើពន្ធ ។ ដូចនេះ សម្រាប់កម្ពុជា ការធ្វើទំនើបភាវូបនីយកម្មក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ចនឹងធានាសម្រេចឱ្យបានពីរផ្នែកគឺ÷ (១)ក្របខ័ណ្ឌស្ថាប័នដែលមានសមត្ថភាពសម្របខ្លួនទៅតាមរបត់សេដ្ឋកិច្ច-សង្គម (learning organization) ដោយមានការបែងចែកការទទួលខុសត្រូវ និងសិទ្ធិអំណាចច្បាស់លាស់រវាងស្នាក់ការកណ្តាល និងថ្នាក់មូលដ្ឋាន និង (២)ក្របខ័ណ្ឌអភិបាលកិច្ច ដែលសវនកម្មផ្ទៃក្នុងមានឯករាជ្យភាពខ្ពស់ក្នុងការធានាសុចរិតភាព វិជ្ជាជីវៈ និងទំនុកចិត្តនៃរដ្ឋបាលសារពើពន្ធ ។ ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក អគ្គនាយកដ្ឋានពន្ធដារបានបញ្ចប់ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រ, ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ, លើកកម្ពស់សេវាអ្នកជាប់ពន្ធ និងបង្កើនកម្រិតអនុលោមភាព ។ ដោយឡែក ដើម្បីសម្រេចបាននូវគោលបំណងនៃការកែទម្រង់ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារត្រូវបន្តដោះស្រាយបញ្ហាមួយចំនួន ដូចខាងក្រោម ÷

- ការគ្រប់គ្រងកម្មវិធីកែទម្រង់ភាគច្រើនផ្តោតលើសកម្មភាព និងលទ្ធផល (output) ដោយមិនបានផ្តោតគ្រប់ជ្រុងជ្រោយលើសមិទ្ធកម្ម (outcome),
- សិទ្ធិសម្រេច និងសមត្ថភាពក្នុងការគ្រប់គ្រងប្រតិបត្តិការថ្នាក់មូលដ្ឋាននៅមានកម្រិត ដែលធ្វើឱ្យភាពជាម្ចាស់ និងការទទួលខុសត្រូវលើប្រតិបត្តិការនៅមានភាពទន់ខ្សោយ,
- ការគ្រប់គ្រងហានិភ័យលើប្រភពចំណូលនៅមានកម្រិត ដោយពុំទាន់អាចឆ្លើយតបទៅតាមរបត់សេដ្ឋកិច្ច, ពាណិជ្ជកម្ម និងបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព,
- ការប្រមូល និងការចែករំលែកព័ត៌មាន និងទិន្នន័យទាំងផ្ទៃក្នុងអង្គភាព និងរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានភាពយឺតយ៉ាវ និងមិនទាន់សភាពការណ៍ ដែលប៉ះពាល់ដល់ប្រសិទ្ធភាពការងារប្រចាំថ្ងៃ,
- សវនកម្មផ្ទៃក្នុងមិនទាន់បានបំពេញមុខងារពេញលេញ ដើម្បីធានាប្រតិតុល្យការអភិបាលកិច្ចផ្ទៃក្នុង ។

២៥. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ដាក់ឱ្យអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតប្រតិបត្តិការ ដើម្បីផ្តល់ភាពងាយស្រួលដល់ថ្នាក់ដឹកនាំ និងប្រធានអង្គភាពក្នុងការគ្រប់គ្រងជាយុទ្ធសាស្ត្រ និងវាយតម្លៃសមិទ្ធកម្ម (outcome),
- រៀបចំផែនការពង្រឹងសមត្ថភាព, ការធ្វើវិមជ្ឈការមុខងារ និងការទទួលខុសត្រូវ ដល់សាខាខេត្ត-ខណ្ឌ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តមុខងារស្នូល,
- ពង្រឹង និងពង្រីកការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅដល់គ្រប់នាយកដ្ឋាន និងសាខាខេត្ត-ខណ្ឌ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពប្រតិបត្តិការប្រចាំថ្ងៃ,
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ,
- ពង្រឹងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូល និងចែករំលែកទិន្នន័យ និងព័ត៌មាន,
- ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីធានាតម្លាភាព និងគណនេយ្យភាពអភិបាលកិច្ចផ្ទៃក្នុង ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យប្រភពចំណូល ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (business cycle),
- កសាង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យដំណើរការប្រតិបត្តិការស្នូលទាន់ពេលវេលា ដើម្បីពង្រឹងប្រសិទ្ធភាពតាមដានវឌ្ឍនភាពសូចនាករសមិទ្ធកម្មគន្លឹះ ។

## ខ. មុខងារប្រតិបត្តិការស្នូល

២៦. ការធ្វើទំនើបភាវូបនីយកម្មមុខងារប្រតិបត្តិការស្នូលតាមឧត្តមានុវត្តន៍អន្តរជាតិត្រូវមានលក្ខណៈពិសេសបីគឺ÷ (១)ការធ្វើឱ្យកាន់តែប្រសើរឡើងនូវដំណើរការការងារ និងការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន មុននឹងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, (២)ការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាលើមុខងារប្រតិបត្តិការទាំងអស់ និង (៣)ការផ្លាស់ប្តូរទៅជារដ្ឋបាលសារពើពន្ធដែលផ្តោតលើអ្នកជាប់ពន្ធ (customer-oriented tax administration) តាមរយៈការពង្រឹងគុណភាពសេវា ។ ដូចនេះ សម្រាប់កម្ពុជា ការធ្វើទំនើបភាវូបនីយកម្មមុខងារប្រតិបត្តិការស្នូលនឹងធ្វើការរៀបចំឡើងវិញនូវដំណើរការការងារ និងធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡាលើគ្រប់មុខងារស្នូល (ការចុះបញ្ជី, ការដាក់លិខិតប្រកាស, ការបង់ប្រាក់ពន្ធ, សេវាអ្នកជាប់ពន្ធ, សវនកម្ម, បណ្តឹងតវ៉ា និងបំណុល) ព្រមទាំងផ្តោតជាចម្បងលើការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ, អនុលោមភាពដោយស្ម័គ្រចិត្ត (អត្រាខ្ពស់នៃការបង់ពន្ធទាន់ពេលវេលា និងអត្រាទាបនៃបំណុលពន្ធ) និងកាត់បន្ថយ និងឈានទៅលុបបំបាត់ការគេចវេសពន្ធ ។

២៧. នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងមកនេះ ទោះបីមានវឌ្ឍនភាពក្នុងការកែទម្រង់មុខងារប្រតិបត្តិការស្នូល ក៏កំណើននៃតម្រូវការអ្នកជាប់ពន្ធ និងការវិវត្តនៃសេដ្ឋកិច្ចនៅបន្តបង្កើនបន្ទុកដល់រដ្ឋបាលពន្ធ និងផ្តល់ភាពស្មុគស្មាញដល់អ្នកជាប់ពន្ធក្នុងការអនុលោមដោយស្ម័គ្រចិត្ត ។ បញ្ហាធំពីរនៅក្នុងប្រតិបត្តិការស្នូល គឺការបង្វិលសងអាករលើតម្លៃបន្ថែម (VAT) និងការធ្វើសវនកម្មជាន់គ្នា ដែលត្រូវបានដោះស្រាយតាមរយៈការដាក់ចេញនូវ (១)ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម និង (២)ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩ ដែលបានកំណត់នូវវិធាន និងនីតិវិធីលម្អិត សំដៅលុបបំបាត់ការចុះធ្វើសវនកម្មជាន់គ្នារវាងអង្គភាព ជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ, ការកាត់បន្ថយពេលកំណត់ពន្ធឡើងវិញ ចំពោះការធ្វើសវនកម្មពេញលេញ ដោយកំណត់គោលការណ៍ទូទៅមកនៅត្រឹម ៣ ឆ្នាំ ថយក្រោយ និងកាត់បន្ថយអត្រាការប្រាក់ទោសទណ្ឌលើការបង់ប្រាក់ពន្ធយឺតពី ២% មកត្រឹម ១,៥% ក្នុងមួយខែ ។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់មុខងារប្រតិបត្តិការស្នូលនៅបន្តមានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម÷

- ការបង្កើនសកម្មភាពសវនកម្មយ៉ាងគំហុកកន្លងមក បានកាត់បន្ថយសកម្មភាពគេចវេសពន្ធមួយចំនួន ប៉ុន្តែក៏បានបង្កើតជាបញ្ហានូវការកើនឡើងនូវបន្ទុកការងាររបស់សវនករ ដែលបញ្ហាទាំងអស់នេះ នាំឱ្យមានការកើនឡើងចំណាយ និងប៉ះពាល់ដល់និរន្តរភាពនៃអនុលោមភាពស្ម័គ្រចិត្តក្នុងរយៈពេលវែង,
- ផែនការយុទ្ធសាស្ត្រផ្តល់សេវាអ្នកជាប់ពន្ធនៅមិនទាន់គ្រប់ជ្រុងជ្រោយ ដោយសារ÷ (១)ការអប់រំផ្តោតតែលើអ្នកជាប់ពន្ធបច្ចុប្បន្ន (existing taxpayers) និងមិនទាន់បានផ្សព្វផ្សាយពីវប្បធម៌បង់ពន្ធឱ្យបានទូលំទូលាយដល់អ្នកជាប់ពន្ធអនាគត (future taxpayers) និង (២)គុណភាពសេវានៅមានកម្រិត (ការបកស្រាយច្បាប់ និងបទប្បញ្ញត្តិមួយចំនួនមិនទាន់មានសង្គតិភាព និងការបង្វិលសងអាករលើតម្លៃបន្ថែមនៅមានភាពយឺតយ៉ាវខ្លាំង ។ល។),
- ទោះបីការធ្វើទំនើបភាវូបនីយកម្មកន្លងមកលើមុខងារប្រតិបត្តិការស្នូលមួយចំនួន បានផ្តល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងជួយលើកកម្ពស់កម្រិតអនុលោមភាពដោយស្ម័គ្រចិត្ត ប៉ុន្តែការធ្វើទំនើបភាវូបនីយកម្មនេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ, ស្វ័យប្រវត្តិកម្មពេញលេញ (fully automated) និងប្រទាក់ក្រឡា (integrated) ។

២៨. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់នូវ (១)ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម និង (២)ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩,

- រៀបចំ និងអនុវត្តផែនការរៀបចំឡើងវិញនូវដំណើរការការងារ (business process re-engineering) និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយរលូន,
- ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្ម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ,
- ពង្រឹងការធ្វើសវនកម្មដោយផ្អែកលើហានិភ័យ (risk-based audit),
- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមានលក្ខណៈនវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកជាប់ពន្ធ,
- បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ និងរៀបចំផែនការលើកទឹកចិត្តដល់មន្ត្រីផ្តល់សេវា,
- អនុវត្តការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា,
- ពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ាអ្នកជាប់ពន្ធ ដើម្បីធានាទំនុកចិត្តរបស់អ្នកជាប់ពន្ធ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើនសមត្ថភាពធ្វើសវនកម្មសំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ,
- ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងជៀសវាងការកើនឡើងបំណុលពន្ធអនាគត ។

### គ. មុខងារគាំទ្រ

២៩. ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រទាមទារនូវកត្តាពីរសំខាន់គឺ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលគាំទ្រការធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធ និងធនធានមនុស្សដែលមានសមត្ថភាព និងជំនាញវិភាគតាមវិស័យ ។ ដូចនេះ សម្រាប់កម្ពុជា ការធ្វើទំនើបភាវូបនីយកម្មមុខងារគាំទ្រនឹងផ្តោតលើការងារពីរផ្នែកគឺ÷ (១) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡារួមមានមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ, ប្រព័ន្ធវិភាគទិន្នន័យនិងព័ត៌មានអ្នកជាប់ពន្ធ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ, ប្រព័ន្ធចែករំលែកទិន្នន័យក្នុងស្ថាប័ន និងអន្តរស្ថាប័ន និង (២) យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ ដើម្បីធានាថាមន្ត្រីអនុវត្តការងារប្រកបដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ ។ ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក វឌ្ឍនភាពសំខាន់ៗ ក្នុងការកែទម្រង់មុខងារគាំទ្ររបស់អគ្គនាយកដ្ឋានពន្ធដារ

មានដូចជា÷ បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ២០១៤-២០១៨, បានបញ្ចប់ផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបានពង្រឹងសវនកម្មផ្ទៃក្នុង ។ យ៉ាងណាមិញ ការអនុវត្តផែនការមេ និងយុទ្ធសាស្ត្រខាងលើនៅមិនទាន់អាចគាំទ្រដំណើរការការងារ ប្រកបដោយវិជ្ជាជីវៈ និងប្រសិទ្ធភាព ដោយសារបញ្ហាមួយចំនួន ដូចខាងក្រោម÷

- សមត្ថភាពជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីមួយចំនួននៅមានកម្រិត,
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធមិនទាន់មានភាពប្រទាក់ក្រឡា និងស្វ័យប្រវត្តិកម្មពេញ-លេញ ដែលមិនអាចធានាបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពប្រតិបត្តិការប្រចាំថ្ងៃ និងការផ្តល់សេវា ។

៣០. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងសមត្ថភាពមន្ត្រីតាមរយៈ ការបណ្តុះបណ្តាល និងរៀបចំប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មការងារ,
- អនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញនិងប្រទាក់ក្រឡា, ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និងប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន ដោយរួមបញ្ចូលទាំងផែនការវិនិយោគ,
- សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ឬបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិ និងលទ្ធភាពពេញលេញដល់រដ្ឋបាលសារពើពន្ធក្នុងការទទួលយកព័ត៌មាន និងទិន្នន័យពន្ធដារ (submission and management of taxation data) ដោយផ្តល់លទ្ធភាពតភ្ជាប់រវាងប្រព័ន្ធទិន្នន័យរបស់ស្ថាប័ននានាមកកាន់ប្រព័ន្ធទិន្នន័យរបស់ អគ្គនាយកដ្ឋានពន្ធដារ,
- សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការតម្រូវឱ្យអាជីវកម្មទាំងអស់ ប្រើប្រាស់ប្រព័ន្ធ cash receipt system សម្រាប់ប្រតិបត្តិការជាមួយអតិថិជនទូទៅ (business to customers) ដោយសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ,
- រៀបចំក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីតម្រូវការនៃព័ត៌មាន និងនីតិវិធីនៃការបែងចែកព័ត៌មាន ហើយលើកសំណើរៀបចំនូវថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតម្រូវការវិនិយោគលើហេដ្ឋារចនា-សម្ព័ន្ធចាំបាច់នានា សំដៅធ្វើទំនើបកម្មសម្រួលកិច្ចការចុះបញ្ជីអាជីវកម្ម និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០១៩,
- ពិនិត្យលទ្ធភាព, ភាពចាំបាច់ និងផលប៉ះពាល់លើការរៀបចំឡើងវិញការលើកទឹកចិត្តសវនករពន្ធដារដែលត្រូវផ្សារភ្ជាប់នឹងសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ ដើម្បីធានាថាមន្ត្រីអនុវត្តការងារប្រកប ដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ ។

## ៤.២ ទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

៣១. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ បានធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលគយ ដូចជាការត្រួតពិនិត្យ និងបញ្ចេញទំនិញ, យន្តការឆ្លងកាត់ និងយន្តការគាំទ្រ ហើយជាលទ្ធផលចំណូលពីអគ្គ-នាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ទោះបីជាមានការអនុវត្តនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការកើនឡើងនូវផលិតកម្មក្នុងស្រុក ។ ជាមួយនឹងការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិ ក៏ដូចជាការបន្តពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ជាទិសដៅសម្រាប់រយៈពេល ៥ ឆ្នាំទៅមុខទៀត ការធ្វើទំនើបភាវូបនីយ-កម្មរដ្ឋបាលសារពើពន្ធនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាការងារចាំបាច់ ដើម្បីបន្តសម្រួលពាណិជ្ជកម្មឱ្យបានជាអតិបរមា និងបង្កើនការប្រមូលចំណូល ។ ក្នុងន័យនេះ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ នឹងផ្តោតការធ្វើទំនើបភាវូបនីយកម្មលើ÷ (១)កិច្ចសម្រួលពាណិជ្ជកម្ម, (២)ការកែលម្អ និងពង្រឹងអភិបាលកិច្ច និង (៣)ការគ្រប់គ្រងបែបយុទ្ធសាស្ត្រ ។

**គំនូសបំព្រួញនៃការធ្វើទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**




### ក. កិច្ចសម្រួលពាណិជ្ជកម្ម

៣២. ការកែទម្រង់ដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្ម មានគោលបំណងជួយកាត់បន្ថយចំណាយ និងពេលវេលារបស់ធុរជនក្នុងការបំពេញកាតព្វកិច្ចគយសម្រាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ ។ ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក អ.គ.រ. បានរួមចំណែកកាត់បន្ថយបន្ទុកចំណាយ និងពេលវេលាសម្រាប់ការនាំចេញ-នាំចូលទំនិញ ។

៣៣. ដើម្បីបន្តសម្រួលនូវការធ្វើពាណិជ្ជកម្ម ក៏ដូចជាកាត់បន្ថយនូវចំណាយក្រៅផ្លូវការរបស់វិស័យឯកជន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវប្រកាសលេខ ១៦០៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលបានអនុវត្តជាផ្លូវការចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៩ ។ ប្រកាសនេះត្រូវបានដាក់បញ្ចូលនូវសេវាទាំងអស់ ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ផ្តល់ជូនដល់ធុរជន ទាំងនៅក្នុងការិយាល័យ, ក្រៅការិយាល័យ, ក្នុងម៉ោងធ្វើការ និងក្រៅម៉ោងធ្វើការ ។ រាល់ការផ្តល់សេវាទាំងអស់ត្រូវមានការចេញជាវិក្កយបត្រពីប្រព័ន្ធកុំព្យូទ័រ ដើម្បីទុកជូនទៅម្ចាស់ទំនិញ ដែលជាប្រការធានាបាននូវតម្លាភាពច្បាស់លាស់សម្រាប់ចំណាយលើសេវានេះ ហើយម្ចាស់ទំនិញក៏អាចយកវិក្កយបត្រនេះ ទៅកាត់កងជាចំណាយរបស់ខ្លួន នៅក្នុងការរៀបចំបញ្ជីបង់ពន្ធដារជាផ្លូវការផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវប្រកាសលេខ ៣២៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូលផ្ទុកក្នុងកុងតែន័រ ដែលត្រូវឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ដើម្បីកាត់បន្ថយការកកស្ទះការស្កេនកុងតែន័រនៅក្នុងកំពង់ផែ ។

៣៤. ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងន័យដើម្បីបន្តលើកកម្ពស់ភាពប្រកួតប្រជែងកម្ពុជាបន្ថែមទៀត អ.គ.រ. ត្រូវបន្តដោះស្រាយបញ្ហាមួយចំនួន ដូចខាងក្រោម÷

- នាឆ្នាំ ២០១៨ ប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយបានវាយតម្លៃថា ប្រហែលជាង ១០% នៃប្រតិវេទន៍គយ (single administrative document) ស្ថិតនៅក្នុងច្រកក្រហមដែលទាមទារការត្រួតពិនិត្យរូបវន្ត (physical inspection) និងប្រមាណជាង ៥៤% នៃប្រតិវេទន៍គយស្ថិតនៅក្នុងច្រកលឿងដែលទាមទារឱ្យមានការត្រួតពិនិត្យឯកសារឡើងវិញ ។ សូចនាករកំណត់ហានិភ័យរបស់ប្រព័ន្ធនេះជាកម្មវត្ថុនៃការពិនិត្យសិក្សា ដើម្បីកែលម្អសុក្រឹតភាព និងប្រសិទ្ធភាពនៃការវាយតម្លៃហានិភ័យ,
- ប្រព័ន្ធបញ្ចរតែមួយជាតិ (National Single Window) ពុំទាន់បានបញ្ចប់ និងដាក់ឱ្យដំណើរការពេញលេញនៅឡើយ ។ បច្ចុប្បន្ន ប្រព័ន្ធនេះ ទើបបានឈានដល់ដំណាក់កាលទី ២ ដែលមានក្រសួង-ស្ថាប័នចូលរួមចំនួន ៥ គឺ÷ ក្រសួងសុខាភិបាល, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ដំណាក់កាលទី២នេះ ផ្តោតលើការអភិវឌ្ឍមុខងារចេញអាជ្ញាបណ្ណ, វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ស្របតាមបទប្បញ្ញត្តិជាធរមាន ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តសាកល្បងចាប់ពីខែមិថុនា ឆ្នាំ ២០១៩ តទៅ,
- នាពេលបច្ចុប្បន្ន សាមញ្ញកម្មនៃការបំពេញបែបបទគយនៅមានកម្រិត ដែលនីតិវិធីភាគច្រើនពឹងផ្អែកលើការប្រើប្រាស់ឯកសាររឹង (hard copy) ដូចជាវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (អ.ត.ប.), ប៉ាតង់ និងឯកសារយោងផ្សេងៗទៀតតម្រូវឱ្យមានហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ហើយច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលចូលរួមចំណែកក្នុងការកាត់បន្ថយប្រតិបត្តិការប្រើប្រាស់ឯកសាររឹងក៏មិនទាន់មាននៅឡើយ ។ នីតិវិធីនេះជារបាំងមួយក្នុងកិច្ចសម្រួលពាណិជ្ជកម្ម ក៏ដូចជាឆ្លុះ

បញ្ហាំងនូវភាពមិនទាន់ប្រទាក់ក្រឡានៃប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរវាង អ.គ.រ., អ.ព.ដ. និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។

៣៥. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- កែលម្អវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ,
- ជំរុញការអនុវត្តប្រកាសលេខ ១៦០៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងប្រកាសលេខ ៣២៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូលផ្ទុកក្នុងកុងតែន័រ ឱ្យមានប្រសិទ្ធភាពខ្ពស់,
- បញ្ចប់ការរៀបចំ និងធ្វើវិសោធនកម្មអនុក្រឹត្យលេខ ២០៩ អនក្រ.បក ដោយកាត់បន្ថយឱ្យបានជាអតិបរមា នូវមុខទំនិញជាប់កម្រិតកំណត់ និងមុខទំនិញហាមឃាត់,
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំង ៥ ដើម្បីជំរុញដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី ២ ឱ្យបានទាន់ពេលវេលាដូចដែលបានកំណត់,
- បន្តធ្វើសាមញ្ញកម្ម, ទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅកែលម្អបន្ថែមទៀតនូវគុណភាពនៃការផ្តល់សេវា និងបង្កើនភាពពេញចិត្តរបស់អតិថិជន,
- រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយកិច្ចសម្រួលពាណិជ្ជកម្ម ប្រកបដោយការទទួលខុសត្រូវ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហានិភ័យ ជាពិសេសជំរុញការដាក់អនុវត្តនូវប្រព័ន្ធ pre-arrival information ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារត្រួតពិនិត្យ និងលើកកម្ពស់អនុលោមភាព,
- ធ្វើឱ្យប្រសើរឡើងថែមទៀត នូវការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់,
- ពង្រីកយន្តការធុរជនល្អបំផុត (best trader mechanism) និងឈានទៅអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (authorised economic operator - AEO) និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការនេះ,
- ពង្រីកវិសាលភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព,
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣,
- តភ្ជាប់ប្រព័ន្ធបញ្ជរជាតិតែមួយរបស់កម្ពុជាទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន ។

## ខ. ការកែលម្អ និងពង្រឹងអភិបាលកិច្ច

៣៦. ការកែលម្អ និងពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលពន្ធគយ គឺជាភារកិច្ចគន្លឹះរបស់ អ.គ.រ. ក្នុងការលើកកម្ពស់អនុលោមភាព និងធានាបាននូវចីរភាពចំណូល ។ ការងារសវនកម្មក្រោយបញ្ចេញទំនិញតាមរយៈការធ្វើសវនកម្មពេញលេញ (comprehensive audit) ដោយចុះត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែង គឺនៅតែជាការងារស្នូលក្នុងការពង្រឹងអនុលោមភាព និងចូលរួមសម្រួលពាណិជ្ជកម្មនៅដើមទី ។ ទន្ទឹមនេះ ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក តួលេខបានបង្ហាញថាចំនួនករណីបទល្មើសគយមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ទាំងចំនួនករណីធំ និងករណីតូច ដែលនេះបង្ហាញពីប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបរបស់ អ.គ.រ. ។ ទោះបី អ.គ.រ. សម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់នាពេលកន្លងមក ដូចជាបានដាក់ឱ្យអនុវត្តផែនការសកម្មភាពរយៈពេលមធ្យម ដើម្បីបង្ការ និងបង្ក្រាបអំពើរត់គេចពន្ធគ្រប់ទម្រង់ ក៏នៅមានបញ្ហាមួយចំនួនដែលត្រូវបន្តដោះស្រាយបន្ថែមទៀត ដូចខាងក្រោម÷

- នីតិវិធីត្រួតពិនិត្យរបស់ អ.គ.រ. ផ្តោតចម្បងនៅមាត់ច្រកព្រំដែន (នៅដើមទី) នៅតែបន្តជារបាំងរដ្ឋបាលមួយ ដែលផ្ទុយនឹងការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ដោយសារប្រសិទ្ធភាពនៃយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញនៅមានកម្រិត ។ ទន្ទឹមនេះ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ត្រូវបានធ្វើឡើងភាគច្រើនតែលើគម្រោងវិនិយោគក្នុងវិស័យកាត់ដេរ ដែលយន្តការនេះពុំទាន់ត្រូវបានអនុវត្តទូលំទូលាយស្របតាមគោលការណ៍គ្រប់គ្រងហានិភ័យលើធុរជនផ្សេងទៀត,
- ទោះបីការងារបង្ការ និងបង្ក្រាបបទល្មើសគយមានវឌ្ឍនភាពខ្ពស់ ការដាក់ពិន័យក្នុងករណីខ្លះ នៅមិនទាន់សមស្របនឹងទំហំឬកម្រិតបទល្មើសនៅឡើយ ។

៣៧. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពង្រឹងការកំណត់សូចនាករ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការជ្រើសរើសក្រុមហ៊ុនសម្រាប់ធ្វើសវនកម្ម ដោយផ្អែកលើហានិភ័យ,
- ជំរុញការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយឱ្យបានទូលាយ (comprehensive customs audit) ជាជាងការធ្វើសវនកម្មតែលើឯកសារ (desk review audit),
- បន្តពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ,
- ពង្រឹងសមត្ថភាពរបស់មន្ត្រីសវនកម្មគយ និងបង្កើនចំនួនអង្គភាពសវនកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង,
- បញ្ចប់យុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy),
- ជំរុញការអនុវត្តកម្រិតផ្តន្ទាទោសតាមប្រព័ន្ធតុលាការចំពោះបទល្មើសគយដែលមិនអាចសម្រុះសម្រួលដោះស្រាយដោយរដ្ឋបាលគយ,

- ពិនិត្យឡើងវិញលើសិទ្ធិរបស់អង្គភាពក្រោមឱវាទ អ.គ.រ. ក្នុងការសម្រុះសម្រួលបទល្មើសគយ តាមឋានានុក្រម,
- តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយតាមបណ្តាអង្គភាពគយ និងរដ្ឋាករពាក់ព័ន្ធ ។

## គ. ការគ្រប់គ្រងបែបយុទ្ធសាស្ត្រ

៣៨. ការគ្រប់គ្រងបែបយុទ្ធសាស្ត្រមានគោលបំណង (១)ពង្រឹងការគ្រប់គ្រងជាយុទ្ធសាស្ត្រនៃប្រភពចំណូលគយ និង(២)អភិវឌ្ឍធនធានមនុស្សទាំងបរិមាណ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃរចនាសម្ព័ន្ធថ្មី និងចូលរួមធានាចីរភាពចំណូល ។ អ.គ.រ. បានអនុវត្តវិធានការកែលម្អការគ្រប់គ្រងប្រភពចំណូលសំខាន់ៗ និងធនធានមនុស្ស ប៉ុន្តែនៅមិនទាន់មានលក្ខណៈយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដែលរួមមានបញ្ហាដូចខាងក្រោម÷

- ទំនិញសំខាន់ៗមួយចំនួនដែលជាប្រភពចំណូល បាននិងកំពុងនាំចូលតាមមាត់ច្រកជាច្រើន ដែលអាចនឹងបង្កឱកាសក្នុងការគេចវេសពន្ធ និងបង្កើតភាពស្មុគស្មាញក្នុងការគ្រប់គ្រងប្រភពចំណូល,
- ការកំណត់លក្ខខណ្ឌក្នុងការលើកទឹកចិត្តលើការនាំចូលមុខទំនិញមួយចំនួន ដើម្បីអភិវឌ្ឍវិស័យអាទិភាពនៅមានភាពស្មុគស្មាញ ហើយមិនច្បាស់លាស់ ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ការប្រមូលចំណូល,
- នាពេលបច្ចុប្បន្ន ធនធានមនុស្សសម្រាប់គាំទ្រប្រតិបត្តិការគយមួយចំនួន នៅមានកម្រិតទាំងចំនួន និងជំនាញ,
- ប្រព័ន្ធស្វ័យប្រវត្តិកម្មគយនៅមិនទាន់ធ្វើសន្ទានកម្មពេញលេញ ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់ការពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារ ។

៣៩. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពិនិត្យ និងកំណត់មុខទំនិញដែលជាប្រភពចំណូលសំខាន់ និងពិនិត្យភាពចាំបាច់នៃការកំណត់មាត់ច្រកជាក់លាក់សម្រាប់ការនាំចូលមុខទំនិញទាំងនេះ តាមកម្រិតហានិភ័យ,
- បន្តពង្រឹងយន្តការផ្តល់ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម,
- បញ្ចប់ការកសាងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT Strategy) របស់ អ.គ.រ. ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- រៀបចំផែនការជាក់លាក់ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប,

- ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ធានកម្មបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. ឱ្យបានកាន់តែទូលាយ ដូចជា ប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, ប្រព័ន្ធបញ្ជរតែមួយជាតិ និង direct trader input (DTI) ។ល។ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ។

## ៤.៣ គោលនយោបាយសារពើពន្ធ

៤០. ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដាក់ចេញការធ្វើវិចារណកម្ម (rationalization) លើគោលនយោបាយសារពើពន្ធ សំដៅធានាសង្គតិភាពជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍ជាតិ, ជំរុញនិងតម្រង់ទិសការវិនិយោគ, លើកកម្ពស់ឧត្តមភាពក្នុងការប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងប្រមូលចំណូលឱ្យអស់សក្តានុពល ស្របទៅនឹងការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច-សង្គមកម្ពុជា ដោយប្រកាន់យកគោលការណ៍ សាមញ្ញភាព, តម្លាភាព, ភាពប្រាកដប្រជា, សមធម៌ និងប្រសិទ្ធភាព ។ យុទ្ធសាស្ត្រកៀរគរចំណូលនេះ នឹងដាក់ចេញនូវវិធានការគោលនយោបាយសារពើពន្ធរយៈពេលខ្លី និងមធ្យម ដើម្បីដោះស្រាយបញ្ហាប្រឈមទៅតាមប្រភេទពន្ធ ដូចខាងក្រោម÷

### ៤.៣.១ គោលនយោបាយអាករពិសេស

៤១. ការដាក់អនុវត្តគោលនយោបាយអាករពិសេស មានគោលបំណងប្រមូលចំណូលរដ្ឋ, កែប្រែឥរិយាបថអ្នកប្រើប្រាស់ និងកាត់បន្ថយផលអវិជ្ជមាន (negative externalities) ក្នុងការប្រើប្រាស់ផលិតផលដែលអាចប៉ះពាល់សុខភាព និងបរិស្ថាន ដូចជាភេសជ្ជៈ, គ្រឿងស្រវឹង, បារី, ប្រេងឥន្ធនៈ, រថយន្ត និងផលិតផលប្រណិតមួយចំនួន ។ ប្រទេសកម្ពុជាបានអនុវត្តអាករពិសេស លើកដំបូងដោយផ្អែកលើក្រឹត្យ-ច្បាប់ឆ្នាំ ១៩៨៥ ដែលត្រូវបានធ្វើវិសោធនកម្មចំនួនបីលើកជាបន្តបន្ទាប់[9] ប៉ុន្តែមិនទាន់មានច្បាប់ស្តីពីអាករពិសេសដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។ ដើម្បីអនុវត្តការប្រមូលអាករពិសេស រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញអនុក្រឹត្យចំនួន ១៣ និងប្រកាសចំនួន ១៥ ជាបន្តបន្ទាប់[10] ជាពិសេសអាករពិសេសលើមុខទំនិញសំខាន់ៗ ដូចជាយានយន្ត, ភេសជ្ជៈ និងបារី ។ ជាក់ស្តែង ចំណូលពីអាករពិសេសមានកំណើនជាមធ្យមប្រមាណ ៣០% ក្នុងមួយឆ្នាំដែលកើនពី ១.៩២០ ពាន់លានរៀល នៅឆ្នាំ ២០១៤ ដល់ ៤.៩៥៨ ពាន់លានរៀលនៅឆ្នាំ ២០១៨[11] ហើយចំណូលអាករពិសេសភាគច្រើនបានមកពីទំនិញនាំចូល ។

៤២. ទោះជាការប្រមូលចំណូលលើអាករពិសេសមានការកើនឡើងគួរឱ្យកត់សម្គាល់ ទាំងក្នុងទិដ្ឋភាពទំហំ និងកំណើន ការអនុវត្តគោលនយោបាយអាករពិសេសនៅមិនទាន់ឆ្លើយតបបានពេញលេញទៅនឹងការវិវត្តនៃបរិការណ៍សេដ្ឋកិច្ច-សង្គម ក៏ដូចជាបរិយាកាសធុរកិច្ច និងឧត្តមានុវត្តន៍អន្តរជាតិ ។ ជារួម ការអនុវត្តគោលនយោបាយអាករ-

---

[9] ការធ្វើវិសោធនកម្មក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥, ច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ និង ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០១ ។

[10] យោងកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ ឆ្នាំ ២០១៤ និងអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ, អត្រាអាករពិសេស និងអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន ។

[11] ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ។

ពិសេសនៅមានបញ្ហាគន្លឹះមួយចំនួនដូចជា÷ (១)កង្វះគោលនយោបាយ និងច្បាប់អាករពិសេសពេញលេញ និងគ្រប់ជ្រុងជ្រោយ បង្កភាពស្មុគស្មាញក្នុងការគ្រប់គ្រងរបស់រដ្ឋបាលសារពើពន្ធ និងការបង្កើនបន្ទុកមិនចាំបាច់ដល់អ្នកជាប់ពន្ធ, (២)ការផ្លាស់ប្តូរអាករពិសេសញឹកញាប់ប៉ះពាល់ដល់ផែនការអាជីវកម្ម និងលំហូរសាច់ប្រាក់របស់ធុរជន, (៣)ការដាក់បន្ទុកអាករពិសេសមិនស្មើភាពរវាងទំនិញនាំចូល និងទំនិញផលិតក្នុងស្រុក និង (៤)ការកំណត់គោលនយោបាយអាករពិសេសទាំងអត្រា, មូលដ្ឋាន និងប្រភេទទំនិញកន្លងមក នៅមិនទាន់បានធ្វើវិចារណកម្មគ្រប់ជ្រុងជ្រោយ ។

៤៣. ទន្ទឹមនេះ គោលនយោបាយអាករពិសេសលើទំនិញ ដែលជាប្រភពចំណូលសំខាន់ដូចជា រថយន្ត និងបារី ក៏មានបញ្ហាប្រឈមជាក់លាក់ដូចជា÷ (១)បន្ទុកអាករពិសេសលើយានយន្តភាតរបរិស្ថាន (environmentally friendly vehicles)[12] នៅខ្ពស់ ដែលមិនលើកទឹកចិត្តដល់ការប្រើប្រាស់យានយន្តប្រភេទនេះ, (២)យានយន្តមានម៉ាស៊ីនទំហំស៊ីឡាំងតូចមានអត្រាអាករពិសេសខ្ពស់ ចំណែកឯយានយន្តមានម៉ាស៊ីនទំហំស៊ីឡាំងធំនៅមានអត្រាទាបជាងប្រទេសមួយចំនួនក្នុងតំបន់, (៣)យានយន្តដឹកអ្នកដំណើរដែលមានកៅអីច្រើន និងរថយន្តដឹកទំនិញមានបន្ទុកពន្ធអាករពិសេសខ្ពស់ និង (៤)បន្ទុកអាករពិសេសលើបារីនៅមានកម្រិតទាប ។

៤៤. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- កំណត់គោលការណ៍នៃរយៈពេលចូលជាធរមាននៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស ក្នុងការធានាភាពប្រាកដប្រជានៃគោលនយោបាយ ដើម្បីសម្រួលដល់ការរៀបចំផែនការអាជីវកម្ម និងលំហូរសាច់ប្រាក់របស់ធុរជន,
- សិក្សា និងពិនិត្យឡើងវិញលើមូលដ្ឋានកំណត់អាករពិសេសរបស់ផលិតផលក្នុងស្រុក ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកទឹកចិត្តឱ្យមានផលិតកម្មក្នុងស្រុកកាន់តែច្រើន,
- ពិនិត្យឡើងវិញលើអត្រាអាករពិសេស និងមូលដ្ឋានគិតពន្ធលើយានយន្តភាតរបរិស្ថាន (environmentally friendly vehicles), ផលិតផលបារី, ស្រាបៀរ, ស្រា និងភេសជ្ជៈមានជាតិស្ករ ។ល។ និងទំនិញប្រភេទប្រណិតមួយចំនួន ដើម្បីធានាសុខុមាលភាពប្រជាជន និងការពារបរិស្ថាន,
- បន្តធ្វើវិចារណកម្មអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញ,
- ពង្រឹងអនុលោមភាពការងារបច្ចេកទេសគយ តាមរយៈការពង្រឹងយន្តការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញ និងការជំរុញការលើកទឹកចិត្តអនុលោមភាពដោយស្ម័គ្រចិត្ត,
- រៀបចំគោលនយោបាយអាករពិសេស ដើម្បីពង្រឹងភាពដែលអាចទស្សន៍ទាយបាន (predictability) នៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស និងលើកកម្ពស់បរិយាកាសធុរកិច្ច,

---

[12] រថយន្តនាំចូលប្រមាណ ៩០% ជារថយន្តប្រើប្រាស់រួច ហើយភាគច្រើនមានអាយុចាប់ពី ១០ ឆ្នាំឡើងទៅ ។

- រាល់សំណើកែប្រែគោលនយោបាយអាករពិសេស ត្រូវដាក់ឱ្យមានការពិគ្រោះយោបល់ក្នុងគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីធានានូវប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្ត ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ពិនិត្យលទ្ធភាពប្តូរប្រព័ន្ធអាករពិសេសពី ប្រភេទគិតតាមអត្រា (ad valorem) ទៅជាប្រព័ន្ធចម្រុះដែលគិតតាមអត្រាផងនិង/ ឬគិតតាមឯកតាផង (mixed method) ដើម្បីធានាបានសមធម៌រវាងផលិតផលក្នុងស្រុក និងផលិតផលនាំចូល,
- រៀបចំឱ្យមានច្បាប់អាករពិសេសរួម និងគ្រប់ជ្រុងជ្រោយ ដើម្បីសម្រួលដល់ការគ្រប់គ្រង, ការអនុវត្ត និងការពង្រឹងអនុលោមភាព ។

### ៤.៣.២ ពន្ធលើអចលនទ្រព្យ

៤៥. គោលនយោបាយពន្ធលើអចលនទ្រព្យ មានគោលបំណងធានានូវសមធម៌, បង្កើនប្រសិទ្ធភាពលើការប្រើប្រាស់អចលនទ្រព្យ និងប្រមូលចំណូលសម្រាប់អភិវឌ្ឍមូលដ្ឋាន ។ បច្ចុប្បន្ន ប្រទេសកម្ពុជាអនុវត្តពន្ធបីប្រភេទលើអចលនទ្រព្យគឺ÷ (១)ពន្ធលើអចលនទ្រព្យ (property tax) មានអត្រា ០,១%, (២)ពន្ធលើដីធ្លីមិនបានប្រើប្រាស់ (tax on unused land) មានអត្រា ២% និង (៣)ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ (property transfer tax) មានអត្រា ៤% ។ ទន្ទឹមនេះ ការអនុវត្តពន្ធទាំងបីប្រភេទក៏សំដៅលើកកម្ពស់វប្បធម៌បង់ពន្ធរបស់ប្រជាពលរដ្ឋ និងជំរុញឱ្យមានការវិនិយោគលើដីទំនេរ ។

៤៦. វិសាលភាពនៃការអនុវត្តពន្ធទាំងបីប្រភេទគឺ÷ (១)ការប្រមូលពន្ធលើអចលនទ្រព្យ (property tax) បានកំពុងអនុវត្តនៅក្នុងរាជធានី និងទីក្រុងនានាតាមបណ្តាខេត្ត ដោយមូលដ្ឋានគិតពន្ធគឺកំណត់យក ៨០% នៃថ្លៃដី, ផ្ទះ, អគារ និងសំណង់ផ្សេងៗដែលសង់ភ្ជាប់នឹងដីនោះ និងដកទឹកប្រាក់ចំនួន ១០០ លានរៀលបន្ថែមទៀត, (២)ពន្ធលើដីធ្លីមិនបានប្រើប្រាស់ អនុវត្តលើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយ ដែលមូលដ្ឋានគិតពន្ធកំណត់ដោយគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និង (៣)ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យអនុវត្តចំពោះការទិញ-លក់, ការដោះដូរ, ការទទួលអំណោយ និងការដាក់ភាគទុនក្រុមហ៊ុន ប៉ុន្តែការផ្ទេរសិទ្ធិកាន់កាប់ក្នុងរង្វង់ញាតិត្រូវបានលើកលែង និងអនុគ្រោះចាប់ពីឆ្នាំ ២០១៦ តរៀងមក ។

៤៧. ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ស្របជាមួយនឹងការអភិវឌ្ឍយ៉ាងលឿនក្នុងវិស័យអចលនទ្រព្យ ចំណូលពន្ធលើអចលនទ្រព្យ, ពន្ធប្រថាប់ត្រា និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានការកើនឡើងគួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង ចំណូលពន្ធសរុបទាំងបីប្រភេទបានកើនពី ៣៥២ ពាន់លានរៀលក្នុងឆ្នាំ ២០១៤ ដល់ ៧៥០ ពាន់លានរៀល ក្នុងឆ្នាំ ២០១៨[13] ។ ស្របជាមួយគ្នានេះ ថ្លៃដីក៏មានការកើនឡើងជាគំហុក ដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាព

---

[13] ទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ត្រឹមថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ។

រស់នៅ និងបង្កើនបន្ទុកថ្លៃដើមមកលើសហគ្រាសធុនតូច និងមធ្យម ព្រមទាំងការប្រកបរបរក្នុងវិស័យកសិកម្ម ដែលកត្តាទាំងនេះបាននិងកំពុងបង្អាក់ដំណើរការក្នុងការអនុវត្តគោលនយោបាយជំរុញពិពិធកម្មសេដ្ឋកិច្ច ។ ជារួម បញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តដោះស្រាយ មានដូចជា÷ (១)ការអនុវត្តពន្ធលើអចលនទ្រព្យនៅមិនទាន់គ្របដណ្ដប់គ្រប់ទីប្រជុំជន, (២)ថ្លៃអចលនទ្រព្យមិនទាន់បានធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់, (៣)កង្វះមូលដ្ឋានទិន្នន័យប្រមូលផ្តុំ និង (៤)មិនទាន់មានគោលនយោបាយគ្រប់គ្រងសកម្មភាពបរិកប្បកម្មអចលនទ្រព្យ (property speculation) នៅឡើយ ។

៤៨. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- រៀបចំ និងដាក់ឱ្យអនុវត្តកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) លើពន្ធអចលនទ្រព្យ ឱ្យស្របនឹងថ្លៃអចលនទ្រព្យដែលត្រូវធ្វើបច្ចុប្បន្នភាពសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រា ដោយដាក់ឱ្យអនុវត្តនៅឆ្នាំ ២០១៩,
- កំណត់គោលការណ៍ធ្វើបច្ចុប្បន្នកម្មថ្លៃអចលនទ្រព្យ សម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រា និងកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) រៀងរាល់ ៥ ឆ្នាំម្តង,
- ត្រួតពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យក្នុងរង្វង់ញាតិ,
- ពិនិត្យលទ្ធភាពលើការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន,
- ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- សិក្សា, រៀបចំ និងដាក់ចេញវិធានការបង្ការសកម្មភាពបរិកប្បកម្មលើអចលនទ្រព្យ (property speculation) ។

### ៤.៣.៣ អាករលើតម្លៃបន្ថែម

៤៩. ចាប់តាំងពីការដាក់អនុវត្តអាករលើតម្លៃបន្ថែមនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៩ ប្រភេទពន្ធនេះបានក្លាយជាប្រភពចំណូលដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ចំណូលអាករលើតម្លៃបន្ថែមមានកំណើនជាមធ្យម ១៦% ពីឆ្នាំ ២០១៤ ដល់ ឆ្នាំ ២០១៨ ។ ប្រទេសកម្ពុជាអនុវត្តអត្រាអាករលើតម្លៃបន្ថែម ១០% លើទំនិញ និងសេវាភាគច្រើន ដែលប្រហាក់ប្រហែលនឹងបណ្តាប្រទេសក្នុងអាស៊ាន លើកលែងតែប្រទេសថៃ, សិង្ហបុរី និងម៉ាឡេស៊ី ដែលមានអត្រាទាបជាងនេះ ដែលការអនុវត្តនេះស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ ក៏ដូចជាជួយពង្រឹងប្រសិទ្ធភាពក្នុងការប្រមូលចំណូល ។ ការអនុវត្តអាករលើតម្លៃបន្ថែមក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនៅមិនទាន់បានគិតគូរគ្រប់ជ្រុងជ្រោយលើប្រភេទទំនិញចាំបាច់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ក៏ដូចជាមុខទំនិញជាធាតុចូលសម្រាប់គាំទ្រ

ផលិតកម្មក្នុងវិស័យអាទិភាព ។ កន្លងមក អាករលើតម្លៃបន្ថែមត្រូវបានចាត់ជាបន្ទុករបស់រដ្ឋលើមុខទំនិញដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ[14] ប៉ុន្តែមានចរិតជាវិធានការដោះស្រាយបញ្ហាតាមករណីជាក់ស្តែង (ad hoc) ដែលទាមទារឱ្យមានការពិនិត្យឡើងវិញ ។

៥០. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាករលើតម្លៃបន្ថែមដោយផ្តោតលើវិក្កយបត្រអាករ (tax invoice) និងវិក្កយបត្រអាករតាមប្រព័ន្ធអេឡិចត្រូនិក (e-tax system) ព្រមទាំង សិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ,
- ពិនិត្យឡើងវិញលើការលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

### ៤.៣.៤ អាករសម្រាប់បំភ្លឺសាធារណៈ

៥១. ប្រទេសកម្ពុជាបានដាក់អនុវត្តអាករសម្រាប់បំភ្លឺសាធារណៈ ៣% លើតម្លៃសុរាមេរ៉ៃ និងបារី និងត្រូវកំណត់គ្រប់ដំណាក់កាលផ្គត់ផ្គង់នៅឆ្នាំ ១៩៩៩ ។ ទន្ទឹមនេះ ប្រទេសមួយចំនួននៅអាស៊ីក៏បានអនុវត្តប្រភេទពន្ធប្រហាក់ប្រហែលនេះក្នុងគោលបំណងខុសគ្នាៗ ដូចជាប្រទេសថៃបានអនុវត្តពន្ធសុខភាព (health surtax), ប្រទេសកូរ៉េបានអនុវត្តពន្ធអប់រំ និងសុខភាពសាធារណៈ (education and public health tax) និងតៃវ៉ាន់បានអនុវត្តពន្ធសុខភាព (health tax) លើផលិតផលស្រា, ស្រាបៀរ និងបារី ។ ការអនុវត្តអាករសម្រាប់បំភ្លឺសាធារណៈគ្រប់ដំណាក់កាលផ្គត់ផ្គង់បានបង្កើនបន្ទុកអនុលោមភាពដល់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ ។ ជាក់ស្តែង ការប្រមូលចំណូលភាគច្រើនបាននៅដំណាក់កាលទីមួយ ខណៈដែលអនុលោមភាពមានកម្រិតទាបចាប់ពីប្រតិបត្តិការដំណាក់កាលទីពីរ ។ ទោះបីជា នៅក្នុងឆ្នាំ ២០១៨ មានការកំណត់យក ២០% នៃតម្លៃលើវិក្កយបត្រជាមូលដ្ឋានគិតពន្ធអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់ប្រតិបត្តិការចាប់ពីដំណាក់កាលទីពីរ ក៏ការកំណត់នេះនៅតែមិនឆ្លុះបញ្ចាំងពីកម្រិតប្រាក់ចំណូលជាក់ស្តែងដែលជាមូលដ្ឋានគិតពន្ធរបស់អ្នកផ្គត់ផ្គង់បន្ត ដែលអាចប៉ះពាល់ដល់ការប្រកួតប្រជែងទីផ្សារ ។

៥២. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពិនិត្យលទ្ធភាពធ្វើការកែសម្រួលអាករសម្រាប់បំភ្លឺសាធារណៈ ដើម្បីបង្កើនអនុលោមភាព, ផ្តល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ។

---

[14] ប្រកាសលេខ ៣៦១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៨ ។

### ៤.៣.៥ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល

៥៣. កម្ពុជាបានប្រមូលពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល តាមរយៈពន្ធលើប្រាក់បៀវត្ស និងលើអត្ថប្រយោជន៍បន្ថែម ព្រមទាំងពន្ធលើប្រាក់ចំណូលពីប្រភពផ្សេងៗ ដូចជាពន្ធលើឈ្នួលផ្ទះ និងដី, ការប្រាក់, ភាគលាភ និងសួយសារទៅតាមអត្រាផ្សេងៗគ្នា[15] ។ ប៉ុន្តែ រាជរដ្ឋាភិបាលមិនទាន់បានប្រមូលពន្ធលើប្រាក់ចំណូលពីប្រភពផ្សេងទៀត ដូចជាចំណេញមូលធន (capital gain) ដែលមិនធានានូវសមធម៌, យុត្តិធម៌ ព្រមទាំងបាត់បង់សក្តានុពលចំណូលពន្ធមួយចំនួន ។ កត្តានេះទាមទារឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល តាមរយៈវិធានការមួយចំនួនដូចខាងក្រោម៖

**វិធានការរយៈពេលខ្លី ២០១៩-២០២០៖**

- កសាងក្របខ័ណ្ឌគោលនយោបាយ សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល,
- ដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន (capital gain) ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣៖**

- រៀបចំរដ្ឋបាលសារពើពន្ធដែលមានសមត្ថភាព និងឯកទេស សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលប្រកបដោយប្រសិទ្ធភាព ។

### ៤.៣.៦ ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៥៤. ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាក្នុងតំបន់ និងសកលលោក សេដ្ឋកិច្ចឌីជីថលនៅកម្ពុជាបាននិងកំពុងលេចរូបរាងជាបណ្តើរៗ និងបានបង្កើតជាសកម្មភាពធុរកិច្ចថ្មីៗជាច្រើនតាមប្រព័ន្ធអេឡិចត្រូនិក ។ នៅឆ្នាំ ២០១៧ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកសរុបនៅកម្ពុជា ដោយប្រើប្រាស់មធ្យោបាយទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានប៉ាន់ស្មានមានទំហំប្រមាណ ១១២ លានដុល្លារអាមេរិក ដែលស្មើ នឹង ០,៥១% នៃ ផ.ស.ស. ។ ក្នុងនោះ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុកមានទំហំប្រមាណ ៦,៤ លានដុល្លារអាមេរិក ខណៈដែលទំហំពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែនមានទំហំប្រមាណ ១០៥ លានដុល្លារអាមេរិក ដែលមានកំណើនក្នុងរង្វង់ ៣០% ក្នុងរយៈពេលបីឆ្នាំកន្លងមក ។ ការទូទាត់ខាងលើភាគច្រើនជាការចំណាយលើសំបុត្រយន្តហោះ និងវិស័យទេសចរណ៍ ។

៥៥. ប្រទេសកម្ពុជាមិនទាន់មានក្របខ័ណ្ឌគតិយុត្តគ្រប់គ្រាន់ ក្នុងការប្រមូលចំណូលពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែននោះទេ ស្របពេលដែលប្រទេសជាច្រើននៅក្នុងសកលលោក និងក្នុងសមាគមអាស៊ាននៅពុំទាន់មានយន្តការរួមណាមួយក្នុងការប្រមូលចំណូលពីប្រភេទពាណិជ្ជកម្មនេះ ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តតាមដាន និងជំរុញសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងធុរកិច្ចថ្មី (start-up) ឱ្យកាន់តែលូតលាស់ថែមទៀតដើម្បីឈានដល់ "ដំណាក់កាលរីកចម្រើន" ដែលអាចលើកស្ទួយសេដ្ឋកិច្ចកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំប្រព័ន្ធអេកូឡូហ្ស៊ីដែលគាំទ្រ និងបង្កើតជាបរិស្ថានអំណោយផលសម្រាប់ធុរកិច្ចថ្មី (start-up) ដែល

[15] ទោះបីជា មិនទាន់មានច្បាប់ ឬ បទប្បញ្ញត្តិរួមស្តីពីពន្ធលើចំណូលរូបវន្តបុគ្គល ។

រួមមានទាំងការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់ផ្សេងៗ, ការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ និងការវិនិយោគលើធនធានមនុស្ស និងការបណ្តុះបណ្តាលជំនាញ ។

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- សិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តពន្ធ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- សិក្សាលទ្ធភាពក្នុងការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ដើម្បីត្រៀមគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

### ៤.៣.៧ វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ

៥៦. ទន្ទឹមនេះ ដើម្បីធានាបាននូវអភិក្រមទាំងបួន ក្នុងការរៀបចំយុទ្ធសាស្ត្រនេះ ជាពិសេសលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា, កាត់បន្ថយបន្ទុកធុរជន និងរដ្ឋបាលសារពើពន្ធ, បន្តការគាំទ្រការវិនិយោគក្នុងវិស័យអាទិភាព និងជំរុញសកម្មភាពអាជីវកម្ម គោលនយោបាយសារពើពន្ធផ្សេងៗទៀតក៏ចាំបាច់ត្រូវត្រួតពិនិត្យឡើងវិញ ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួន ដូចជា÷ (១) ការប្រមូលពន្ធមិនទាន់ពេញលេញលើអាជីវកម្មក្នុងបរិវេណកាស៊ីណូក្រៅពីអាជីវកម្មភ្នាល់, (២) កម្រិតអប្បបរមាប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គលមានកម្រិតទាបមិនផ្តល់ការលើកទឹកចិត្តក្នុងការធ្វើអាជីវកម្ម, (៣) ផលរបរប្រចាំឆ្នាំ ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច, មធ្យម និងធំ នៅមិនទាន់ឆ្លើយតបទៅនឹងកំណើនសកម្មភាពធុរកិច្ចជាក់ស្តែង ដែលកត្តានេះបានបង្កើនបន្ទុកដល់រដ្ឋបាលថ្នាក់កណ្តាលក្នុងការគ្រប់គ្រងការកើនឡើងអ្នកជាប់ពន្ធធំ, (៤) ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ (២០%) ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) មិនបានលើកទឹកចិត្តជាក់ស្តែងដល់វិនិយោគិន, (៥) មុខទំនិញនាំចូល ដែលជាធាតុចូលសម្រាប់គាំទ្រវិស័យអាទិភាព ដូចជាវិស័យកសិកម្ម អប់រំ និងការដឹកជញ្ជូន នៅមិនទាន់ទទួលបានការលើកទឹកចិត្តពេញលេញ និង (៦) គោលនយោបាយសារពើពន្ធលើវិស័យហិរញ្ញវត្ថុ និងការអនុវត្តមិនមានសង្គតិភាព ។

៥៧. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ដាក់កាតព្វកិច្ចបង់ពន្ធតាមរបបស្វ័យប្រកាសចំពោះអាជីវកម្មទាំងអស់ក្រៅពីសកម្មភាពល្បែង,
- ពិនិត្យឡើងវិញនូវផលរបរប្រចាំឆ្នាំ ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច, មធ្យម និងធំ ដើម្បីឆ្លើយតបទៅនឹងកំណើនសកម្មភាពធុរកិច្ច,
- ពិនិត្យឡើងវិញកម្រិតប្រាក់ចំណូលអប្បបរមាជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គល ដើម្បីលើកទឹកចិត្តការធ្វើអាជីវកម្ម,

- ពិនិត្យឡើងវិញពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ (២០%) ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដើម្បីទាក់ទាញការវិនិយោគ,
- ពិនិត្យឡើងវិញអត្រាពន្ធគយលើមុខទំនិញ ដែលមិនមែនជាប្រភពចំណូលនិងជាធាតុចូលសំខាន់សម្រាប់វិស័យអាទិភាព ដូចជា វិស័យកសិកម្ម, អប់រំ និងដឹកជញ្ជូន ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- ពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធលើវិស័យហិរញ្ញវត្ថុ ។

### ៤.៣.៨ ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ

៥៨. ការលើកទឹកចិត្តពន្ធក្នុងច្បាប់ស្តីពីវិនិយោគនៃកម្ពុជា ដែលបានដាក់ឱ្យប្រើប្រាស់តាំងពីឆ្នាំ ១៩៩៤[16] បានចូលរួមបង្កើតការងារ និងទាក់ទាញវិស័យដែលមានតម្លៃបន្ថែមទាបដូចជា វិស័យវាយនភណ្ឌនិងកាត់ដេរ ជាពិសេសផលិតកម្មស្បែកជើង, វិស័យបង្គុំឧបករណ៍អេឡិចត្រូនិក និងវិស័យដំឡើងកង់ជាដើម ។ ប៉ុន្តែការលើកទឹកចិត្តពន្ធនាពេលបច្ចុប្បន្ន ពុំមានការផ្តល់ការលើកទឹកចិត្តដល់ការពង្រីកច្រវ៉ាក់ផលិតកម្មដែលមានស្រាប់ និងទាក់ទាញវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យអាទិភាពថ្មីនៅឡើយ ដែលតម្រូវឱ្យមានការគិតគូរឡើងវិញលើរបបលើកទឹកចិត្តពន្ធនេះ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច, បរិយាកាសធុរកិច្ច និងផ្សារភ្ជាប់សហគ្រាសធុនតូចនិងមធ្យមទៅនឹងច្រវ៉ាក់ផលិតកម្មគម្រោងវិនិយោគ ។ ទន្ទឹមនេះ ការផ្តល់ការលើកទឹកចិត្តនៅមានភាពមិនស្មើគ្នា រវាងគម្រោងវិនិយោគបម្រើទីផ្សារនាំចេញ, គម្រោងវិនិយោគក្នុងឧស្សាហកម្មគាំទ្រ និងគម្រោងវិនិយោគបម្រើទីផ្សារក្នុងស្រុក ។ បច្ចុប្បន្ន វត្ថុធាតុដើមនាំចូលសម្រាប់គម្រោងវិនិយោគបម្រើទីផ្សារនាំចេញ ទទួលការលើកទឹកចិត្តដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ ប៉ុន្តែសម្រាប់គម្រោងវិនិយោគបម្រើទីផ្សារក្នុងស្រុក ពុំទទួលបានការលើកទឹកចិត្ត ខណៈដែលទីផ្សារក្នុងស្រុកបច្ចុប្បន្នមានទំហំកាន់តែធំ និងរាជរដ្ឋាភិបាលកំពុងជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុក ។

៥៩. ជាក់ស្តែងក្នុងបរិបទបច្ចុប្បន្ន របបលើកទឹកចិត្តពន្ធរបស់កម្ពុជា មានគោលបំណងមិនច្បាស់លាស់ ដោយវិសាលភាពនៃវិស័យអាទិភាពទូលំទូលាយ, ការកំណត់នៃលក្ខន្តិកៈមួយចំនួននៅមិនទាន់ច្បាស់លាស់, នីតិវិធី និងយន្តការស្នើសុំនិងផ្តល់ការលើកទឹកចិត្តមានភាពស្មុគស្មាញ, កង្វះការត្រួតពិនិត្យទៅលើចំណាយថវិការដ្ឋនៃការលើកលែងពន្ធ, បទប្បញ្ញត្តិនៃការលើកទឹកចិត្តពន្ធមិនស្ថិតក្រោមច្បាប់ស្តីពីសារពើពន្ធ, ជាពិសេសកង្វះការលើកទឹកចិត្តពន្ធសម្រាប់ការពង្រីកទុនវិនិយោគ ឬច្រវ៉ាក់ផលិតកម្ម និងការលើកទឹកចិត្តពន្ធដែលទាក់ទាញឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់ ។

៦០. ដើម្បីកែសម្រួលការលើកទឹកចិត្តពន្ធឱ្យសមស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិបទសេដ្ឋកិច្ចបច្ចុប្បន្នរបស់កម្ពុជា រាជរដ្ឋាភិបាលបានអនុម័តជាគោលការណ៍ឱ្យរៀបចំយកជំពូកស្តីពីការលើកទឹកចិត្តវិនិយោគ ចេញពីច្បាប់

---

[16] របបលើកទឹកចិត្តពន្ធត្រូវបានកែសម្រួលតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ ឆ្នាំ ២០០៣ និងដាក់ចេញឱ្យអនុវត្តតាមរយៈអនុក្រឹត្យលេខ ១១១ អនក្រ.បក ឆ្នាំ ២០០៥ ។

ស្តីពីវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស មកដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ហើយរៀបចំជាអនុក្រឹត្យរបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្ត ដើម្បីផ្តល់ភាពទន់ភ្លន់ក្នុងការផ្លាស់ប្តូរគោលនយោបាយសម្រាប់លើកទឹកចិត្តទៅលើវិស័យអាទិភាពនានា ឱ្យបានឆាប់រហ័ស តាមសេចក្តីត្រូវការចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាតទៅមុខទៀត ។ ក្នុងក្របខ័ណ្ឌនេះ ការកំណត់វិស័យអាទិភាព ដែលត្រូវទទួលបានការលើកទឹកចិត្ត គួរជាកម្មវត្ថុនៃការពិភាក្សាក្នុងចំណោមក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទន្ទឹមនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និងរៀបចំច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសឱ្យបានចប់សព្វគ្រប់នៅចុងឆមាសទី ១ ឆ្នាំ ២០១៩ ។ វិធានការចម្បងៗ ដែលត្រូវតែបញ្ចប់ឱ្យបាន រួមមានដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- បញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និងរៀបចំច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសឱ្យបានចប់សព្វគ្រប់នៅចុងឆមាសទី ១ ឆ្នាំ ២០១៩,
- កំណត់វិស័យអាទិភាព និងរបបលើកទឹកចិត្តពន្ធដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ។

### ៤.៣.៩ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម

៦១. សហគ្រាសធុនតូច និងមធ្យម ជាឆ្អឹងខ្នងសេដ្ឋកិច្ច និងជាកម្លាំងចលករដ៏ខ្លាំងមួយក្នុងការជំរុញកំណើន និងបង្កើតការងារសម្រាប់ប្រជាជន ។ ដោយសារទំហំនៃការវិនិយោគតូច និងភាគច្រើនគឺដើម្បីបម្រើសេចក្តីត្រូវការក្នុងស្រុក សហគ្រាសធុនតូច និងមធ្យម ទាំងនៅកម្ពុជា និងនៅប្រទេសដ៏ទៃទៀតតែងតែជួបប្រទះនូវបញ្ហាជាច្រើន ។ ដោយយល់ច្បាស់អំពីសារៈសំខាន់របស់សហគ្រាសធុនតូច និងមធ្យម រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាកញ្ចប់ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ពង្រឹងភាពប្រកួតប្រជែង និងបង្កើនសមត្ថភាពផលិតកម្ម ។ អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យមក៏ទទួលបាននូវការលើកទឹកចិត្ត ។ វិស័យអាទិភាព ដែលទទួលបាននូវការលើកទឹកចិត្តមានដូចខាងក្រោម÷

១- សហគ្រាសផលិត និងផ្គត់ផ្គង់ទឹកស្អាត,
២- ផលិតកម្មកសិកម្ម ឬកសិ-ឧស្សាហកម្ម,
៣- ផលិតកម្មផលិត និងកែច្នៃម្ហូបអាហារ,
៤- កម្មន្តសាលផលិតទំនិញបម្រើឱ្យការនាំចេញ,
៥- កម្មន្តសាលផលិតទំនិញប្រើប្រាស់ក្នុងស្រុក, កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍,
៦- កម្មន្តសាលផលិតនូវផលិតផលសម្រេច ឬផលិតផលពាក់កណ្តាលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃទៀត,
៧- ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍,

៨- អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម ។

៦២. គោលនយោបាយជាកញ្ចប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ រួមមានដូចខាងក្រោម÷

- អនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១៨ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលនៅក្នុងនេះរួមមាន ការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ ទៅ ៥ ឆ្នាំ, លើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា និងការលើកទឹកចិត្តចំណាយដែលអាចកាត់កងបានពី ១៥០% ទៅ ២០០% ។
- អនុក្រឹត្យលេខ ៥០ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៩ ពីការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលនៅក្នុងនេះរួមមានការលើកលែងពន្ធគយលើសម្ភារបរិក្ខារផលិតកម្ម, សម្ភារ-សាងសង់ និងធាតុចូលផលិតកម្មសម្រាប់សហគ្រាសផលិតនិងផ្គត់ផ្គង់ទឹកស្អាត, សហគ្រាសបម្រើឱ្យការនាំចេញ និងសហគ្រាសជាប្រភេទឧស្សាហកម្មគាំទ្រ ។ សម្រាប់អ្នកអភិវឌ្ឍន៍តំបន់ប្រមូលផ្តុំសហ-គ្រាសធុនតូច និងមធ្យម និងសហគ្រាសបម្រើតម្រូវការក្នុងស្រុកទទួលបានការលើកលែងពន្ធគយតែលើសម្ភារបរិក្ខារផលិតកម្ម និងសម្ភារសាងសង់ ។ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានទទួលបានការលើកលែងពន្ធគយ លើសម្ភារបរិក្ខារសម្រាប់ដំឡើង និងប្រើប្រាស់ក្នុងការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍ ។
- អនុក្រឹត្យលេខ ៥១ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលអត្រាពន្ធគយ, អត្រាអាករពិសេស និងអត្រាអាករនាំចេញ ដើម្បីលើកទឹកចិត្តដល់វិស័យកសិកម្ម, សហគ្រាសធុនតូច និងមធ្យម និងការថែរក្សាបរិស្ថាន ។

៦៣. ក្នុងន័យដើម្បីអនុវត្តអនុក្រឹត្យខាងលើប្រកបដោយប្រសិទ្ធភាព យុទ្ធសាស្ត្រនេះនឹងដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- រៀបចំប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១២៤, ៥១ និង ៥០ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- សិក្សា និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តអនុក្រឹត្យទាំងបីខាងលើ និងស្នើសុំកែសម្រួលក្នុងករណីចាំបាច់ ។

### ៤.៣.១០ ការរៀបចំប្រព័ន្ធសារពើពន្ធ

៦៤. គោលនយោបាយសារពើពន្ធដែលបានរៀបចំខាងលើ គឺភាគច្រើនសម្រាប់តែរយៈពេល ៥ ឆ្នាំ ទៅមុខ ។ សម្រាប់បរិបទកម្ពុជាដែលមានការអភិវឌ្ឍលឿន ជាមួយនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច-សង្គមជាប្រចាំ និង

បំណងប្រាថ្នាសម្រេចឱ្យបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ តម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការគិតគូរគ្រប់ជ្រុងជ្រោយលើទិដ្ឋភាពចំណូល, សេដ្ឋកិច្ច, សង្គម និងបរិស្ថាន ក្នុងរយៈពេលវែង ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រាជរដ្ឋាភិបាលនឹងសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើ-ពន្ធកម្ពុជា ។

## ជំពូកទី៥÷ ការពង្រឹងរដ្ឋបាល និងគោលនយោបាយចំណូលមិនមែនសារពើពន្ធ

៦៥. ដើម្បីឈានដល់ការសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងរបស់យុទ្ធសាស្ត្រនេះ ការប្រមូលចំណូលមិនមែនសារពើពន្ធនឹងបន្តអនុវត្តតាមអភិក្រមសសរស្តម្ភទាំង ៣[17] ដែលកំណត់នៅក្នុងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ព្រមទាំងបន្ថែមការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធក្នុងន័យពង្រឹងការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព ស្របតាមបរិបទនៃសេដ្ឋកិច្ច-សង្គមកម្ពុជា ។ ការងារចម្បងៗដែលត្រូវផ្តោតការយកចិត្តទុកដាក់លើពីរផ្នែកធំៗ រួមមាន÷ (១)ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រង និង (២)ការបញ្ចប់ និងដាក់ឱ្យអនុវត្តនូវវិធានការមុតស្រួចតាមវិស័យនិងប្រភពចំណូលសំខាន់ៗ ។ ជាមួយគ្នានេះ សូចនាករសមិទ្ធកម្មគន្លឹះក៏ត្រូវបានកសាងឡើងដើម្បីផ្តល់ភាពងាយស្រួលក្នុងការវាស់វែង និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត ។

### ៥.១ ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រង

៦៦. បើទោះបីជាមានវឌ្ឍនភាពល្អក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ នារយៈពេល ០៥ ឆ្នាំកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នប្រមូលចំណូលទាំងអស់ត្រូវខិតខំបន្ថែមទៀត ដើម្បីធានាប្រសិទ្ធភាពនៃរដ្ឋបាលចំណូលមិនមែនសារពើពន្ធ ។ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋនៅជួបបញ្ហាប្រឈមដូចជាការកត់ត្រា, ការបង់ចំណូល, ការរៀបចំរបាយការណ៍ និងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលនឹងត្រូវដោះស្រាយតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងពីរ ខាងក្រោម÷

**(១) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)÷** ប្រព័ន្ធនេះបានដាក់ឱ្យអនុវត្តសម្រាប់ក្រសួង-ស្ថាប័នទាំង ២៣ នាពេលកន្លងមក និងត្រូវបន្តកែលម្អ ព្រមទាំងដាក់ឱ្យអនុវត្តវិធានការមួយចំនួន ដូចខាងក្រោម÷

- ពង្រីកប្រព័ន្ធ NRMIS ឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រឹមឆ្នាំ ២០២០,
- រៀបចំផែនការ និងសកម្មភាពជាក់លាក់សម្រាប់បន្តការបណ្តុះបណ្តាលសមត្ថភាពបន្ថែមដល់អ្នកអនុវត្ត,
- បន្តកែលម្អមុខងាររបស់ប្រព័ន្ធ ដូចជាការកត់ត្រា, ការបង់, ការគ្រប់គ្រង, ការរៀបចំរបាយការណ៍ ឱ្យឆ្លើយតបនឹងបញ្ហាប្រឈមជាក់ស្តែងផ្សេងៗគ្នានៅតាមក្រសួង-ស្ថាប័ន,
- បង្កើតមុខងារបង់ប្រាក់តាមប្រព័ន្ធអនឡាញ និងការរៀបចំកម្មវិធីក្នុងទូរស័ព្ទត្រឹមឆ្នាំ ២០២២,
- រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ប្រព័ន្ធ NRMIS រយៈពេលខ្លី និងមធ្យមឱ្យមានមុខងារពេញលេញ ។

**(២) ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ÷** ទោះបីជាមានវឌ្ឍនភាពផ្នែកបច្ចេកទេសក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក៏ប្រព័ន្ធនេះនៅមិនទាន់បានសាកល្បងអនុវត្តឱ្យទូលំទូលាយ

---

[17] សសរស្តម្ភទាំងបីរួមមាន÷ ការពង្រឹងរដ្ឋបាលចំណូល, ការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន និងការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ ។

នៅឡើយ ។ ដើម្បីឱ្យប្រព័ន្ធគ្រប់គ្រងនេះអាចដំណើរការពេញលេញ វិធានការមួយចំនួនត្រូវដាក់ឱ្យអនុវត្ត ដូចខាងក្រោម៖

- អនុវត្តសាកល្បងជាប្រព័ន្ធក្រៅបណ្តាញ (offline system) សម្រាប់ក្រសួង-ស្ថាប័ន, មន្ទីររាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រឹមឆ្នាំ ២០២០,
- រៀបចំកំណត់លេខកូដទ្រព្យសកម្ម, បញ្ចូលទិន្នន័យនៅកម្រិតអនុវត្ត និងរក្សាទុកព័ត៌មានក្រោមប្រព័ន្ធតែមួយ និងដាក់ឱ្យអនុវត្តជាប្រព័ន្ធអនឡាញ (online system) ត្រឹមឆ្នាំ ២០២៣ ។

៦៧. បច្ចុប្បន្ននេះ ទោះបីនីតិវិធីនៃការបង់ចំណូលមិនមែនសារពើពន្ធត្រូវបានកែលម្អជាបន្តបន្ទាប់ក្តី ប៉ុន្តែនៅមិនទាន់សមស្របទៅនឹងសម័យកាលបច្ចេកវិទ្យាទំនើបនៅឡើយ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធ មានដូចជា ការសិក្សាលទ្ធភាពក្នុងការផ្លាស់ប្តូរ/កែសម្រួលនីតិវិធីពីការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ និង/ឬតាមប្រព័ន្ធ e-payment ដើម្បីកាត់បន្ថយការចំណាយលើការបោះពុម្ពបង្កាន់ដៃ, ការរក្សាទុក, ការដឹកជញ្ជូន និងបង្កើនប្រសិទ្ធភាពនៃការបង់ប្រាក់ ។ វិធានការដែលនឹងត្រូវដាក់ចេញ មានដូចជា៖

- សិក្សាស៊ីជម្រៅស្តីពីនីតិវិធីនៃការផ្លាស់ប្តូរការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ ឬជាការប្រើប្រាស់ e-payment ។

## ៥.២ វិធានការតាមវិស័យ និងប្រភពចំណូលសំខាន់ៗ

៦៨. ការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យ និងប្រភពចំណូលសំខាន់ៗ មានការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ យ៉ាងណាមិញ ការប្រមូលចំណូលនេះនៅពុំទាន់ឆ្លុះបញ្ចាំងពីសក្តានុពលជាក់ស្តែង ស្របតាមការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច ដោយសារភាពយឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពលើកិច្ចព្រមព្រៀង, កិច្ចសន្យា និងអាជ្ញាបណ្ណ និងការតាក់តែងច្បាប់ និងបទប្បញ្ញត្តិធំៗ ដូចជាឯកសារគោល (blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ, ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋជាដើម ។ ជាមួយគ្នានេះ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល ការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈតម្រូវឱ្យមានយន្តការស្តង់ដារ និងឈរលើគោលការណ៍សមធម៌ ។ ក្រៅពីនេះ វិស័យ និងប្រភពចំណូលសំខាន់ៗទាំងនេះមានបញ្ហាជាក់លាក់ ដែលចាំបាច់ត្រូវដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

### ក. វិស័យអាកាសចរណ៍ស៊ីវិល

៦៩. វិស័យនេះមានប្រភពចំណូលធំៗពីសេវានាំផ្លូវចុះចត/ហោះហើរ និងហោះឆ្លងកាត់, ចំណូលសួយសារ (royalty), ចំណូលពីព្រលានយន្តហោះ និងចំណូលផ្សេងៗទៀត ។ ចំណូលនេះមានកំណើនជាមធ្យម ១៧,៩% ប្រចាំឆ្នាំ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ និងមានចំណែកជាមធ្យម ៦% នៃចំណូលមិនមែនសារពើពន្ធសរុប ។ វិស័យនេះមាន

បញ្ហាប្រឈមធំមួយគឺមិនទាន់មានការពិនិត្យឡើងវិញ ឬកែសម្រួលកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជា ។

៧០. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- បន្តសិក្សា និងពិនិត្យលទ្ធភាពកែសម្រួលកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាឱ្យឆ្លុះបញ្ចាំងពីកំណើនជើងហោះហើរឡើង/ចុះ និងហោះឆ្លងកាត់ដែនអាកាសកម្ពុជា និងធានាឱ្យបាននូវលក្ខខណ្ឌដែលអំណោយផលដល់ការអភិវឌ្ឍវិស័យនេះ និងកំណើនចំណូលសមស្រប ។

## ខ. វិស័យទេសចរណ៍

៧១. វិស័យទេសចរណ៍កម្ពុជាមានឧត្តមភាពប្រកួតប្រជែងខ្ពស់ និងជាវិស័យសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងជាប្រភពចំណូលមានសក្តានុពល ។ ចំណូលពីវិស័យទេសចរណ៍ មានកំណើនជាមធ្យម ២៦,១% ក្នុងមួយឆ្នាំ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ដែលជាលទ្ធផលពីការរៀបចំឱ្យមានគ្រឹះស្ថានអង្គរ និងការដំឡើងថ្លៃសំបុត្រចូលទស្សនាតំបន់អង្គរ ក៏ដូចជាការកែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាល ។ ការប្រមូលចំណូលពីវិស័យនេះនៅជួបបញ្ហាប្រឈម ដូចជា÷ (១)ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារនៅមានកម្រិតទាប, (២)ការបែងចែកតួនាទីក្នុងការគ្រប់គ្រងរមណីយដ្ឋានមួយចំនួននៅមានភាពប្រទាំងប្រទើស, (៣)កិច្ចសហការរបស់ម្ចាស់អាជីវកម្មក្នុងការចាត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍នៅមានកម្រិត និង (៤)តំបន់ទេសចរណ៍សក្តានុពលមួយចំនួននៅមិនទាន់ទទួលបានការអភិវឌ្ឍ និងប្រមូលចំណូលឱ្យអស់ពីលទ្ធភាព ។

៧២. ដើម្បីដោះស្រាយបញ្ហាខាងលើ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារ,
- សិក្សាកែតម្រូវប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់ការធ្វើអាជីវកម្ម និងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ,
- រៀបចំបែងចែកតួនាទីគ្រប់គ្រងរមណីយដ្ឋានឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធ,
- បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- សិក្សា និងពិនិត្យលទ្ធភាពអភិវឌ្ឍន៍រមណីយដ្ឋានដែលមានសក្តានុពល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងប្រមូលចំណូលឱ្យអស់លទ្ធភាព ។

### គ. ចំណូលពីអាករស្ថានទូត

៧៣. ចំណូលពីអាករស្ថានទូតត្រូវបានប្រមូលដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ ដែលរួមចំណែកជាមធ្យមប្រមាណ ២៣% នៃចំណូលមិនមែនសារពើពន្ធសរុប និងមានកំណើនជាមធ្យម ២១,១% ក្នុងមួយឆ្នាំ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ ឆ្លើយតបនឹងកំណើនឥតឈប់ឈរនៃចំនួនភ្ញៀវទេសចរមកកម្ពុជា និងកំណើនតម្រូវការលិខិតឆ្លងដែនរបស់ប្រជាពលរដ្ឋ ចំណូលនេះរំពឹងថានឹងបន្តកើនឡើង និងបន្តមានសក្តានុពលនាពេលអនាគត ។ ប៉ុន្តែបញ្ហាប្រឈមមួយចំនួនដែលនៅតែកើតមានឡើង ដូចជា÷ (១)ប្រព័ន្ធរបាយ-ការណ៍ស្តីពីចំណូលរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និង (២)កម្រៃទិដ្ឋាការសម្រាប់ជនអន្តោប្រវេសន៍ចេញ-ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់បានវាយតម្លៃគ្រប់ជ្រុងជ្រោយ លើទិដ្ឋភាពចំណូល និងតម្រូវការសេដ្ឋកិច្ច ។

៧៤. ដើម្បីដោះស្រាយបញ្ហាខាងលើនេះ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការដូចខាងក្រោម÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពង្រឹងការរៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថាន-ភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ផ្អែកលើនីតិវិធីនៃការកត់ត្រា និងតាមដានសន្និធិ តាមវិធីសាស្ត្រឃ្លាំងសន្និធិ (stock inventory) នៅគ្រប់ចំណុចគោលដៅ ដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចររួមមាន ច្រកអន្តរជាតិ, ស្ថានទូត, ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស,
- សិក្សាលទ្ធភាពកែសម្រួលកម្រៃទិដ្ឋាការសម្រាប់ជនអន្តោប្រវេសន៍ចេញ-ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ឃ. វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍

៧៥. វិស័យទូរគមនាគមន៍ជាវិស័យមួយមានសក្តានុពលខ្លាំង ប៉ុន្តែកំណើនចំណូលពីវិស័យនេះ នៅមិនទាន់ឆ្លុះបញ្ចាំងពីការរីកចម្រើនសេដ្ឋកិច្ច ។ វឌ្ឍនភាពនៃការងារកែទម្រង់កន្លងមកមាន ដូចជា÷ ការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីទូរគមនាគមន៍, ការធ្វើបច្ចុប្បន្នភាពអាជ្ញាបណ្ណ, ការរៀបចំស្ថាប័នគ្រប់គ្រងនិងចេញអាជ្ញាបណ្ណ និងការគណនាកម្រៃកាន់តែច្បាស់លាស់សម្រាប់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ។ ប៉ុន្តែការប្រមូលចំណូលពីវិស័យនេះនៅជួបប្រទះបញ្ហាប្រឈម ដូចជា÷ (១)ទិន្នន័យដែលផលិតបានពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) មិនទាន់ប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងប្រមូលចំណូលពន្ធ និងមិនមែនពន្ធ, (២)ការគ្រប់គ្រង និងប្រមូលចំណូលពីវិសាលគមន៍ប្រេកង់វិទ្យុ (radio frequency spectrum) ដែលជាធនធានកម្មសិទ្ធិរបស់ជាតិ ក៏ដូចជាចំណូលផ្សេងៗទៀតនៅមិនទាន់អស់លទ្ធភាព និងមានប្រសិទ្ធភាពនៅឡើយ, (៣)ការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍នៅមិនទាន់

ពេញលេញ និងការរៀបចំនូវបទប្បញ្ញត្តិគាំទ្រផ្សេងទៀតមិនទាន់បានបញ្ចប់, (៤)ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ដែលបានដាក់អនុវត្តនៅឆ្នាំ ២០០២ នៅមិនទាន់ឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃវិស័យប្រៃសណីយ៍ ។

៧៦. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ជំរុញការប្រើប្រាស់ប្រកាសរួមស្តីពីការដាក់ឱ្យអនុវត្តទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ឱ្យមានប្រសិទ្ធភាព ដើម្បីជាមូលដ្ឋានក្នុងការប្រមូលចំណូលពន្ធ និងមិនមែនពន្ធ,
- គ្រប់គ្រង និងប្រមូលចំណូលពីវិសាលគមន៍ហ្វ្រេកង់វិទ្យុ (radio frequency spectrum) ដែលជាធនធានកម្រូបស់ជាតិ និងចំណូលផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ តាមរយៈការដកហូតអាជ្ញាបណ្ណហ្វ្រេកង់ទំនេរដែលមិនបានប្រើប្រាស់ ព្រមទាំងការដាក់ឱ្យដេញថ្លៃ (auction) ហ្វ្រេកង់ទំនេរនិងមានតម្រូវការ,
- អនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ឱ្យបានពេញលេញ និងពន្លឿនបញ្ចប់បទប្បញ្ញត្តិគាំទ្រ ព្រមទាំងពង្រឹងការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់នៅក្នុងវិស័យនេះ,
- ធ្វើវិសោធនកម្មច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។

### ខ. ដីសម្បទានសេដ្ឋកិច្ច

៧៧. កន្លងមក ការគ្រប់គ្រង និងការអភិវឌ្ឍលើដីសម្បទានសេដ្ឋកិច្ចនៅជួបប្រទះបញ្ហាស្មុគស្មាញច្រើន ។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍រៀបចំឡើងវិញនូវកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រង និងដោះស្រាយបញ្ហាជម្លោះនិងផលប៉ះពាល់នានា ប៉ុន្តែការអនុវត្តនូវគោលការណ៍នេះមានភាពយឺតយ៉ាវ ដោយសារនីតិវិធីច្រើន និងកិច្ចសម្របសម្រួលអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានបាត់បង់ចំណូលពីការផ្ទេរឬការលក់គម្រោងដីសម្បទានសេដ្ឋកិច្ចក្រោមរូបភាពជាការផ្ទេរភាគហ៊ុន ឬផ្លាស់ប្តូរឈ្មោះម្ចាស់ក្រុមហ៊ុន ។

៧៨. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យា ឬកិច្ចសន្យាកែសម្រួល ពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាឱ្យបានម៉ឺងម៉ាត់,
- រៀបចំយន្តការគ្រប់គ្រងការផ្ទេរឬលក់ដីសម្បទានសេដ្ឋកិច្ច ក្រោមរូបភាពជាការផ្ទេរភាគហ៊ុន ឬផ្លាស់ប្តូរឈ្មោះម្ចាស់ក្រុមហ៊ុន ដើម្បីបង្កើនការប្រមូលចំណូលឱ្យអស់លទ្ធភាព,

- ពិនិត្យឡើងវិញលើថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច និងពិនិត្យបែងចែកចំណូលពីដីសម្បទានសេដ្ឋកិច្ចទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ,
- ការផ្លាស់ប្ដូរការបង់ចំណូលដីសម្បទានសេដ្ឋកិច្ចពីការបង់ចំណូលតាមទំហំផ្ទៃដីអនុញ្ញាតឈូសឆាយមកជាការបង់ចំណូលតាមទំហំផ្ទៃដីផ្ដល់ជូនដែលមានចែងក្នុងកិច្ចសន្យាសម្បទាន អនុវត្តតាមគោល-ការណ៍ឯកភាពពីរាជរដ្ឋាភិបាល ។

### ច. ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍

៧៩. រាជរដ្ឋាភិបាលបានជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានមួយចំនួនឱ្យក្រុមហ៊ុនឯកជន ដើម្បីធ្វើការវិនិយោគ និងអភិវឌ្ឍជាតំបន់ទេសចរណ៍ ដែលទាមទារឱ្យមានការបង់ជាប្រាក់កក់, ថ្លៃឈ្នួល និងលក្ខខណ្ឌផ្សេងៗទៀត ។ ការប្រមូលចំណូលពីការជួលនេះ នៅមានបញ្ហាប្រឈមដូចជា÷ (១)ក្រុមហ៊ុនមួយចំនួនពន្យារពេលក្នុងការអភិវឌ្ឍតំបន់ទេសចរណ៍បន្ទាប់ពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល, (២)ចំណូលពីការផ្ទេរកិច្ចសន្យាជួលនៅមិនទាន់អាចប្រមូលបាន និង (៣)ការបង់ប្រាក់ឈ្នួលនៅមានភាពយឺតយ៉ាវ ។

៨០. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្ដីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ,
- សិក្សាលទ្ធភាពកែសម្រួលថ្លៃជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យស្របតាមថ្លៃទីផ្សារជាក់ស្ដែង និង ការផ្ដល់រយៈពេលអនុគ្រោះលើការបង់ថ្លៃឈ្នួល ដោយភ្ជាប់លក្ខខណ្ឌជាមួយនឹងវឌ្ឍនភាពនៃការអនុវត្តគម្រោង/កិច្ចសន្យា,
- អនុវត្តការបង់កម្រៃចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន ។

### ឆ. សហគ្រាសសាធារណៈ

៨១. សហគ្រាសសាធារណៈ ជាស្ថាប័នដែលមានស្វ័យភាពហិរញ្ញវត្ថុក្នុងការចាត់ចែង និងប្រើប្រាស់ធនធានរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាមី និងអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប៉ុន្តែសហគ្រាសទាំងនេះនៅស្ថិតក្រោមក្របខ័ណ្ឌគតិ-យុត្តចាស់ តាំងពីឆ្នាំ ១៩៩៦ ដែលកាតព្វកិច្ចអនុលោមភាពចំពោះរដ្ឋ នៅមិនទាន់បានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន ។

៨២. ដើម្បីដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលត្រូវរៀបចំក្របខ័ណ្ឌគតិយុត្តថ្មីឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ ។

## ជ. គ្រឹះស្ថានសាធារណៈរដ្ឋបាល

៨៣. ការកែទម្រង់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ផ្តោតសំខាន់លើការគ្រប់គ្រងប្រកបដោយតម្លាភាព, គណនេយ្យភាព និងសមធម៌ ដើម្បីពង្រីកសេវាសាធារណៈប្រកបដោយគុណភាព ព្រមទាំងអាចគ្រប់គ្រងបាននូវហានិភ័យ និងកាត់បន្ថយបន្ទុកចំណាយថវិការដ្ឋ ។ កន្លងមក ច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលរួមទាំងបទប្បញ្ញត្តិគាំទ្រផ្សេងៗត្រូវបានរៀបចំ ប៉ុន្តែការអនុវត្តនៅមិនទាន់រលូនដោយសារសមត្ថភាពមន្ត្រី និងការយល់ដឹងពីនីតិវិធីថ្មីនៅមានកម្រិត ។

៨៤. ដើម្បីដោះស្រាយបញ្ហាខាងលើ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវអនុវត្តតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី ឱ្យបានពេញលេញ ដើម្បីធានាតម្លាភាពនៃប្រតិបត្តិការរបស់គ្រឹះស្ថាន ។

## ឈ. វិស័យរ៉ែ និងថាមពល

៨៥. វិស័យរ៉ែនិងថាមពល ជាវិស័យមានសក្តានុពលមួយនាពេលអនាគត និងអាចជាប្រភពចំណូលបន្ថែមដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ។ កន្លងមក ការប្រមូលចំណូលពីវិស័យរ៉ែ និងថាមពល មានកំណើនជាមធ្យម ៤១,១% ក្នុងមួយឆ្នាំពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ ទោះបី រាជរដ្ឋាភិបាលដាក់អនុវត្តបទប្បញ្ញត្តិមួយចំនួនដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងលើវិស័យនេះ ការប្រមូលចំណូលនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជា÷ (១)កាតព្វកិច្ចហិរញ្ញវត្ថុដែលមាននៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន នៅមិនទាន់សមស្របនឹងការវិវឌ្ឍសេដ្ឋកិច្ច, (២)ប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ សម្រាប់រដ្ឋនៅមានកម្រិត, (៣)កង្វះប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល, និង (៤)កង្វះមន្ត្រីក្នុងការចុះកៀរគរចំណូលឱ្យមានប្រសិទ្ធភាព ។

៨៦. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- សិក្សា និងធ្វើបច្ចុប្បន្នភាព កាតព្វកិច្ចហិរញ្ញវត្ថុនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ឱ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងផ្តល់ផលប្រយោជន៍ជូនភាគីរាជរដ្ឋាភិបាល,
- ពង្រឹងប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ,
- បន្តអនុវត្តលើការបង់ចំណូលពីវិស័យធនធានរ៉ែ ដោយតម្រូវឱ្យសម្បទានិកធ្វើការបង់ចំណូលដែលគ្រោងជាមុន ដោយផ្អែកលើផែនការផលិតកម្ម និងមធ្យោបាយផលិតកម្ម,

- រៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល,
- រៀបចំលិខិតបទដ្ឋាន ដើម្បីកំណត់ឱ្យក្រុមហ៊ុនអាជីវកម្មរ៉ែមានប្រធានការដ្ឋានដែលមានជំនាញច្បាស់លាស់នៅគ្រប់ការដ្ឋានរ៉ែ ។

## ញ. ចំណូលពីសកម្មភាពល្បែង

៨៧. ចំណូលពីសកម្មភាពល្បែងរួមមានចំណូលពីកាស៊ីណូ និងចំណូលពីអាជីវកម្មល្បែងផ្សងសំណាង ដែលចំណូលនេះមានចំណែកប្រមាណ ៧% នៃចំណូលមិនមែនសារពើពន្ធសរុបក្នុងឆ្នាំ ២០១៨ និងមានកំណើនជាមធ្យម ១៣,៤% ក្នុងមួយឆ្នាំ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ វិស័យនេះមានការលូតលាស់ខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែការគ្រប់គ្រងបច្ចុប្បន្ននៅជួបប្រទះបញ្ហាមួយចំនួនដូចជា÷ (១)ច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មនៅមិនទាន់អនុម័ត ដែលនាំឱ្យខ្វះមូលដ្ឋានគតិយុត្តគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រង និង (២) សកម្មភាពល្បែងខុសច្បាប់នៅបន្តកើតមាន ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។

៨៨. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពន្លឿនការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម,
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់,
- បន្តខិតខំកៀរគរចំណូលឱ្យអស់ពីលទ្ធភាពពីសកម្មភាពល្បែងគ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលតាមបទប្បញ្ញត្តិជាធរមាន ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម ។

## ដ. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ

៨៩. ចំណូលពីទ្រព្យសម្បត្តិរដ្ឋមានប្រភពពីការជួលទ្រព្យសម្បត្តិរដ្ឋ និងសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ កន្លងមកការប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ មានបញ្ហាប្រឈម ដូចជា÷ (១) លក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋមួយចំនួន មិនទាន់ឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន និង (២) ការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ (ដូចជាភាស៊ីផ្សារ, ចំណតរថយន្ត និងសម្បទានដទៃទៀត) នៅមិនទាន់មានប្រសិទ្ធភាព ។

៩០. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន,
- ពង្រឹងយន្តការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធានាការអភិវឌ្ឍ និងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- សិក្សា និងពិនិត្យលទ្ធភាពបង្កើតតំបន់អចលនវត្ថុរបស់រដ្ឋ ឱ្យស្របទៅតាមផែនការមេនៃការរៀបចំទីក្រុង (urban development master plan),
- សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍ ស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈ,
- សហការជាមួយក្រសួងទទួលបន្ទុក និងអាជ្ញាធរដែនដីចុះពិនិត្យផ្ទាល់ការអនុវត្ត និងផ្ទៀងផ្ទាត់លើការបង់ចំណូលពីការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចជាការចាក់ដីបំពេញបឹង, ឆ្នេរ, ទន្លេ និងការយកដីសាធារណៈរបស់រដ្ឋដទៃទៀត ដើម្បីផលប្រយោជន៍ឯកជន ហើយត្រូវអនុវត្តតាមច្បាប់ និងនីតិវិធីជាធរមាន ព្រមទាំងបង់ចំណូលចូលថវិការដ្ឋតាមតម្លៃទីផ្សារជាក់ស្តែង ។

## ៥. ចំណូលពីការចាត់ចែងវត្ថុតាងរឹបអូសពីបទល្មើស

៩១. កន្លងមក វត្ថុតាងពីបទល្មើសផ្សេងៗ ត្រូវបានរក្សាទុករង់ចាំដំណើរការតាមនីតិវិធីតុលាការចប់ជាស្ថាពរ ដែលត្រូវចំណាយពេលវេលាយូរ ហើយបានធ្វើឱ្យវត្ថុតាងមួយចំនួនធំខូចខាត, បាត់បង់តម្លៃ និងជួបបញ្ហាខ្វះខាតទីកន្លែងរក្សាទុក ព្រមទាំងថែមខ្ទង់ចំណាយថែរក្សាទ្រព្យសម្បត្តិទាំងនោះផងដែរ ។ បញ្ហាប្រឈមទាំងនេះ នៅមិនទាន់មានយន្តការជាក់លាក់ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ដើម្បីចាត់ចែង និងប្រមូលទ្រព្យទាំងអស់នោះបង់ចូលថវិការដ្ឋនៅឡើយទេ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ រួមមាន÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពន្លឿនការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិរឹបអូសពីបទល្មើសនានា និងបង់ចំណូលចូលថវិការដ្ឋ ស្របតាមនីតិវិធីជាធរមាន មុនមានសាលក្រម/ សាលដីកាស្ថាពរ ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូស ។

## ជំពូកទី៦÷ ការត្រួតពិនិត្យ និងវាយតម្លៃ

៩២. ការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ទាមទារឱ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់មួយ ព្រមទាំងមានឆន្ទៈនយោបាយមោះមុត និងធនធានគ្រប់គ្រាន់ ដើម្បីតាមដានលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រនេះជាប្រចាំ ។

៩៣. ការត្រួតពិនិត្យ និងវាយតម្លៃយុទ្ធសាស្ត្រនេះ នឹងប្រើប្រាស់យន្តការដែលមានស្រាប់គឺ÷(១)គណៈកម្មាធិការគោលនយោបាយសារពើពន្ធ, (២)គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និង (៣)គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ។

៩៤. គណៈកម្មាធិការគោលនយោបាយសារពើពន្ធ មានតួនាទី និងមុខងារត្រួតពិនិត្យ និងតាមដានលើការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះ ព្រមទាំងសម្របសម្រួល, ពិនិត្យ និងលើកសំណើកែសម្រួលគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍សមធម៌, សាមញ្ញភាព, តម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព ។

៩៥. គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ មានតួនាទីតាមដានការអនុវត្ត, ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ពាក់ព័ន្ធការប្រមូលចំណូលសារពើពន្ធ ព្រមទាំងជំរុញ និងផ្តល់ការណែនាំលើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលសារពើពន្ធឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលវេលា ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ។

៩៦. គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ មានតួនាទីតាមដានការអនុវត្ត, ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ ព្រមទាំងជំរុញ និងផ្តល់ការណែនាំដល់ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ លើការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅ និងទាន់ពេលវេលា ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ។

៩៧. អគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីជាលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ ដែលនឹងរៀបចំក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃលម្អិត ដើម្បីធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការ និងសូចនាករសមិទ្ធកម្មគន្លឹះទាំងអស់ដែលបានដាក់ចេញ ព្រមទាំងរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំដាក់ជូនគណៈកម្មាធិការទាំង ៣ ។

៩៨. សូចនាករសមិទ្ធកម្មគន្លឹះរបស់វិធានការគោលនយោបាយសំខាន់ៗ ក៏ដូចជាសូចនាករសមិទ្ធកម្មគន្លឹះនៃវិធានការទំនើបភាវូបនីយកម្មរបស់រដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ខណៈដែល បន្ទាត់មូលដ្ឋាន និងគោលដៅនៃសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួនទៀត នឹងរៀបចំក្នុងក្របខ័ណ្ឌនិងដំណើរការត្រួតពិនិត្យ និងវាយតម្លៃលម្អិត ។

៩៩. ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រាល់ការស្នើសុំការផ្លាស់ប្តូរគោលនយោបាយសារពើ-ពន្ធត្រូវមានការពិភាក្សាកម្រិតបច្ចេកទេសជាមួយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍ និងអនុសាសន៍ជូនគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ។

១០០. ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការអនុវត្តវិធានការនានាដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះត្រូវរៀបចំ និងផ្តល់របាយការណ៍វឌ្ឍនភាព មកលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ រៀងរាល់ឆមាស ឬទៅតាមការស្នើសុំរបស់លេខាធិការដ្ឋាន ដើម្បីរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារជូនគណៈកម្មាធិការទាំង ៣ បានទាន់ពេលវេលា ។ របាយការណ៍វឌ្ឍនភាពប្រចាំឆមាសត្រូវផ្ញើជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការទាំង ៣ យ៉ាងយូរត្រឹមដំណាច់ខែបន្ទាប់ ។

## ជំពូកទី៧÷ សេចក្តីសន្និដ្ឋាន

១០១. **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** នឹងក្លាយជាឧបករណ៍គោលនយោបាយក្នុងការកៀរគរចំណូលក្នុងស្រុក ដើម្បីគាំទ្រកិច្ចការកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នៅក្នុង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា** និង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាល ទី ៤** ដើម្បីធានានូវការសម្រេចបាននូវ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងពង្រឹងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរយៈពេលមធ្យម និងវែងរបស់កម្ពុជា ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងមានធនធានកាន់តែច្រើនក្នុងការអនុវត្តនូវគោលនយោបាយនានា សំដៅរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបចីរភាព, បង្កើតការងារជូនប្រជាជន តាមរយៈការកែលម្អបរិយាកាសវិនិយោគ និងការលើកកម្ពស់ការអភិវឌ្ឍវិស័យឯកជន, បន្តកាត់បន្ថយភាពក្រីក្រ, បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ និងធានាសមធម៌សង្គម ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែង និងបរិការណ៍ថ្មីរបស់កម្ពុជា ព្រមទាំងបន្តរក្សាបាននូវឯករាជ្យភាពនៃថវិកាជាតិ និងសេដ្ឋកិច្ច ។

១០២. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩ - ២០២៣ ទាមទារឱ្យមានឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តខ្ពស់ ព្រមទាំងការចូលរួមយ៉ាងសស្រាក់សស្រាំពីគ្រប់ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជន ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាក្នុងគោលដៅសម្រេចបានចក្ខុវិស័យ, គោលបំណង, គោលដៅ និងសូចនាករសមិទ្ធកម្មគន្លឹះដែលបានកំណត់ ។ ទន្ទឹមនេះ ការអនុវត្តវិធានការដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រនេះទាមទារឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថក្នុងការបំពេញកាតព្វកិច្ចបម្រើជាតិ ដោយត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" ។

## ឧបសម្ព័ន្ធ ១. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានពន្ធដារ

### ក .សូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវរាយការណ៍ជាប្រចាំ

| គោលបំណង | សូចនាករសមិទ្ធកម្មគន្លឹះ | រង្វាស់ | បន្ទាត់មូលដ្ឋាន ២០១៨ | គោលដៅប្រចាំឆ្នាំ | | | | |
|---|---|---|---|---|---|---|---|---|
| | | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| សេវាកម្ម និង អនុលោមភាព | ១ រយៈពេលមធ្យមនៃការបង្វិលសងអាករលើតម្លៃបន្ថែម ត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ | ចំនួនថ្ងៃធ្វើការ | ១២០ | ៣៧ | ៣៥ | ៣៣ | ៣១ | ៣០ |
| | ២ រយៈពេលមធ្យមនៃការបញ្ចប់សវនកម្មមានកម្រិត | ចំនួនថ្ងៃធ្វើការ | ៣៥ | ៣៣ | ៣០ | ២៨ | ២៥ | ២០ |
| | ៣ រយៈពេលមធ្យមនៃការបញ្ចប់សវនកម្មពេញលេញ | ចំនួនថ្ងៃធ្វើការ | ៣០ | ៣០ | ២៨ | ២៥ | ២៣ | ២០ |
| | ៤ អត្រាប្រកាសពន្ធទាន់ពេលវេលា | % នៃអ្នកជាប់ពន្ធពន្ធធំ និងមធ្យម | ៦៨% | កើនឡើង ២%រៀងរាល់ឆ្នាំ | | | | |
| | ៥ អត្រាបង់ពន្ធទាន់ពេលវេលា | % នៃអ្នកជាប់ពន្ធពន្ធធំ និងមធ្យម | ៧០% | កើនឡើង ២%រៀងរាល់ឆ្នាំ | | | | |

## ២ .សូចនាករសមិទ្ធកម្មគន្លឹះកម្រិតប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលត្រូវរាយការណ៍ជាប្រចាំ

| វិធានការទំនើបភាវូបនីយកម្មនៃអគ្គនាយកដ្ឋានពន្ធដារ | សូចនាករសមិទ្ធកម្មគន្លឹះ | មូលដ្ឋាន ២០១៨ | គោលដៅ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
| យោងតាមគោលបំណង និងគោលដៅដូចដែលបានរៀបរាប់ខាងលើ រាជរដ្ឋាភិបាលនឹងធ្វើការវាយតម្លៃសមិទ្ធកម្មការងារលើវិធានការដែលបានដាក់ចេញ តាមរយៈសូចនាករសមិទ្ធកម្មគន្លឹះដូចខាងក្រោម÷ | | | | | | | |
| **ក. ក្របខ័ណ្ឌស្ថាប័ន និងអភិបាលកិច្ច** | | | | | | | |
| • ដាក់ឱ្យអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតប្រតិបត្តិ-ការ ដើម្បីផ្តល់ភាពងាយស្រួលដល់ថ្នាក់ដឹកនាំ និងប្រធានអង្គភាពក្នុងការគ្រប់គ្រងជាយុទ្ធសាស្ត្រ និងវាយតម្លៃសមិទ្ធកម្ម (outcome) | របាយការណ៍ស្តីពីការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះកម្រិតប្រតិបត្តិការ និងកម្រិតយុទ្ធសាស្ត្រ | គ្មាន | រៀងរាល់ឆមាស | | | | |
| • រៀបចំផែនការពង្រឹងសមត្ថភាព, ការធ្វើវិមជ្ឈការមុខងារ និងការទទួលខុសត្រូវ ដល់សាខាខេត្ត-ខណ្ឌ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តមុខងារស្នូល | ផែនការពង្រឹងសមត្ថភាព, ការធ្វើវិមជ្ឈការមុខងារ និងការទទួលខុសត្រូវដល់សាខាខេត្ត-ខណ្ឌ ត្រូវបានរៀបចំ | គ្មាន | | √ | | | |
| • ផ្តល់សិទ្ធិអំណាច និងពង្រឹងប្រសិទ្ធភាពសវនកម្មផ្ទៃក្នុង ដើម្បីធានាតម្លាភាព និងគណនេយ្យភាព អភិបាលកិច្ចផ្ទៃក្នុង | ចំនួនអង្គភាពដែលមានប្រើប្រាស់នីតិវិធីប្រតិបត្តិការស្តង់ដារ (standard operational procedure) | ១ | កើនយ៉ាងតិច ១ ក្នុងមួយឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • ពង្រឹង និងពង្រីកការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅដល់គ្រប់នាយកដ្ឋាន និងសាខាខេត្ត-ខណ្ឌ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពប្រតិបត្តិការប្រចាំថ្ងៃ | ចំនួនការិយាល័យក្នុង អ.ព.ដ. ដែលប្រើប្រាស់ប្រព័ន្ធចែករំលែកទិន្នន័យបែបអេឡិចត្រូនិក (real-time data sharing system) | គ្រប់ការិ-យាល័យទាំងអស់ | √ | | | | |
| • ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាពការងារ<br>• ពង្រឹងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូល និងចែករំលែកទិន្នន័យ និងព័ត៌មាន | ប្រព័ន្ធចែករំលែកទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក-ដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានគោលនយោបាយត្រូវបានតភ្ជាប់ | គ្មាន | | √ | | | |
| • ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យប្រភពចំណូល ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច (business cycle) | ឯកសារវិភាគហានិភ័យទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ | សេចក្តីព្រាងឯកសារ | √ | √ | √ | √ | √ |
| • កសាង និងអនុវត្តប្រព័ន្ធត្រួតពិនិត្យដំណើរការប្រតិបត្តិការស្វ័យទាន់ពេលវេលា ដើម្បីពង្រឹងប្រសិទ្ធភាពតាមដានវឌ្ឍនភាពស្ទួចនាករសមិទ្ធកម្មគន្លឹះ | ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដំណើរការប្រតិបត្តិ-ការស្វ័យទាន់ពេលវេលាត្រូវបានដាក់ឱ្យដំណើរការ | គ្មាន | | | √ | √ | √ |
| **ខ. មុខងារប្រតិបត្តិការស្នូល** | | | | | | | |
| • ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់នូវ(១) ប្រព័ន្ធ អនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃ | ភាគរយនៃករណីបង្វិលសងដោយជោគជ័យក្នុងការទទួលបានការបង្វិលសងអាករលើតម្លៃបន្ថែម | គ្មាន | កើនឡើងជារៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បន្ថែម និង(២) ប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩, | របាយការណ៍វឌ្ឍនភាពនៃការអនុវត្តប្រកាសស្តីពីសវនកម្មពន្ធដារ លេខ ២៧០ សហវ. ប្រក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៩ (ដោយបញ្ជាក់ពីសមិទ្ធផលការងារដែលឆ្លើយតបនឹងគោលបំណងនៃប្រកាសនេះ) | គ្មាន | របាយការណ៍វឌ្ឍនភាពជារៀងរាល់ឆ្នាំ | | | | |
| • រៀបចំ និងអនុវត្តផែនការរៀបចំឡើងវិញនូវដំណើរការការងារ (business process re-engineering) និងផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័ន (organizational change management) ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយរលូន | ឯកសារស្តីពីដំណើរការការងារនៃមុខងារស្នូល និងមុខងារគាំទ្រនីមួយៗ ទាំងមុន និងក្រោយប្រើ-ប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ | គ្មាន | | √ | | | |
| | ផែនការគ្រប់គ្រងការផ្លាស់ប្តូរស្ថាប័នត្រូវបានដាក់ឱ្យអនុវត្ត | គ្មាន | | √ | | | |
| • ធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តផែនការ និងនីតិវិធីសវនកម្មរួម ដើម្បីដោះស្រាយបញ្ហាការធ្វើសវនកម្មច្រើនដង, អសង្គតិភាពនៃការអនុវត្តនីតិវិធីសវនកម្ម និងការកាត់បន្ថយនូវបន្ទុកការងាររបស់សវនករ<br>• ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការវិភាគទិន្នន័យ ដើម្បីបង្កើន សមត្ថភាពធ្វើសវនកម្មសំដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ | ភាគរយនៃសហគ្រាសដែលត្រូវបានធ្វើសវនកម្មធៀបនឹងផែនការសវនកម្ម | ៥០% | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសស្នើសុំបិទអាជីវកម្មដែលត្រូវបានធ្វើសវនកម្ម | ៣៥% | កើនឡើង ៣% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសស្នើសុំជម្រះបញ្ជីពន្ធដែលត្រូវបានធ្វើសវនកម្ម | ៦០% | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • ពង្រឹងការធ្វើសវនកម្មដោយផ្អែកលើហានិភ័យ (risk-based audit) | ចំនួនករណីសវនកម្មជាមធ្យមក្នុងសវនករម្នាក់ក្នុងមួយឆ្នាំ | ១១ | មិនលើស ១២ | | | | |
| | រយៈពេលមធ្យមនៃសវនកម្មពេញលេញអ្នកជាប់ពន្ធមធ្យម/ ធំ | ៣៥ ថ្ងៃ | ៣៥ | ៣០ | ៣០ | ២៥ | ២០ |
| | រយៈពេលមធ្យមនៃសវនកម្មមានកម្រិតអ្នកជាប់ពន្ធមធ្យម/ ធំ | ៣០ ថ្ងៃ | ៣០ | ៣០ | ២៥ | ២៥ | ២០ |
| | ភាគរយជាមធ្យមនៃករណីកំណត់ពន្ធឡើងវិញដែលត្រូវបានប្តឹងតវ៉ា ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីអ្នកជាប់ពន្ធទទួលលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ | ៣០% | | | | | |
| | ចំនួនករណីស៊ើបអង្កេតដែលបានបញ្ចប់ | ២៥ | ៤០ | កើនឡើង ៥% រៀងរាល់ឆ្នាំ | | | |
| | រយៈពេលមធ្យមនៃការបញ្ចប់ការស៊ើបអង្កេត | ១២ខែ | ១២ | ១២ | ១១ | ១០ | ១០ |
| • រៀបចំ និងអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់អនុលោមភាពស្ម័គ្រចិត្ត ដែលមាន លក្ខណៈនវានុវត្តន៍ និងគ្រប់ជ្រុងជ្រោយ ជាពិសេសការពង្រឹងគុណភាពសេវា និងការអប់រំអ្នកជាប់ពន្ធ | រយៈពេលមធ្យមនៃការបង្វិលសងអាករលើតម្លៃបន្ថែមត្រឹមកម្រិតអគ្គនាយកដ្ឋានពន្ធដារ | ១២០ | ៣៧ | ៣៥ | ៣៣ | ៣១ | ៣០ |
| | លទ្ធផលនៃការស្ទង់មតិស្តីពីការពេញចិត្តចំពោះការផ្តល់សេវាដល់អ្នកជាប់ពន្ធរៀងរាល់ ០២ឆ្នាំម្តង | គ្មាន | | √ | | √ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | រយៈពេលដែលអ្នកជាប់ពន្ធរង់ចាំក្នុងការទទួលបានការពិគ្រោះយោបល់ និងឆ្លើយបំភ្លឺពី អពដ (លាយលក្ខណ៍អក្សរ, call centre, live chat, SMS, បញ្ចូរពិគ្រោះយោបល់ និងប្រអប់ទទួលមតិយោបល់) | ៣០ថ្ងៃ សម្រាប់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ | ៣០ | ២៩ | ២៨ | ២៧ | ២៥ |
| • អនុវត្តការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (e-registration), ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-filing), និងការបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) ដែលមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា, | ភាគរយនៃសហគ្រាស ដែលត្រូវចុះបញ្ជីតាមលទ្ធផលអង្កេតសហគ្រាស | ២០% | ឱ្យបាន ២០% ក្នុងមួយឆ្នាំ ធៀបនឹងលទ្ធផលអង្កេត | | | | |
| | ភាគរយនៃក្រុមហ៊ុនចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក | គ្មាន | កើនឡើង ២% ក្នុងមួយឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបានធ្វើបច្ចុប្បន្នភាពដោយជោគជ័យ ធៀបជាមួយចំនួនសហគ្រាសដែលបានស្នើសុំក្នុងឆ្នាំ | ៧០% | ៧០% | ៧០% | ៨០% | ៨០% | ៩០% |
| | ភាគរយនៃសហគ្រាសដែលបានដាក់លិខិតប្រកាស | ៧៥% | កើនឡើង ១% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលដាក់លិខិតប្រកាសតាមប្រព័ន្ធអេឡិចត្រូចនិក (e-filing) | គ្មាន | កើនឡើង ២% ក្នុងមួយឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ចំនួនសហគ្រាសដែលបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក (e-payment) | ១៣១ | កើនឡើង ៥០% ក្នុងមួយឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលដាក់លិខិតប្រកាសទាន់ពេលវេលាសម្រាប់អ្នកជាប់ពន្ធធំ និងមធ្យម | ៦៨% | កើនឡើង ២% រៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបង់ប្រាក់ពន្ធទាន់ពេលវេលាសម្រាប់អ្នកជាប់ពន្ធធំ និងមធ្យម | ៧០% | កើនឡើង ២% រៀងរាល់ឆ្នាំ | | | | |
| | រយៈពេលនៃការទទួលលិខិតប្រកាស និងផ្ទៀងផ្ទាត់ | ១៥នាទី | ១០ | ១០ | ១០ | ៨ | ៨ |
| | រយៈពេលបម្រើសេវា (serving time) នៃការដាក់ពាក្យស្នើសុំប្រកាសបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនៅរាជធានីភ្នំពេញ | ១៥នាទី | ១០ | ១០ | ១០ | ៨ | ៨ |
| | ភាគរយនៃអចលនទ្រព្យដែលបានចុះបញ្ជីតាមរយៈអង្កេត | ១០០% | ១០០% | | | | |
| | ភាគរយនៃអចលនទ្រព្យដែលបានធ្វើបច្ចុប្បន្នភាពតាមរយៈអង្កេត | ១០០% | ១០០% | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • បង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ និងរៀបចំផែនការលើកទឹកចិត្តដល់មន្ត្រីផ្តល់សេវា | យន្តការត្រួតពិនិត្យ និងវាយតម្លៃការពង្រឹងគុណភាពសេវាអ្នកជាប់ពន្ធ ត្រូវបានបង្កើត | គ្មាន | | √ | | | |
| | ផែនការលើកទឹកចិត្តដល់មន្ត្រីផ្តល់សេវាត្រូវបានរៀបចំ | គ្មាន | | √ | | | |
| • ពង្រឹងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលពន្ធ សំដៅកាត់បន្ថយជាអតិបរមានូវបំណុលបច្ចុប្បន្ន និងជៀសវាងការកើនឡើងបំណុលពន្ធអនាគត | ចំនួនសហគ្រាសដែលស្ថិតក្នុងបញ្ជីបំណុលអាចប្រមូលបាន (បំណុលអាយុកាលតិចជាង ០៣ឆ្នាំ) | ២ ៨៤៣ សហគ្រាស | ថយចុះជារៀងរាល់ឆ្នាំ | | | | |
| | ភាគរយនៃសហគ្រាសដែលបានទូទាត់ | ១០% | កើនឡើង ១% រៀងរាល់ឆ្នាំ | | | | |
| | ចំនួនសហគ្រាសដែលស្ថិតក្នុងបញ្ជីបំណុលមិនអាចប្រមូលបាន (បំណុលអាយុកាលលើសពី ០៣ឆ្នាំ) | ២ ៩៩២ សហគ្រាស | ថយចុះជារៀងរាល់ឆ្នាំ | | | | |
| **គ. មុខងារគាំទ្រ** | | | | | | | |
| • ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ និងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាល និងរៀបចំប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មការងារ | ផែនការយុទ្ធសាស្ត្រធនធានមនុស្សត្រូវបានដាក់ឱ្យអនុវត្ត | គ្មាន | √ | | | | |
| | ចំនួនមន្ត្រីដែលបានទទួលការកសាងសមត្ថភាពត្រូវនឹងមុខងារស្នូលរបស់ខ្លួន | ១ ៣៦០ នាក់ | កើនឡើងជារៀងរាល់ឆ្នាំ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • អនុវត្តផែនការមេអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារពើពន្ធ ដែលមាន លក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា, ប្រព័ន្ធវិភាគទិន្នន័យ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអ្នកជាប់ពន្ធពេញលេញ, ប្រព័ន្ធផ្តល់សេវាអ្នកជាប់ពន្ធ និងប្រព័ន្ធចែករំលែកទិន្នន័យអន្តរស្ថាប័ន ដោយរួមបញ្ចូលទាំងផែនការវិនិយោគ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរដ្ឋបាលសារពើពន្ធ រួមមានមុខងារស្នូល (ចុះបញ្ជីពន្ធដារ, សេវាអ្នកជាប់ពន្ធ, ការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ, សវនកម្ម, បំណុល, និង វិវាទ) និងមុខងារគាំទ្រ ត្រូវបានធ្វើសមាហរណកម្ម និងស្វ័យប្រវត្តិកម្មពេញលេញ ត្រូវបានបង្កើត | គ្មាន | | | | √ | |
| • សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ឬបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិ និងលទ្ធភាពពេញលេញដល់រដ្ឋបាលសារពើពន្ធក្នុងការទទួលយកព័ត៌មាន និងទិន្នន័យពន្ធដារ (submission and management of taxation data) ដោយ ផ្តល់លទ្ធភាពតភ្ជាប់រវាងប្រព័ន្ធទិន្នន័យរបស់ស្ថាប័ននានាមកកាន់ប្រព័ន្ធទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ | របាយការណ៍លទ្ធផលនៃការសិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ឬបទប្បញ្ញត្តិស្តីពីការផ្តល់សិទ្ធិ និងលទ្ធភាពពេញលេញដល់រដ្ឋបាលសារពើពន្ធក្នុងការទទួលយកព័ត៌មាន និងទិន្នន័យពន្ធដារ | គ្មាន | | √ | | | |
| • សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតម្រូវការឱ្យអាជីវកម្មទាំងអស់ប្រើប្រាស់ប្រព័ន្ធ cash receipt system សម្រាប់ប្រតិបត្តិការជាមួយអតិថិជនទូទៅ (business to customers) ដោយសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ | របាយការណ៍លទ្ធផលនៃសិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងច្បាប់ស្តីពីតម្រូវការឱ្យអាជីវកម្មទាំងអស់ប្រើប្រាស់ប្រព័ន្ធ cash receipt system សម្រាប់ប្រតិបត្តិការជាមួយអតិថិជនទូទៅ (business to customers) | គ្មាន | | √ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| • រៀបចំក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីតម្រូវការនៃព័ត៌មាន និងនីតិវិធីនៃការបែងចែកព័ត៌មាន ហើយលើកសំណើរៀបចំនូវថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សំដៅធ្វើទំនើបកម្មសម្រួលកិច្ចការចុះបញ្ជីអាជីវកម្ម និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០១៩ | សេចក្តីសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីសិក្សាអំពីតម្រូវការនៃព័ត៌មាន និងនីតិវិធីនៃការបែងចែកព័ត៌មានហើយលើកសំណើរៀបចំនូវថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតម្រូវការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សំដៅធ្វើទំនើបកម្មសម្រួលកិច្ចការចុះបញ្ជីអាជីវកម្ម | គ្មាន | | √ | | | |
| • ពិនិត្យលទ្ធភាព, ភាពចាំបាច់ និងផលប៉ះពាល់លើការរៀបចំឡើងវិញការលើកទឹកចិត្តសវនករពន្ធដារ ដែលត្រូវផ្សារភ្ជាប់នឹងសូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ | លទ្ធផលនៃការសិក្សាការរៀបចំឡើងវិញការលើកទឹកចិត្តសវនករពន្ធដារ ដែលត្រូវផ្សារភ្ជាប់នឹងសូចនាករសមិទ្ធកម្មគន្លឹះ | គ្មាន | | √ | | | |
| • ដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ ដើម្បីធានាថា  មន្ត្រីអនុវត្តការងារប្រកប ដោយជំនាញឯកទេស និងក្រមសីលធម៌វិជ្ជាជីវៈ | ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មការងារ មន្ត្រីត្រូវបានប្រើប្រាស់ នៅគ្រប់នាយកដ្ឋាន និងសាខាខេត្ត-ខណ្ឌ | គ្មាន | | | √ | | |

## ឧបសម្ព័ន្ធ ២. សូចនាករសមិទ្ធកម្មគន្លឹះរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

| ល.រ | វិធានការទំនើបភាវូបនីយកម្ម នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សូចនាករ | បន្ទាត់មូលដ្ឋាន | គោលដៅប្រចាំឆ្នាំ |
|---|---|---|---|---|
| I. | កិច្ចសម្រួលពាណិជ្ជកម្ម | | | |
| ១ | កែលម្អវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ | វិធីសាស្ត្រនៃការកំណត់សូចនាករហានិភ័យ និងលក្ខខណ្ឌវិនិច្ឆ័យជ្រើសរើសហានិភ័យ ត្រូវបានអនុវត្ត | | ២០២០ |
| | | ភាគរយនៃចំនួន SAD សរុបដែលបានកំណត់ក្រោមច្រកក្រហម | ១០% | មិនលើស ៩% នៃចំនួន SAD សរុប (២០២០) |
| | | របាយការណ៍ចំនួនបទល្មើសគយក្រោយពីបានធ្វើការត្រួតពិនិត្យរូបវន្ត | | ២០២០ |
| ២ | ជំរុញការអនុវត្តប្រកាសលេខ ១៦០៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការផ្តល់សេវា សាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង ប្រកាសលេខ ៣២៨ សហវ.ប្រក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ និងនីតិវិធីនៃការកំណត់មុខសញ្ញាទំនិញនាំចេញ-នាំចូលផ្ទុកក្នុងកុងតែន័រ ឱ្យមានប្រសិទ្ធភាពខ្ពស់ | របាយការណ៍លទ្ធផល | | ២០១៩ |

| | | | | |
|---|---|---|---|---|
| ៣ | បញ្ចប់ការរៀបចំ និងធ្វើវិសោធនកម្មអនុក្រឹត្យលេខ ២០៩ អនក្រ.បក ដោយកាត់បន្ថយឱ្យបានជាអតិបរមា នូវមុខទំនិញជាប់កម្រិតកំណត់ និងមុខទំនិញហាមឃាត់ | អនុក្រឹត្យថ្មីត្រូវបានបង្កើត | | ២០២០ |
| ៤ | សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធទាំង ៥ ដើម្បីជំរុញដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិដំណាក់កាលទី ២ ឱ្យបានទាន់ពេលវេលាដូចដែលបានកំណត់ | ប្រព័ន្ធបញ្ចរតែមួយជាតិដំណាក់កាលទី ២ ត្រូវបានដាក់ឱ្យអនុវត្ត | | ២០១៩ |
| ៥ | បន្តធ្វើសាមញ្ញកម្ម, ទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀតស្របតាមស្តង់ដារអន្តរជាតិ សំដៅកែលម្អបន្ថែមទៀតនូវគុណភាពនៃការផ្តល់សេវា និងបង្កើនភាពពេញចិត្តរបស់អតិថិជន | របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃលើបញ្ជីទំនិញហាមឃាត់ និងជាប់កម្រិតកំណត់ (prohibited and restricted goods) និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | | ២០១៩ |
| | | ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ និងការផ្តល់លិខិតអនុញ្ញាតគយ ត្រូវបានធ្វើវិមជ្ឈការដោយផ្អែកលើគោលការណ៍ហានិភ័យ | | ប្រចាំឆ្នាំ |
| | | នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតគយត្រូវបានកាត់បន្ថយឱ្យខ្លី និងត្រូវបានធ្វើស្វ័យប្រវត្តិកម្ម | | ២០១៩ |
| | | ការត្រួតពិនិត្យដោយម៉ាស៊ីនស្កែនត្រូវបានកាត់បន្ថយ | | ២០១៩ |
| | | ចងក្រងបញ្ជីមុខទំនិញដែលចាំបាច់នៃការប្រើប្រាស់លិខិតអនុញ្ញាតគយសម្រាប់ការនាំចេញ និងការនាំចូល | | ២០២០ |

| | | | | |
|---|---|---|---|---|
| | | តម្រូវការឯកសារ hard copy សម្រាប់នីតិវិធីគយត្រូវបានកាត់បន្ថយ | | ២០២១ |
| | | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ត្រូវបានធ្វើសន្ទានកម្ម | | ២០២៣ |
| ៦ | រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយកិច្ចសម្រួលពាណិជ្ជកម្ម ប្រកបដោយការទទួលខុសត្រូវ | យន្តការតាមដាន និងវាយតម្លៃនៃការផ្តល់សេវាសាធារណៈ ត្រូវបានបង្កើត | | ២០១៩ |
| | | របាយការណ៍នៃការតាមដាន និងវាយតម្លៃ | | ២០១៩ |
| | | របាយការណ៍ការសិក្សារយៈពេលបញ្ចេញទំនិញពីគយ (time release study) | | ២០២០ |
| ៧ | ពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហានិភ័យ ជាពិសេសជំរុញការដាក់អនុវត្តនូវប្រព័ន្ធ pre-arrival information ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារត្រួតពិនិត្យ និងលើកកម្ពស់អនុលោមភាព | ប្រព័ន្ធ pre-arrival ព័ត៌មានត្រូវរៀបចំ និងអនុវត្តជាប្រព័ន្ធស្វ័យប្រវត្តិកម្ម | | ២០២២ |
| ៨ | ធ្វើឱ្យប្រសើរឡើងថែមទៀត នូវការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនមានអនុលោមភាពខ្ពស់ | កញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តត្រូវបានកែសម្រួលនិងដាក់ឱ្យអនុវត្ត | | ២០២១ |
| ៩ | ពង្រីកយន្តការធុរជនល្អបំផុត (best trader mechanism) និងឈានទៅអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (authorised economic operator - AEO) និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអត្ថប្រយោជន៍នៃយន្តការនេះ | ចំនួនសមាជិកក្រុមធុរជនល្អបំផុតត្រូវបានបង្កើន | | ២០២១ |
| | | យន្តការ AEO ត្រូវបានបង្កើត និងដាក់អនុវត្ត | | ២០២៣ |

| | | | | |
|---|---|---|---|---|
| ១០ | ពង្រីកវិសាលភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កែន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព | ចំនួនការប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យដោយម៉ាស៊ីនស្កែន និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព | | ២០២២ |
| ១១ | ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ | ប្រព័ន្ធបញ្ជរតែមួយជាតិដំណាក់កាលទី ៣ ចាប់ផ្តើមអនុវត្ត និងពង្រីកវិសាលភាពជាបន្តបន្ទាប់ | | ២០២០ |
| ១២ | តភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិរបស់កម្ពុជាទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន | ប្រព័ន្ធបញ្ជរតែមួយជាតិរបស់កម្ពុជាត្រូវបានតភ្ជាប់ទៅនឹងប្រព័ន្ធបញ្ជរតែមួយរបស់អាស៊ាន | | ២០២៣ |
| **II.** | **ការកែលម្អ និងពង្រឹងអភិបាលកិច្ច** | | | |
| ១ | ពង្រឹងការកំណត់សូចនាករ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់ក្នុងការជ្រើសរើសក្រុមហ៊ុនសម្រាប់ធ្វើសវនកម្ម ដោយផ្អែកលើហានិភ័យ | សូចនាករ និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស ក្រុមហ៊ុនសម្រាប់ធ្វើសវនកម្មត្រូវបានអនុវត្ត | | ២០២០ |
| ២ | ជំរុញការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយឱ្យបានទូលាយ (comprehensive customs audit) ជាជាងការធ្វើសវនកម្មតែលើឯកសារ (desk review audit) | ចំនួនសវនកម្មក្រោយពេលបញ្ចេញទំនិយពីគយដែលសម្រេចបានធៀបនឹងផែនការ | | ៥០% ក្នុងឆ្នាំ ២០២០ |
| | | យន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយឱ្យបានទូលាយ (comprehensive customs audit) ត្រូវបានអនុវត្ត | | ២០២០ |
| ៣ | បន្តពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ | មុខសញ្ញារងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ត្រូវបានបង្កើនចំនួន | | ២០២០ |

| | | | | |
|---|---|---|---|---|
| ៤ | ពង្រឹងសមត្ថភាពរបស់មន្ត្រីសវនកម្មគយ និងបង្កើនចំនួនអង្គភាពសវនកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង | ចំនួនអង្គភាពសវនកម្មត្រូវបានបង្កើត | | ២០២០ |
| | | ការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីសវនកម្មគយត្រូវបានបង្កើន | | ២០២០ |
| ៥ | បញ្ចប់យុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ (enforcement strategy) | យុទ្ធសាស្ត្រជំរុញការអនុវត្តច្បាប់ត្រូវបានបញ្ចប់ និងដាក់ឱ្យអនុវត្ត | | ២០២០ |
| ៦ | ជំរុញការអនុវត្តកម្រិតផ្តន្ទាទោសតាមប្រព័ន្ធតុលាការចំពោះបទល្មើសគយ ដែលមិនអាចសម្រុះសម្រួលដោះស្រាយដោយរដ្ឋបាលគយ | របាយការណ៍លទ្ធផល | | ២០២០ |
| ៧ | ពិនិត្យឡើងវិញលើសិទ្ធិរបស់អង្គភាពក្រោមឱវាទ អ.គ.រ. ក្នុងការសម្រុះសម្រួលបទល្មើសគយ តាមឋានានុក្រម | លិខិតបទដ្ឋានគតិយុត្តទាក់ទិននឹងសិទ្ធិក្នុងការសម្រុះសម្រួលបទល្មើសគយ ត្រូវបានកែសម្រួល | | ២០២០ |
| ៨ | តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងារបង្ការ និងបង្ក្រាបបទល្មើសគយតាមបណ្តាអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ | របាយការណ៍វាយតម្លៃប្រសិទ្ធភាពការងារតាមអង្គភាពត្រូវបានរៀបចំ | | ២០២០ |
| III. | **ការគ្រប់គ្រងបែបយុទ្ធសាស្ត្រ** | | | |
| ១ | ពិនិត្យ និងកំណត់មុខទំនិញដែលជាប្រភពចំណូលសំខាន់ និងពិនិត្យភាពចាំបាច់នៃការកំណត់មាត់ច្រកជាក់លាក់សម្រាប់ការនាំចូលមុខទំនិញទាំងនេះ តាមកម្រិតហានិភ័យ | មុខទំនិញដែលជាប្រភពចំណូលសំខាន់ៗ ត្រូវបានកំណត់ | | ២០២០ |
| | | មាត់ច្រកសម្រាប់ការនាំចេញនាំចូលមុខទំនិញខាងលើ ត្រូវបានកំណត់ | | ២០២០ |

| | | | | |
|---|---|---|---|---|
| ២ | បន្តពង្រឹងយន្តការផ្តល់ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម | របាយការណ៍លទ្ធផលត្រូវបានរៀបចំ | | ២០១៩ |
| ៣ | បញ្ចប់ការកសាងឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT Strategy) របស់ អ.គ.រ. | ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបញ្ចប់ និងដាក់អនុវត្ត | | ២០២០ |
| ៤ | រៀបចំផែនការដាក់លាក់ក្នុងការរៀបចំធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត ដើម្បីឆ្លើយតបនឹងតម្រូវការ ក៏ដូចជាការត្រៀមខ្លួនសម្រាប់ការវិវត្តនៃបច្ចេកវិទ្យាថ្មី និងការឈានឆ្ពោះទៅសម្រេចបាននូវអង្គភាពមួយដែលទំនើប | របាយការណ៍លទ្ធផលវាយតម្លៃតម្រូវការចាំបាច់នៃធនធានមនុស្សតាមអង្គភាពនៅគ្រប់កម្រិត និងតាមភូមិសាស្ត្រ | | ២០២១ |
| | | ផែនការដាក់លាក់ក្នុងការរៀបចំធនធានមនុស្សសម្រាប់ អ.គ.រ. | | ២០២១ |
| ៥ | ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ទានកម្មបច្ចេកវិទ្យាព័ត៌មានរបស់ អ.គ.រ. ឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, ប្រព័ន្ធបញ្ជរតែមួយជាតិ និង direct trader input (DTI) ។ល។ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ | ប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានាត្រូវបានធ្វើសន្ទានកម្ម | | ២០២៣ |

## ឧបសម្ព័ន្ធ ៣. សូចនាករវិធានការគោលនយោបាយសារពើពន្ធ

| ល.រ | វិធានការគោលនយោបាយសារពើពន្ធ | សូចនាករ | ឆ្នាំគោលដៅ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| I. | **គោលនយោបាយអាករពិសេស** | | | |
| ១ | កំណត់គោលការណ៍នៃរយៈពេលចូលជាធរមាន នៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស ក្នុងការធានាភាពប្រាកដប្រជានៃគោលនយោបាយ ដើម្បីសម្រួលដល់ការរៀបចំផែនការអាជីវកម្ម និងលំហូរសាច់ប្រាក់របស់ធុរជន | រយៈពេលចូលជាធរមាន នៃការផ្លាស់ប្តូរគោល-នយោបាយអាករពិសេសត្រូវបានកំណត់ | ២០២០ | កសហវ, អគរ, អពជ និង អគស |
| ២ | សិក្សា និងពិនិត្យឡើងវិញលើមូលដ្ឋានកំណត់អាករពិសេសរបស់ផលិតផលក្នុងស្រុក ដើម្បីរក្សាឧត្តមភាពប្រកួតប្រជែង និងលើកទឹកចិត្តឱ្យមានផលិតកម្មក្នុងស្រុកកាន់តែច្រើន | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អគរ, អពជ និង អគស |
| ៣ | ពិនិត្យឡើងវិញអត្រាអាករពិសេស និងមូលដ្ឋានគិតពន្ធលើយានយន្តភាតរបរិស្ថាន (environmentally friendly vehicles), ផលិតផលបារី, ស្រាបៀរ, ស្រា, និងភេសជ្ជៈមានជាតិស្ករ ។ល។ និងទំនិញប្រភេទប្រណិតមួយចំនួន ដើម្បីធានាសុខុមាលភាពប្រជាជន និងការពារបរិស្ថាន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ និង ក្រសួងពាក់ព័ន្ធ |
| ៤ | បន្តធ្វើវិចារណកម្មអត្រាពន្ធគយ និងអត្រាអាករពិសេសលើទំនិញ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០១៩ | កសហវ, អគរ, អពជ និង អគស |

| | | | | |
|---|---|---|---|---|
| ៥ | ពង្រឹងអនុលោមភាពការងារបច្ចេកទេសគយ តាមរយៈការពង្រឹងយន្តការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញ និងការជំរុញការលើកទឹកចិត្តអនុលោមភាពដោយស្ម័គ្រចិត្ត | នីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ចំណាត់ថ្នាក់ទំនិញ និងដើមកំណើតទំនិញត្រូវបានកែសម្រួល | ២០២០ | កសហវ, អគរ, អពដ និង អគស |
| | | មុខសញ្ញាមានហានិភ័យទាប ត្រូវបានកំណត់ដើម្បីផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្ត | ២០២០ | កសហវ, អគរ, អពដ និង អគស |
| ៦ | រៀបចំគោលនយោបាយអាករពិសេស ដើម្បីពង្រឹងភាពដែលអាចទស្សន៍ទាយបាន (predictability) នៃការផ្លាស់ប្តូរគោលនយោបាយអាករពិសេស និងលើកកម្ពស់បរិយាកាសធុរកិច្ច | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០១៩ | កសហវ, អពដ, អគរ, និង អគស |
| | | សេចក្តីព្រាងគោលនយោបាយអាករពិសេសត្រូវបានដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ | ២០២០ | |
| ៧ | រាល់សំណើកែប្រែគោលនយោបាយអាករពិសេស ត្រូវដាក់ឱ្យមានការពិគ្រោះយោបល់ក្នុងគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដើម្បីធានានូវប្រសិទ្ធភាព និងសង្គតិភាពក្នុងការអនុវត្ត | សំណើរលើការកែប្រែគោលនយោបាយអាករពិសេសត្រូវបានពិគ្រោះយោបល់ក្នុងគណៈកម្មាធិការគោល-នយោបាយសារពើពន្ធ | ២០១៩ | គណៈកម្មាធិការគោលនយោបាយសារពើពន្ធ |
| ៨ | ពិនិត្យលទ្ធភាពប្តូរប្រព័ន្ធអាករពិសេសពី ប្រភេទគិតតាមអត្រា (ad valorem) ទៅជាប្រព័ន្ធចម្រុះដែលគិតតាមអត្រាផងនិង/ឬគិតតាមឯកតាផង (mixed method) ដើម្បីធានាបានសមធម៌រវាងផលិតផលក្នុងស្រុក និងផលិតផលនាំចូល | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២១ | កសហវ, អគរ, អពដ និង អគស |
| | | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០១៩ | |

| | | | | |
|---|---|---|---|---|
| ៩ | រៀបចំឱ្យមានច្បាប់អាករពិសេសរួម និងគ្រប់ជ្រុងជ្រោយ ដើម្បីសម្រួលដល់ការគ្រប់គ្រង, ការអនុវត្ត និងការពង្រឹងអនុលោមភាព | កិច្ចប្រជុំរបស់ក្រុមការងារជាមួយតួអង្គពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងច្បាប់អាករពិសេស | ២០២០ | កសហវ, ក្រុមប្រឹក្សានីតិកម្ម, អគរ, អពជ និង អគស |
| | | សេចក្តីព្រាងច្បាប់អាករពិសេសត្រឹមកម្រិតក្រុមការងារ | ២០២១ | |
| | | សេចក្តីព្រាងច្បាប់អាករពិសេសត្រូវបានដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ | ២០២២ | |
| II. | **ពន្ធលើអចលនទ្រព្យ** | | | |
| ១ | រៀបចំ និងដាក់ឱ្យអនុវត្តកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) លើពន្ធអចលនទ្រព្យ ឱ្យស្របនឹងថ្លៃអចលនទ្រព្យដែលត្រូវធ្វើបច្ចុប្បន្នភាពសម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រាដោយដាក់ឱ្យអនុវត្តនៅឆ្នាំ ២០១៩ | លិខិតបទដ្ឋានគតិយុត្តលើការធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានគិតពន្ធត្រូវបានដាក់ឱ្យអនុវត្ត | ២០១៩ | កសហវ, អពជ, និង អគស |
| | | លិខិតបទដ្ឋានគតិយុត្តនៃការកែសម្រួលកម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) លើពន្ធអចលន-ទ្រព្យ ត្រូវបានដាក់ឱ្យអនុវត្ត | ២០២០ | |
| ២ | កំណត់គោលការណ៍ធ្វើបច្ចុប្បន្នកម្មថ្លៃអចលនទ្រព្យ សម្រាប់ជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងពន្ធប្រថាប់ត្រា និង កម្រិតអនុគ្រោះដែលទទួលបានការលើកលែងពីមូលដ្ឋានគិតពន្ធ (minimum threshold) រៀងរាល់ ៥ ឆ្នាំម្តង | លិខិតបទដ្ឋានគតិយុត្តក្នុងការកំណត់រយៈពេលនៃការធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានគិតពន្ធត្រូវបានដាក់ឱ្យអនុវត្ត | ២០២០ | កសហវ, អពជ, MOI, MOLMUC |

| | | | | |
|---|---|---|---|---|
| ៣ | ត្រួតពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យក្នុងរង្វង់ញាតិ | របាយការណ៍លទ្ធផលត្រួតពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អពជ និង អគស |
| ៤ | ពិនិត្យលទ្ធភាពលើការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អពជ និង អគស |
| ៥ | ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ចំនួនអ្នកបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | ២០១៩ | កសហវ, អពជ |
| ៦ | សិក្សា, រៀបចំ និងដាក់ចេញវិធានការបង្ការសកម្មភាពបរិកប្បកម្មលើអចលនទ្រព្យ (property speculation) | ក្រុមការងារ និងឯកសារទស្សនាទានត្រូវបានបង្កើត | ២០២០ | កសហវ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| | | របាយការណ៍លទ្ធផលសិក្សាត្រូវបានរៀបចំ | ២០២៣ | |
| **III.** | **អាករលើតម្លៃបន្ថែម** | | | |
| ១ | សិក្សាអំពីលទ្ធភាពរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាករលើតម្លៃបន្ថែម ដោយផ្តោតលើវិក្កយបត្រអាករ (tax invoice) និងវិក្កយបត្រអាករតាមប្រព័ន្ធអេឡិចត្រូនិក (e-tax system) ព្រមទាំងសិក្សារៀបចំផ្តល់ទាំងការលើកទឹកចិត្ត និងការដាក់ពិន័យទោសទណ្ឌចំពោះការប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ | របាយការណ៍លទ្ធផលសិក្សា និងបទប្បញ្ញត្តិគតិយុត្ត ត្រូវបានរៀបចំ | ២០២០ | កសហវ, អពជ, អគរ និង អគស |
| ២ | ពិនិត្យឡើងវិញលើការលើកលែងអាករលើតម្លៃបន្ថែមលើមុខទំនិញ ដែលជាអាហារជាមូលដ្ឋានសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងបទប្បញ្ញត្តិគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពជ និង អគរ |
| **IV.** | **អាករសម្រាប់បំភ្លឺសាធារណៈ** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពិនិត្យលទ្ធភាពធ្វើការកែសម្រួលអាករសម្រាប់បំភ្លឺសាធារណៈ ដើម្បីបង្កើនអនុលោមភាព, ផ្ដល់ភាពងាយស្រួលក្នុងការបង់ពន្ធ និងបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ, អគរ និង អគស |
| **V.** | **ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល** | | | |
| ១ | កសាងក្របខ័ណ្ឌគោលនយោបាយ សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល | ក្របខ័ណ្ឌគោលនយោបាយត្រូវបានបង្កើត | ២០២០ | កសហវ, អពដ និង អគស |
| ២ | ដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន (capital gain) | លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីគណនា ត្រូវបានរៀបចំ | ២០២០ | កសហវ និង អពដ |
| | | ផ្សព្វផ្សាយដល់សាធារណៈជន | ២០២០ | កសហវ និង អពដ |
| | | ពន្ធលើចំណេញមូលធនត្រូវបានអនុវត្ត | ២០២០ | កសហវ និង អពដ |
| ៣ | រៀបចំរដ្ឋបាលសារពើពន្ធដែលមានសមត្ថភាព និងឯកទេស សម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលប្រកបដោយប្រសិទ្ធភាព | រដ្ឋបាលសារពើពន្ធត្រូវបានពង្រឹងសមត្ថភាព | ២០២៣ | កសហវ និង អពដ |
| **VI.** | **ពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** | | | |
| ១ | សិក្សាលទ្ធភាពក្នុងការលើកទឹកចិត្តពន្ធ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ និងក្រសួងពាក់ព័ន្ធ |

| | | | | |
|---|---|---|---|---|
| ២ | សិក្សាលទ្ធភាពក្នុងការរៀបចំក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ដើម្បីត្រៀមគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | របាយការណ៍លទ្ធផលសិក្សា និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២៣ | កសហវ និងក្រសួងពាក់ព័ន្ធ |
| **VII.** | **វិធានការគោលនយោបាយសារពើពន្ធផ្សេងៗ** | | | |
| ១ | ដាក់កាតព្វកិច្ចបង់ពន្ធតាមរបបស្វ័យប្រកាសចំពោះអាជីវកម្មទាំងអស់ក្រៅពីសកម្មភាពល្បែង | លិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | ២០២០ | កសហវ, អពដ |
| ២ | ពិនិត្យឡើងវិញនូវផលរបរប្រចាំឆ្នាំ ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច, មធ្យម និងធំ ដើម្បីឆ្លើយតបទៅនឹងកំណើនសកម្មភាពធុរកិច្ច | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគស |
| ៣ | ពិនិត្យឡើងវិញកម្រិតប្រាក់ចំណូលអប្បបរមាជាប់ពន្ធប្រចាំឆ្នាំរបស់សហគ្រាសឯកបុគ្គល ដើម្បីលើកទឹកចិត្តការធ្វើអាជីវកម្ម | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគស |
| ៤ | ពិនិត្យឡើងវិញពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ (២០%) ចំពោះគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដើម្បីទាក់ទាញការវិនិយោគ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អពដ និង អគស |
| ៥ | ពិនិត្យឡើងវិញអត្រាពន្ធគយលើមុខទំនិញ ដែលមិនមែនជាប្រភពចំណូលនិងជាធាតុចូលសំខាន់សម្រាប់វិស័យអាទិភាព ដូចជា វិស័យកសិកម្ម, អប់រំ និងដឹកជញ្ជូន | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | កសហវ, អគរ, អពដ, និង អគស |
| ៦ | ពិនិត្យឡើងវិញលើគោលនយោបាយសារពើពន្ធលើវិស័យហិរញ្ញវត្ថុ | របាយការណ៍លទ្ធផលពិនិត្យឡើងវិញ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២២ | កសហវ, អពដ និង អគស |
| **VIII.** | **ការកែទម្រង់របបលើកទឹកចិត្តពន្ធនៅក្នុងច្បាប់ស្តីពីវិនិយោគ** | | | |

| | | | | |
|---|---|---|---|---|
| ១ | បញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីវិនិយោគ និងរៀបចំច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ឱ្យបានចប់សព្វគ្រប់នៅចុងឆមាសទី ១ ឆ្នាំ ២០១៩ | ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគត្រូវបានបញ្ចប់ | ឆមាសទី ១ ឆ្នាំ ២០១៩ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| | | ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសត្រូវបានរៀបចំ | ឆមាសទី ១ ឆ្នាំ ២០១៩ | |
| ២ | កំណត់វិស័យអាទិភាព និងរបបលើកទឹកចិត្តពន្ធដាក់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង | វិស័យអាទិភាព និងរបបលើកទឹកចិត្តពន្ធ ត្រូវបានកំណត់ និងដាក់បញ្ចូលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង | ២០២០ | កសហវ |
| **IX.** | **ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម** | | | |
| ១ | រៀបចំប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ១២៤, ៩១ និង ៩០ | ប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបង្កើត | ២០១៩ | កសហវ |
| ២ | សិក្សា និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តអនុក្រឹត្យទាំងបីខាងលើ និងស្នើសុំកែសម្រួលក្នុងករណីចាំបាច់ | របាយការណ៍វាយតម្លៃត្រូវបានរៀបចំ | ២០២១ | កសហវ |
| **X.** | **ការរៀបចំប្រព័ន្ធសារពើពន្ធ** | | | |
| ១ | សិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជា | ឯកសារស្តីពីប្រព័ន្ធសារពើពន្ធត្រូវបានរៀបចំ | ២០២៣ | កសហវ |

## ឧបសម្ព័ន្ធ ៤. សូចនាករសមិទ្ធកម្មគន្លឹះរបស់រដ្ឋបាលចំណូលមិនមែនសារពើពន្ធ

| ល.រ | វិធានការ | សូចនាករ | ឆ្នាំគោលដៅ | ក្រសួង-ស្ថាប័នទទួលខុសត្រូវ |
|---|---|---|---|---|
| I | **ទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការគ្រប់គ្រង** | | | |
| ១ | បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ដើម្បីសម្រួលដល់ការបង់ចំណូល, ការប្រើប្រាស់ប្រព័ន្ធធនាគារឱ្យបានពេញលេញ, ការបង់ចំណូលចូលគណនីទោលរតនាគារជាតិឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា, ការចងក្រងរបាយការណ៍ចំណូលក្នុងប្រព័ន្ធឱ្យកាន់តែមានតម្លាភាព និងឆាប់រហ័ស និងបញ្ចូលកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ ចូលក្នុងប្រព័ន្ធ ដើម្បីធានាតម្លាភាព និងការតាមដានកាន់តែមានប្រសិទ្ធភាព | រាល់ប្រតិបត្តិការចំណូលត្រូវបានឆ្លងកាត់ប្រព័ន្ធ NRMIS | ២០២០ | កសហវ និង ក្រសួង-ស្ថាប័នប្រមូលចំណូល (ថ្នាក់ជាតិ) |
| | | | ២០២២ | កសហវ និង រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | | ចំនួនកិច្ចសន្យា កិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណបន្ថែមត្រូវបានបញ្ចូលក្នុងប្រព័ន្ធ NRMIS | ២០២០ | កសហវ និងក្រសួង-ស្ថាប័នប្រមូលចំណូល |
| ២ | បន្តអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិសម្រាប់ដាក់ឱ្យអនុវត្តដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងជំរុញឱ្យការរៀបចំបញ្ជីក្នុងប្រព័ន្ធ និងការរៀបចំបណ្ណកម្មសិទ្ធិឱ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ | ប្រព័ន្ធក្រៅបណ្ដាញ (offline) ត្រូវបានដាក់ឱ្យប្រើប្រាស់ដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | កសហវ និងក្រសួង-ស្ថាប័នជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ |
| | | ប្រព័ន្ធអនឡាញ (online system) ត្រូវបានអនុវត្តដល់គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២៣ | កសហវ និងក្រសួង-ស្ថាប័នជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ |

| | | | | |
|---|---|---|---|---|
| ៣ | សិក្សាស៊ីជម្រៅស្តីពីនីតិវិធីនៃការផ្លាស់ប្តូរការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ ឬជាការប្រើប្រាស់ e-payment | លទ្ធផលជាក់លាក់ស្តីពីនីតិវិធីនៃការផ្លាស់ប្តូរការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់មកជាវិធីសាមញ្ញ ឬជាការប្រើប្រាស់ e-payment ត្រូវបានបញ្ចប់ ដោយក្នុងនោះមានទាំងលទ្ធផលនៃការសិក្សា រៀបចំលិខិតបទដ្ឋានគតិយុត្ត និងការងារបច្ចេកទេសព័ត៌មានវិទ្យា | ២០២១ | កសហវ និងក្រសួងស្ថាប័នប្រមូល-ចំណូល |
| **II** | **បទប្បញ្ញត្តិគោលពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ** | | | |
| ១ | សិក្សា និងរៀបចំឯកសារគោល (blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ | ឯកសារគោល (blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ | ២០២០ | កសហវ |
| ២ | អនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ២០២២ | កសហវ |
| ៣ | អនុម័តច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ច្បាប់ស្តីពីការគ្រប់គ្រង, ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ២០២០ | កសហវ |
| **III** | **វិធានការតាមវិស័យ និងប្រភពចំណូលសំខាន់ៗ** | | | |
| ១ | សិក្សាឡើងវិញ និងរៀបចំយន្តការស្តង់ដារក្នុងការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈ ឈរលើគោលការណ៍សមធម៌ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល | ចងក្រងឯកសារ និងយន្តការស្តង់ដារក្នុងការគ្រប់គ្រង, ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈ | ២០២២ | ក្រសួង-ស្ថាប័នប្រមូលចំណូល និងកសហវ |

| | | | | |
|---|---|---|---|---|
| **ក** | **វិស័យអាកាសចរណ៍ស៊ីវិល** | | | |
| ១ | បន្តសិក្សា និងពិនិត្យលទ្ធភាពកែសម្រួលកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាកម្មចរាចរណ៍ផ្លូវអាកាសកម្ពុជា និងក្រុមហ៊ុនសម្បទានព្រលានយន្តហោះកម្ពុជាឱ្យឆ្លុះបញ្ចាំងពីកំណើនជើងហោះហើរឡើង/ ចុះ និងហោះ ឆ្លងកាត់ដែនអាកាសកម្ពុជា និងធានាឱ្យបាននូវលក្ខខណ្ឌដែលអំណោយផលដល់ការអភិវឌ្ឍវិស័យនេះ និងកំណើនចំណូលសមស្រប | កិច្ចសន្យាថ្មីដែលត្រូវបានធ្វើវិសោធនកម្ម ឬ របាយការណ៍ហេតុផលនៃការមិនធ្វើវិសោធនកម្ម ក្នុងករណីមិនមានការកែសម្រួល | ២០២០ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង កសហវ |
| **ខ** | **វិស័យទេសចរណ៍** | | | |
| ១ | បន្តជំរុញការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារ | រាល់អាជ្ញាបណ្ណទេសចរណ៍ត្រូវស្នើសុំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងចំណូលត្រូវបង់តាមធនាគារ | ២០២០ | ក្រសួងទេសចរណ៍ និង កសហវ |
| ២ | សិក្សាកែតម្រូវប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ ដើម្បីសម្រួលដល់ការធ្វើអាជីវកម្ម និងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ថ្មីៗ | ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណទេសចរណ៍ | ២០១៩ | ក្រសួងទេសចរណ៍ |
| ៣ | រៀបចំបែងចែកតួនាទីគ្រប់គ្រងរមណីយដ្ឋានឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធ | លិខិតបទដ្ឋានស្តីពីការបែងចែកតួនាទីគ្រប់គ្រងរមណីយដ្ឋានរបស់ស្ថាប័នពាក់ព័ន្ធ | ២០២០ | ក្រសួងទេសចរណ៍, កសហវ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ៤ | បន្តអភិវឌ្ឍប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ និងជំរុញឱ្យគ្រប់ម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ស្នើសុំការវាយតម្លៃចំណាត់ថ្នាក់តាមប្រព័ន្ធ | ប្រព័ន្ធកំណត់ចំណាត់ថ្នាក់សេវាកម្មទេសចរណ៍ត្រូវបានដាក់អនុវត្ត | ២០២០ | ក្រសួងទេសចរណ៍ |

| | | | | |
|---|---|---|---|---|
| ៥ | សិក្សានិងពិនិត្យលទ្ធភាពអភិវឌ្ឍន៍រមណីយដ្ឋានដែលមានសក្ដានុពលដើម្បីទាក់ទាញភ្ញៀវទេសចរ និងប្រមូលចំណូលឱ្យអស់លទ្ធភាព | របាយការណ៍លទ្ធផលនៃការសិក្សា ស្ដីពីការអភិវឌ្ឍរមណីយដ្ឋានសក្ដានុពល | ២០២២ | ក្រសួងទេសចរណ៍ |
| **គ** | **ចំណូលពីអាករស្ថានទូត** | | | |
| ១ | ពង្រឹងការរៀបចំរបាយការណ៍ស្ដីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ផ្អែកលើនីតិវិធីនៃការកត់ត្រា និងតាមដានសន្និធិ តាមវិធីសាស្ត្រឃ្លាំងសន្និធិ (stock inventory) នៅគ្រប់ចំណុចគោលដៅ ដែលមានសមត្ថកិច្ចផ្ដល់ទិដ្ឋាការជូនភ្ញៀវទេសចររួមមាន ច្រកអន្តរជាតិ, ស្ថានទូត, ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយស | របាយការណ៍ស្ដីពីចំណូលអាករស្ថានទូត, ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ត្រូវបានផ្ដល់ជូន កសហវ ឱ្យបានទៀងទាត់ | ប្រចាំត្រីមាស | ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| ២ | សិក្សាលទ្ធភាពកែសម្រួលកម្រៃទិដ្ឋាការសម្រាប់ជនអន្តោប្រវេសន៍ចេញ-ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា | របាយការណ៍សិក្សា និងលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ | ២០២០ | ក្រសួងមហាផ្ទៃ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង កសហវ |
| **ឃ** | **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ១ | ជំរុញការប្រើប្រាស់ប្រកាសរួមស្ដីពីការដាក់ឱ្យអនុវត្តទិន្នន័យពីមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យទូរគមនាគមន៍ (DMC) ឱ្យមានប្រសិទ្ធភាពដើម្បីជាមូលដ្ឋានក្នុងការប្រមូលចំណូលពន្ធ និងមិនមែនពន្ធ | ប្រសិទ្ធភាព និងស័ក្ដិសិទ្ធិភាពនៃប្រកាសរួមស្ដីពីការដាក់ឱ្យអនុវត្តទិន្នន័យ DMC | ២០១៩ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ២ | គ្រប់គ្រង និងប្រមូលចំណូលពីវិសាលគមន៍ប្រេកង់វិទ្យុ (radio frequency spectrum) ដែលជាធនធានកម្មរបស់ជាតិ និងចំណូល | កំណើនចំណូលថ្មីពីវិសាលគមន៍ប្រេកង់វិទ្យុ (radio frequency spectrum) | ២០១៩ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |

| | | | | |
|---|---|---|---|---|
| | ផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ តាមរយៈការដកហូតអាជ្ញាបណ្ណប្រេកង់ទំនេរដែលមិនបានប្រើប្រាស់ ព្រមទាំងការដាក់ឱ្យដេញថ្លៃ (auction) ប្រេកង់ទំនេរនិងមានតម្រូវការ | | | |
| ៣ | អនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ឱ្យបានពេញលេញ និងពន្លឿនបញ្ចប់បទប្បញ្ញត្តិគាំទ្រ ព្រមទាំងពង្រឹងការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់នៅក្នុងវិស័យនេះ | ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍ និងអនុវត្តបទប្បញ្ញត្តិគាំទ្រ | ២០២០ | កសហវ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| ៤ | ធ្វើវិសោធនកម្មច្បាប់ស្តីពីវិស័យប្រៃសណីយ៍ | ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ត្រូវបានធ្វើវិសោធនកម្ម | ២០២០ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| **ង** | **ដីសម្បទានសេដ្ឋកិច្ច** | | | |
| ១ | ពន្លឿននីតិវិធីរៀបចំឡើងវិញនូវកិច្ចសន្យា ឬ កិច្ចសន្យាកែសម្រួលពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាព ពិសេសជំរុញការអនុវត្តច្បាប់ និង លិខិតបទដ្ឋាននានាឱ្យបានម៉ឺងម៉ាត់ | ៥០% នៃកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចទាំងអស់ ត្រូវបានរៀបចំឡើងវិញស្របតាមបទ-ប្បញ្ញត្តិជាធរមាន | ២០១៩ | កសហវ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រសួងបរិស្ថាន |
| | | ១០០% នៃកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចទាំងអស់ ត្រូវបានរៀបចំឡើងវិញស្របតាមបទ-ប្បញ្ញត្តិជាធរមាន | ២០២០ | កសហវ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, និងក្រសួងបរិស្ថាន |

| | | | | |
|---|---|---|---|---|
| ២ | រៀបចំយន្តការគ្រប់គ្រងការផ្ទេរឬលក់ដីសម្បទានសេដ្ឋកិច្ច ក្រោមរូបភាពជាការផ្ទេរភាគហ៊ុនឬផ្លាស់ប្តូរឈ្មោះម្ចាស់ក្រុមហ៊ុន ដើម្បីបង្កើនការប្រមូលចំណូលឱ្យអស់លទ្ធភាព | លិខិតបទដ្ឋានស្តីពីយន្តការគ្រប់គ្រងការផ្ទេរ ឬលក់ដីសម្បទានសេដ្ឋកិច្ច | ២០២០ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង កសហវ |
| ៣ | ពិនិត្យឡើងវិញលើថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច និងពិនិត្យបែងចែកចំណូលពីដីសម្បទានសេដ្ឋកិច្ចទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ៥០% នៃចំណូលត្រូវបែងចែកជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | ២០២០ | កសហវ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤ | ការផ្លាស់ប្តូរការបង់ចំណូលដីសម្បទានសេដ្ឋកិច្ចពីការបង់ចំណូលតាមទំហំផ្ទៃដីអនុញ្ញាតឈូសឆាយ មកជាការបង់ចំណូលតាមទំហំផ្ទៃដីផ្តល់ជូនដែលមានចែងក្នុងកិច្ចសន្យាសម្បទាន អនុវត្តតាមគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាល | លក្ខខណ្ឌនេះ ត្រូវបានកែសម្រួលបញ្ចូលទៅគ្រប់កិច្ចសន្យាលិខិតអនុញ្ញាត/កិច្ចព្រមព្រៀង/ពាក់ព័ន្ធនានា នៃសម្បទានដីសេដ្ឋកិច្ច ឬតាមរយៈលិខិតបទដ្ឋានគតិយុត្តដើម្បីដាក់ឱ្យអនុវត្ត | ២០២០ | កសហវ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **ច** | **ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍** | | | |
| ១ | ពង្រឹងការអនុវត្តប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាស្តីពីការគ្រប់គ្រងចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យមានប្រសិទ្ធភាព និងជំរុញការអនុវត្តកាតព្វកិច្ចបង់ចំណូលតាមកិច្ចសន្យាជួលឱ្យបានពេញលេញ | កំណើនចំណូលពីកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាន | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ២ | សិក្សាលទ្ធភាពកែសម្រួលថ្លៃជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋានឱ្យស្របតាមថ្លៃទីផ្សារជាក់ស្តែង និង ការផ្តល់រយៈពេលអនុគ្រោះលើការបង់ថ្លៃឈ្នួល ដោយភ្ជាប់លក្ខខណ្ឌជាមួយនឹងវឌ្ឍនភាពនៃការអនុវត្តគម្រោង/កិច្ចសន្យា | របាយការណ៍លទ្ធផលសិក្សាត្រូវបានរៀបចំ | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |

| | | | | |
|---|---|---|---|---|
| ៣ | អនុវត្តការបង់កម្រៃចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន | កំណើនចំណូលពីការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា | ២០២០ | កសហវ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| **ឆ** | **សហគ្រាសសាធារណៈ** | | | |
| ១ | រៀបចំក្របខ័ណ្ឌគតិយុត្តថ្មីឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យជំរុញការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ | ក្របខ័ណ្ឌគតិយុត្តថ្មីត្រូវបានរៀបចំ | ២០២២ | កសហវ, ក្រសួងអាណាព្យាបាលបច្ចេកទេស និងសហគ្រាសសាធារណៈនីមួយៗ |
| **ជ** | **គ្រឹះស្ថានសាធារណៈរដ្ឋបាល** | | | |
| ១ | គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវអនុវត្តតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី ឱ្យបានពេញលេញ ដើម្បីធានាតម្លាភាពនៃប្រតិបត្តិការរបស់គ្រឹះស្ថាន | គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្តពេញលេញតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី | ២០២០ | កសហវ, ក្រសួងអាណាព្យាបាលបច្ចេកទេស និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ |
| **ឈ** | **វិស័យរ៉ែ និងថាមពល** | | | |
| ១ | សិក្សា និងធ្វើបច្ចុប្បន្នភាព កាតព្វកិច្ចហិរញ្ញវត្ថុនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ឱ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងផ្តល់ផលប្រយោជន៍ជូនភាគីរាជរដ្ឋាភិបាល | ៥០% នៃកាតព្វកិច្ចហិរញ្ញវត្ថុ នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាននឹងត្រូវបានពិនិត្យឡើងវិញ (ឆ្នាំគោល ២០១៨) | ២០២០ | ក្រសួងរ៉ែ និងថាមពល និង កសហវ |

| | | | | |
|---|---|---|---|---|
| | | ១០០% នៃកាតព្វកិច្ចហិរញ្ញវត្ថុ នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាននឹងត្រូវបានពិនិត្យឡើងវិញ (ឆ្នាំគោល ២០១៨) | ២០២៣ | ក្រសួងរ៉ែ និងថាមពល និង កសហវ |
| ២ | ពង្រឹងប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ, | កំណើនចំណូលពីការកៀរគរការប្រមូលចំណូលពីសួយសារ | ២០២០ | ក្រសួងរ៉ែ និងថាមពល និង កសហវ |
| ៣ | រៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល | ប្រព័ន្ធព័ត៌មានគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ត្រូវបានបង្កើត | ២០២០ | ក្រសួងរ៉ែ និងថាមពល |
| ៤ | រៀបចំលិខិតបទដ្ឋានដើម្បីកំណត់ឱ្យក្រុមហ៊ុនអាជីវកម្មរ៉ែមានប្រធានការដ្ឋានដែលមានជំនាញច្បាស់លាស់នៅគ្រប់ការដ្ឋានរ៉ែ | លិខិតបទដ្ឋានត្រូវបានរៀបចំ | ២០២០ | ក្រសួងរ៉ែ និងថាមពល |
| | | ៣០% នៃការដ្ឋានរ៉ែមានប្រធានការដ្ឋានដែលមានជំនាញទទួលស្គាល់ដោយក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើនចំណូល | ២០២១ | ក្រសួងរ៉ែ និងថាមពល |
| | | ១០០% នៃការដ្ឋានរ៉ែមានប្រធានការដ្ឋានដែលមានជំនាញទទួលស្គាល់ដោយក្រសួងរ៉ែ និងថាមពល ដើម្បីបង្កើនចំណូល | ២០២៣ | ក្រសួងរ៉ែ និងថាមពល |
| **៣** | **ចំណូលពីសកម្មភាពល្បែង** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពន្លឿនការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ច្បាប់ | ច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មត្រូវបានអនុម័ត និងដាក់ឱ្យប្រើប្រាស់ | ២០២០ | កសហវ និងក្រសួងមហាផ្ទៃ |
| | | អនុក្រឹត្យ ឬប្រកាស ត្រូវបានបង្កើត | ២០២១ | |
| ២ | បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់ | ចំនួនករណីអាជីវកម្មល្បែងខុសច្បាប់ត្រូវបានបង្ក្រាប | ២០២០ | កសហវ និងក្រសួងមហាផ្ទៃ |
| ៣ | បន្តខិតខំកៀរគរចំណូលឱ្យអស់ពីលទ្ធភាពពីសកម្មភាពល្បែងគ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលតាមបទប្បញ្ញត្តិជាធរមាន | កំណើនចំណូល | ២០២០ | កសហវ |
| **ង** | **ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** | | | |
| ១ | ពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន | ៥០% នៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋត្រូវបានពិនិត្យឡើងវិញ | ២០១៩ | កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| | | ១០០% នៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋត្រូវបានពិនិត្យឡើងវិញ | ២០២០ | កសហវ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ |
| ២ | ពង្រឹងយន្តការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធានាការអភិវឌ្ឍ និងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព | របាយការណ៍ស្តីពីការចុះត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ | ២០២០ | កសហវ |

| | | | | |
|---|---|---|---|---|
| ៣ | សិក្សា និងពិនិត្យលទ្ធភាពបង្កើតតំបន់អចលនវត្ថុរបស់រដ្ឋ ឱ្យស្របទៅតាមផែនការមេនៃការរៀបចំទីក្រុង (urban development master plan) | របាយការណ៍លទ្ធផលនៃការសិក្សា | ២០២១ | កសហវ |
| ៤ | សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍ ស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាធារណៈ | របាយការណ៍លទ្ធផលនៃការសិក្សា | ២០២២ | កសហវ, ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ និងអាជ្ញាធរមូលដ្ឋាន |
| ៥ | សហការជាមួយក្រសួងទទួលបន្ទុក និងអាជ្ញាធរដែនដីចុះពិនិត្យផ្ទាល់ការអនុវត្ត និងផ្ទៀងផ្ទាត់លើការបង់ចំណូលពីការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចជាការចាក់ដីបំពេញបឹង, ឆ្នេរ, ទន្លេ និងការយកដីសាធារណៈរបស់រដ្ឋដទៃទៀត ដើម្បីផលប្រយោជន៍ឯកជន ហើយត្រូវអនុវត្តតាមច្បាប់ និងនីតិវិធីជាធរមាន ព្រមទាំងបង់ចំណូលចូលថវិការដ្ឋតាមតម្លៃទីផ្សារជាក់ស្តែង | ចុះពិនិត្យផ្ទៀងផ្ទាត់នៅតំបន់ដែលមានការអភិវឌ្ឍខ្លាំង | ២០២០ | កសហវ, ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានីខេត្ត |
| | | ស្នើសុំគោលការណ៍ និងសេចក្តីណែនាំពីថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/រាជរដ្ឋាភិបាល | | |
| | | បំពេញនីតិវិធីលើការចាត់ចែងទ្រព្យសម្បត្តិរដ្ឋតាមបទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន | | |
| | | បង្កើនការបង់ចំណូលចូលថវិការដ្ឋ | | |
| **ថ** | **ចំណូលពីការចាត់ចែងវត្ថុតាងរឹបអូសពីបទល្មើស** | | | |

| | | | | |
|---|---|---|---|---|
| ១ | ពន្លឿនការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ ឬចាត់ចែងទ្រព្យសម្បត្តិរឹបអូសពីបទល្មើសនានា និងបង់ចំណូលចូលថវិការដ្ឋ ស្របតាមនីតិវិធីជាធរមាន មុនមានសាលក្រម/ សាលដីកាស្ថាពរ | ច្បាប់ពាក់ព័ន្ធត្រូវបានធ្វើវិសោធនកម្ម | ២០២០ | ក្រសួងយុត្តិធម៌ |
| ២ | រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាសម្រាប់ចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូស | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាត្រូវបានរៀបចំ | ២០២១ | ក្រសួងយុត្តិធម៌ |